ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា



# របាយការណ៍ស្តីពីប្រសិទ្ធភាពកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនៅកម្ពុជា

រៀបចំដោយ

គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ខែ មករា ឆ្នាំ ២០១៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា



# របាយការណ៍ស្តីពីប្រសិទ្ធភាពកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនៅកម្ពុជា

រៀបចំដោយ

គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ខែ មករា ឆ្នាំ ២០១៨

**មាតិការឿង**

*អារម្ភកថា*

*ខ្លឹមសារសង្ខេបប្រតិបត្តិ* i - vi

*ជំពូក ១ - សេចក្តីផ្តើម* ១-៤

*ជំពូក ២ - កម្ពុជាក្នុងឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួច* ៥

ស្ថានភាពហិរញ្ញប្បទានសម្រាប់កិច្ចអភិវឌ្ឍន៍ក្នុងបរិការណ៍ប្រទេសមានចំណូលមធ្យមកម្រិតទាប ៦

អត្ថប្រយោជន៍សម្រាប់កម្ពុជា និងប្រទេសមានការអភិវឌ្ឍតិចតួចដទៃទៀត ៦

វឌ្ឍនភាពរបស់កម្ពុជាក្នុងការឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច ៩

ស្ថានភាពកម្ពុជាក្នុងការសម្រេចលក្ខខណ្ឌសម្រាប់ឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច ១១

អាទិភាពគោលនយោបាយសម្រាប់កម្ពុជាឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច ១១

ផលប៉ះពាល់បន្ទាប់ពីឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច ១២

ផលប៉ះពាល់លើភាពប្រកួតប្រជែងសម្រាប់កម្ពុជាបន្ទាប់ពីឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច ១៣

ទិសដៅអាទិភាពរបស់កម្ពុជា ១៣

*ជំពូក ៣ - ការវិវត្តនៃហិរញ្ញប្បទានសហប្រតិបត្តិការ* ១៥

ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ ឆ្នាំ ២០០៨-២០១៨ ១៥

ការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ ២០០៨-២០១៨ ១៧

ការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការតាមវិស័យ ឆ្នាំ ២០០៨-២០១៨ ១៨

និន្នាការសំខាន់ៗនៃការបើកផ្តល់កម្ចីសម្បទាន ឆ្នាំ ២០១៤-២០១៨ ២០

ទម្រង់នៃការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ ២០០៨-២០១៨ ២១

ការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយអាទិភាពជាតិ ២២

ការចូលរួមរបស់ដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសចម្រុះ ២៣

ភាពទស្សន៍ទាយបាននៃហិរញ្ញប្បទានសហប្រតិបត្តិការ ឆ្នាំ ២០១៦ ២៥

គណនេយ្យភាពទ្វេទិសដោយផ្តោតលើលទ្ធផល ២៦

ការគាំទ្រដល់រាជធានី-ខេត្ត ២៧

ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៧ ២៩

*ជំពូក ៤ - ស្ថានភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្នុងអន្តរវិស័យ* ៣២

ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់លើកកម្ពស់សមភាពយេនឌ័រ ៣៣

ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការប្រែប្រួលអាកាសធាតុ ៣៥

ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការអភិវឌ្ឍវិស័យឯកជន ៣៨

***ជំពូក ៥ – តួនាទីហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការគាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្ម*** ៤១

តួនាទីហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការអភិវឌ្ឍវិស័យ
ឧស្សាហកម្មនៅកម្ពុជា ៤២

ការវិភាគហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រគោលនយោបាយ
អភិវឌ្ឍន៍វិស័យឧស្សាហកម្ម ៤៣

ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ
និងឧត្តមសិក្សា ៤៧

***ជំពូក ៦ – សេចក្តីសន្និដ្ឋាន*** ៥០

# បញ្ជីតារាង

២.១- ដំណើរការឆ្លងផុតពីប្រទេសមានការអភិវឌ្ឍតិចតួច ១០
៣.១- ការបើកផ្ដល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ឆ្នាំ ២០០៨-២០១៨ ១៨
៣.២- ការបើកផ្ដល់ហិរញ្ញប្បទានតាមវិស័យ ឆ្នាំ ២០០៨-២០១៨ ១៩
៣.៣- ការបើកផ្ដល់កម្ចីសម្បទានតាមវិស័យឆ្នាំ ២០១៤-២០១៨ ២១
៣.៤- ការបើកផ្ដល់ហិរញ្ញប្បទាន និងសកម្មភាពរបស់ដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារ
បច្ចេកទេសចម្រុះ ឆ្នាំ ២០១៧ ២៤
៣.៥- ការបើកផ្ដល់ហិរញ្ញប្បទានតាមរាជធានី-ខេត្ត ២៨
៣.៦- ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាល ឆ្នាំ ២០១៥-២០១៧ ២៩
៣.៧- ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗ ឆ្នាំ ២០១៥-២០១៧ ៣០
៤.១-វិស័យសម្គាល់បន្ថែម ៣៣
៤.២- ការបញ្ច្រាបសមភាពយេនឌ័រតាមវិស័យ ឆ្នាំ ២០១៦-២០១៧ ៣៤
៤.៣- ការបញ្ច្រាបសមភាពយេនឌ័ររបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ ២០១៦-២០១៧ ៣៥
៤.៤- ការបញ្ច្រាបការប្រែប្រួលអាកាសធាតុតាមវិស័យ ឆ្នាំ ២០១៦-២០១៧ ៣៦
៤.៥- ការបញ្ច្រាបការប្រែប្រួលអាកាសធាតុរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ ២០១៦-២០១៧ ៣៧
៤.៦- ការបញ្ច្រាបការអភិវឌ្ឍវិស័យឯកជនតាមវិស័យ ឆ្នាំ២០១៦-២០១៧ ៣៩
៤.៧- ការបញ្ច្រាបរបស់ដៃគូអភិវឌ្ឍន៍ក្នុងការអភិវឌ្ឍវិស័យឯកជន ឆ្នាំ ២០១៦-២០១៧ ៤០
៥.១-វិធានការគោលនយោបាយ និងវិធានការគន្លឹះ ៤ ជាក់ស្ដែង ៤១
៥.២- ការគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ ២០១៧ ៤៣
៥.៣- ធនធានរយៈពេលមធ្យមសម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ៤៤
៥.៤- ការបញ្ច្រាបគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មរបស់ដៃគូអភិវឌ្ឍន៍
ឆ្នាំ ២០១៦-២០១៧ ៤៦
៥.៥- ការបញ្ច្រាបគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មតាមវិស័យ ឆ្នាំ ២០១៦-២០១៧ ៤៧
៥.៦- ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍សម្រាប់ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស
និងវិជ្ជាជីវៈ និងឧត្ដមសិក្សា ៤៩

## បញ្ជីគំនូរ

២.១- លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ឆ្លងផុតពីប្រទេសមានការអភិវឌ្ឍតិចតួច ៥
២.២- សន្ទស្សន៍នៃភាពងាយរងគ្រោះខាងសេដ្ឋកិច្ច ១១
៣.១- ការបើកផ្តល់ហិរញ្ញប្បទាន ឆ្នាំ ២០០៨-២០១៨ ១៦
៣.២- ហិរញ្ញប្បទានសម្រាប់ប្រជាជនម្នាក់ និងអនុបាតហិរញ្ញប្បទានធៀបនឹង ផ.ស.ស ឆ្នាំ ២០០៧-២០១៧ ១៦
៣.៣- ទម្រង់នៃការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ ២០០៨-២០១៨ ២២
៣.៤- ការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២២
៣.៥- ការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២២
៣.៦- ការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍សម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២៣
៣.៧- ភាពអាចទស្សន៍ទាយបាននូវហិរញ្ញប្បទានសហប្រតិបត្តិការតាមវិស័យ និងដៃគូអភិវឌ្ឍន៍ ក្នុងឆ្នាំ ២០១៦ ២៦
៣.៨- ការគាំទ្រតាមរាជធានី-ខេត្ត ២៨
៣.៩- ការគាំទ្រតាមវិស័យរបស់អង្គការមិនមែនរដ្ឋាភិបាល ២៩
៣.១០- ភាគរយនៃធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ ២៩

## បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១ : ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការតាមដៃគូអភិវឌ្ឍន៍ និងតាមវិស័យ ឆ្នាំ ២០១៥
ឧបសម្ព័ន្ធទី ២ : ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការតាមដៃគូអភិវឌ្ឍន៍ និងតាមវិស័យ ឆ្នាំ ២០១៦
ឧបសម្ព័ន្ធទី ៣ : ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការតាមដៃគូអភិវឌ្ឍន៍ និងតាមវិស័យ ឆ្នាំ ២០១៧
ឧបសម្ព័ន្ធទី ៤ : ការបើកផ្តល់ និងការព្យាករណ៍ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ ២០០០-២០១៨
ឧបសម្ព័ន្ធទី ៥ : ការបើកផ្តល់ និងការព្យាករណ៍ហិរញ្ញប្បទានសហប្រតិបត្តិការតាមវិស័យ ឆ្នាំ ២០០០-២០១៨
ឧបសម្ព័ន្ធទី ៦ : ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការតាមខេត្ត និងរាជធានី ឆ្នាំ ២០១៥-២០១៨

# អារម្ភកថា

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលបានសម្រេចវឌ្ឍនភាពធំធេងក្នុងការអនុវត្តរបៀបវារៈអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ដោយមានការចូលរួមពីតួអង្គអភិវឌ្ឍន៍ ដើម្បីលើកកម្ពស់លទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព ។ ការលើកកម្ពស់គុណភាពសេវាសាធារណៈ និងការអនុវត្តការកែទម្រង់ស៊ីស្វូល រួមមាន ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការកែទម្រង់រដ្ឋបាលសាធារណៈ និងការកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានបង្ហាញអំពីភាពដឹកនាំ និងសមត្ថភាពដ៏រឹងមាំរបស់រាជរដ្ឋាភិបាល ក្នុងការចង្អុលណែនាំដំណើរការនៃការអភិវឌ្ឍជាតិ ។

ដើម្បីអនុវត្តការប្តេជ្ញាស្តីពីភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ រាជរដ្ឋាភិបាលបានអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ ដើម្បីកំណើន, ការងារ, សមធម៌ និងប្រសិទ្ធភាព ដែលបានរំលេចអំពីតម្រូវការក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃភាពជាដៃគូជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ដើម្បីកម្ពុជាសម្រេចបានវឌ្ឍនភាពបន្ថែមទៀត និងដោះស្រាយបញ្ហាប្រឈមនានា ព្រមទាំងក្តាប់ជាប់នូវកាលានុវត្តភាពថ្មីៗ ក្នុងជីវភាពតំបន់ និងសកលលោក ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៤-២០១៨ គឺជាក្របខ័ណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាល សម្រាប់អភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ។ លើសពីនេះ ដើម្បីសម្រេចចក្ខុវិស័យរបស់ខ្លួនឱ្យក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ ក្នុងឆ្នាំ ២០៣០ និងដើម្បីផ្សារភ្ជាប់សេដ្ឋកិច្ចកម្ពុជា ជាមួយសហគមន៍សេដ្ឋកិច្ចអាស៊ាន និងសេរីភាវូបនីយកម្មសេដ្ឋកិច្ចតំបន់ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ដែលជាយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មី សម្រាប់បន្តជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច, ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានរៀបចំ និងអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ ២០១៤-២០១៨ ដើម្បីបន្តលើកកម្ពស់ភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ ស្របតាមបរិការណ៍ជាក់ស្តែងរបស់កម្ពុជា ។

គោលដៅចម្បងនៃរបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនៅកម្ពុជា ឆ្នាំ ២០១៧ ដែលបានរៀបចំដោយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.នា/ក.អ.ក) គឺការឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពនៃភាពជាដៃគូ និងការវិភាគលើការវិវត្តកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា ដោយផ្អែកលើសក្ខីកម្មជាក់ស្តែង ។ របាយការណ៍នេះក៏បានរំលេចពីអាទិភាពសម្រាប់ពង្រឹងប្រសិទ្ធភាពនៃភាពជាដៃគូ ដើម្បីរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣ និងផ្តល់ធាតុចូលសំខាន់ៗសម្រាប់អភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ដែលផ្សារភ្ជាប់នឹងរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ ២០៣០ ព្រមទាំងរំលេចអំពីការវិវត្តសំខាន់ៗនៃភាពជាដៃគូកន្លងមក ក្នុងបរិការណ៍

ដែលកម្ពុជាបានសម្រេចឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប និងកំពុងបន្តកិច្ចប្រឹងប្រែងរបស់ខ្លួន ដើម្បីចាកផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច ។

ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ **ឈឿង យ៉ាណារ៉ា** អគ្គលេខាធិការ គ.ជ.នា/ក.អ.ក និងសហការី ដែលបានរៀបចំរបាយការណ៍វិភាគនេះ ។ ខ្ញុំជឿជាក់ថា របាយការណ៍នេះនឹងផ្តល់ព័ត៌មានសំខាន់ៗ សម្រាប់អ្នករៀបចំគោលនយោបាយ និងតួអង្គអភិវឌ្ឍន៍ទាំងអស់ និងជាឯកសារណែនាំ សម្រាប់បន្តពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍កម្ពុជា ។

ថ្ងៃព្រហស្បតិ៍ ២កើត ខែ មាឃ ឆ្នាំ រកា នព្វស័ក ព.ស. ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៨

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**

**អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**ជីន ប៊ុនសៀន**

# ខ្លឹមសារសង្ខេបប្រតិបត្តិ

ក្នុងឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប កម្ពុជាកំពុងបន្តរក្សា និងពង្រឹងវឌ្ឍនភាពក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចដែលសម្រេចបានកន្លងមក ។ ការបោះជំហានយ៉ាងស្វាហាប់ដើម្បីឈានទៅសម្រេចគោលដៅឆ្នាំ ២០៣០ របស់ខ្លួន ទន្ទឹមនឹងការវិវត្តយ៉ាងឆាប់រហ័សនៃបរិការណ៍អភិវឌ្ឍន៍សកល ទាមទារនូវចក្ខុវិស័យទូលំទូលាយ និងគ្រប់ជ្រុងជ្រោយក្នុងការអភិវឌ្ឍ ដែលត្រូវរំលេចក្នុងផែនការអភិវឌ្ឍន៍ជាតិ ហើយត្រូវមានសង្គតិភាពជាមួយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ។ ក្នុងបរិការណ៍ដែលកំពុងវិវត្តនេះ រាជរដ្ឋាភិបាលបានវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨ ក្នុងគោលដៅកំណត់បញ្ហាគន្លឹះមួយចំនួន ក៏ដូចជាធ្វើជាមូលដ្ឋានសម្រាប់រៀបចំផែនការក្នុងដំណាក់កាលបន្ទាប់ ។ រាជរដ្ឋាភិបាលទទួលស្គាល់ពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងភាពជាដៃគូ ពិសេសហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រដល់ការអនុវត្តរបៀបវារៈស្តីពីការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ទន្ទឹមនឹងតួនាទីជាកាតាលីករសម្រាប់កៀរគរប្រភពហិរញ្ញប្បទានដទៃទៀត ដើម្បីជំរុញកំណើនប្រកបដោយបរិយាប័ន្ន និងកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា ។

## *វឌ្ឍនភាពរបស់កម្ពុជាក្នុងការឈានឆ្ពោះទៅការចាកចេញពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច*

តាមរយៈការសម្រេចកំណើនសេដ្ឋកិច្ចខ្ពស់ និងល្បឿននៃការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាលទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ កម្ពុជាបានសម្រេចសន្ទស្សន៍ស្តីពីការអភិវឌ្ឍធនធានមនុស្សរបស់ប្រទេសអភិវឌ្ឍន៍តិចតួច និងជិតសម្រេចបានសន្ទស្សន៍ស្តីពីភាពងាយរងគ្រោះខាងសេដ្ឋកិច្ច ។ ទោះជាយ៉ាងនេះក្តី កម្ពុជានឹងបន្តខិតខំបន្ថែមទៀត ដើម្បីសម្រេចសន្ទស្សន៍ស្តីពីប្រាក់ចំណូល ១ ២៤២ ដុល្លារ ក្នុងប្រជាជនម្នាក់ដែលកំណត់ដោយធនាគារពិភពលោក ។ ផ្អែកតាមការវិភាគលើសមិទ្ធកម្មសង្គម-សេដ្ឋកិច្ចកម្ពុជា ធៀបនឹងលក្ខខណ្ឌនៃការតម្លើងចំណាត់ថ្នាក់ប្រទេស ការចាកផុតពីប្រទេសអភិវឌ្ឍន៍តិចតួចក្នុងរង្វង់ ១០ ឆ្នាំខាងមុខត្រូវផ្អែកលើលទ្ធភាពរបស់កម្ពុជាក្នុងការពង្រីកវិស័យកម្មន្តសាល និងសេវា រួមទាំងការធ្វើឧស្សាហូបនីយកម្មសម្រាប់ជំរុញពិពិធកម្មនៃការនាំចេញ, ការធ្វើទំនើបកម្មកសិកម្ម និងការគ្រប់គ្រងឱ្យបាននូវហានិភ័យដែលបង្កឡើងដោយគ្រោះមហន្តរាយនានា ។

ដើម្បីពន្លឿនកម្ពុជាឱ្យចាកផុតពីប្រទេសអភិវឌ្ឍន៍តិចតួច រាជរដ្ឋាភិបាលបានរៀបចំគោលនយោបាយប្រទាក់ក្រឡាមួយចំនួន ដែលពាក់ព័ន្ធនឹងការពង្រឹងភាពប្រកួតប្រជែងសេដ្ឋកិច្ច, ពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ សម្រាប់ធានាភាពរលូនក្នុងអន្តរកាលនៃការចាកចេញរបស់កម្ពុជាពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច ។ ទំហំហិរញ្ញប្បទានសហប្រតិបត្តិការ និងភាពជាដៃគូរវាងកម្ពុជា និងដៃគូអភិវឌ្ឍន៍ ក្នុងរយៈពេល ១០ ឆ្នាំខាងមុខ គឺជាបញ្ហាដែលពិបាកទស្សន៍ទាយជាមុន ។ ដៃគូអភិវឌ្ឍន៍មួយចំនួនអាចបញ្ចប់កិច្ចសហប្រតិបត្តិការនៅកម្ពុជា ឬទាមទារថវិកាបដិភាគច្រើនជាងមុនពីរាជរដ្ឋាភិបាល និងអាចផ្លាស់ប្តូរទម្រង់នៃការផ្តល់ហិរញ្ញប្បទានពីហិរញ្ញប្បទានឥតសំណង ទៅជាហិរញ្ញប្បទានកម្ចី ។ ទន្ទឹមនឹងនេះ លក្ខណៈសម្បទាន

ខាងពាណិជ្ជកម្មសម្រាប់ទីផ្សារក្នុងប្រទេសអភិវឌ្ឍន៍ ក៏អាចកាត់បន្ថយ ប៉ុន្តែ អាចបន្តទទួលភាពអនុគ្រោះមួយចំនួន ។ ទោះជាយ៉ាងនេះក្តី ការប្តេជ្ញារបស់កម្ពុជាក្នុងការអនុវត្តរបៀបវារៈសកលស្តីពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព នឹងផ្តល់កាលានុវត្តភាពសម្រាប់កម្ពុជាកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការ និងតម្រង់ទិសការវិភាជធនធានទាំងនេះ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ ។

## ការវិវត្តនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

ក្នុងឆ្នាំ ២០១៧ ការបើកផ្តល់ហិរញ្ញប្បទានក្រៅប្រទេសមាន ១ ៣៥០ លានដុល្លារ (៨៤% ជាធនធានរបស់ដៃគូអភិវឌ្ឍន៍ និង ១៦% ជាធនធានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាល) ។ ក្នុងឆ្នាំ ២០១៤-២០១៧ ហិរញ្ញប្បទានសហប្រតិបត្តិការបានធ្លាក់ចុះពី ១ ៤៥០ លានដុល្លារ ក្នុងឆ្នាំ ២០១៤ មកត្រឹម ១ ២៧០ លានដុល្លារ ក្នុងឆ្នាំ ២០១៦ ។ ការបើកផ្តល់ក្នុងឆ្នាំ ២០១៧ បានកើន ៩% ធៀបនឹងឆ្នាំ ២០១៦ ដោយសារការកើនឡើងនៃការបើកផ្តល់កម្ចីសម្បទាន ។ ក្នុងដំណាក់កាលនេះ ហិរញ្ញប្បទានឥតសំណងបានធ្លាក់មកត្រឹម ៨០០ លានដុល្លារ ក្នុងមួយឆ្នាំ ។ ផលធៀបរវាងការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ និងផលិតផលក្នុងស្រុកសរុបបានធ្លាក់ចុះពី ៩% ក្នុងឆ្នាំ ២០១៤ មកត្រឹម ៦% ក្នុងឆ្នាំ ២០១៧ ហើយហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ប្រជាជនម្នាក់ មានប្រមាណ ៩០ ដុល្លារ ក្នុងមួយឆ្នាំ ។

ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការក្នុងឆ្នាំ ២០១៧ បានកើនឡើង ដោយសារការកើនឡើងនៃធនធានរបស់អង្គការសហប្រជាជាតិ, ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ, ដៃគូអភិវឌ្ឍន៍អឺរ៉ុប និងជប៉ុន ។ ធនាគារអភិវឌ្ឍន៍អាស៊ី និងបារាំង ជាដៃគូអភិវឌ្ឍន៍សំខាន់ ដែលបានបើកផ្តល់ធនធាន ១៩% នៃធនធានសរុប ។ ទន្ទឹមនឹងនេះ ជប៉ុនបានបើកផ្តល់ប្រមាណ ១/១០ នៃហិរញ្ញប្បទានសរុប ។ ទោះបីទំហំហិរញ្ញប្បទានរបស់សាធារណរដ្ឋប្រជាមានិតចិនមានការធ្លាក់ចុះបន្តិចក្នុងឆ្នាំ ២០១៧ សាធារណរដ្ឋប្រជាមានិតចិននៅតែជាដៃគូសំខាន់ ដែលបានបើកផ្តល់ច្រើនជាងគេ ប្រមាណ ២២៤ លានដុល្លារ ស្មើនឹង ១៧% នៃហិរញ្ញប្បទានសរុប ។

ក្នុងឆ្នាំ ២០១៧ វិស័យសង្គមកិច្ចទទួលហិរញ្ញប្បទានច្រើនជាងវិស័យដទៃ ប្រមាណ ៣៧% នៃហិរញ្ញប្បទានសរុប ហើយបន្ទាប់មក គឺវិស័យហេដ្ឋារចនាសម្ព័ន្ធទទួលប្រមាណ ២៨% ។ រីឯវិស័យសេដ្ឋកិច្ច និងអន្តរវិស័យបានទទួល ២២% និង ១០% នៃហិរញ្ញប្បទានសរុប ។ ហិរញ្ញប្បទានភាគច្រើនត្រូវបានវិភាជដល់វិស័យសំខាន់ ៥ រួមមាន ÷ វិស័យដឹកជញ្ជូន ១៦,១%, វិស័យសុខាភិបាល ១៥,៨%, វិស័យកសិកម្ម ១៣,៥%, វិស័យអប់រំ ១១% និងវិស័យថាមពល ៦,៦% ។ ក្នុងរយៈពេល ៤ ឆ្នាំចុងក្រោយ ២០១៤-២០១៧ កិច្ចសហប្រតិបត្តិការបច្ចេកទេសមានទំហំនឹងនរ ប្រមាណ ៤០០ លានដុល្លារ ក្នុងមួយឆ្នាំ ។ រីឯធនធានសម្រាប់វិនិយោគបានធ្លាក់ចុះពី ៩៦៦ លានដុល្លារ ក្នុងឆ្នាំ ២០១៤ មកត្រឹម ៧៣០ លានដុល្លារ ក្នុងឆ្នាំ ២០១៦ ប៉ុន្តែបានកើនឡើងវិញប្រមាណ ៨២៥ លានដុល្លារ ក្នុងឆ្នាំ ២០១៧ ។

| ការវិវត្តនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ | |
|---|---|
| ការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទាន (លានដុល្លារ) | ការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ (លានដុល្លារ) |




ការវិភាជតាមវិស័យ" ឆ្នាំ " ២០១៧" (លានដុល្លារ)




| Development Partners | 2014 | 2015 | 2016 | 2017 (Est.) | 2018 (Proj.) |
|---|---|---|---|---|---|
| UN (core fund) | 53.9 | 47.2 | 63.2 | 76.3 | 57.0 |
| World Bank | 50.6 | 17.6 | 20.1 | 39.7 | 54.2 |
| ADB | 129.8 | 137.2 | 109.9 | 146.0 | 181.2 |
| GAVI Alliance | 5.5 | 19.0 | 10.2 | 10.9 | 9.2 |
| Global Fund | 54.6 | 33.3 | 28.2 | 71.7 | - |
| **Sub-Total UN & Multilaterals** | **294.4** | **254.3** | **231.5** | **344.6** | **301.6** |
| EU/EC | 70.3 | 55.8 | 56.0 | 59.8 | 26.7 |
| Czech Republic | 1.2 | 1.2 | 1.3 | 1.2 | - |
| France | 59.5 | 63.3 | 31.9 | 103.3 | 40.6 |
| Germany | 29.8 | 25.8 | 48.4 | 36.5 | 29.7 |
| Ireland | 0.7 | 0.6 | 0.6 | 1.3 | 1.3 |
| Sweden | 33.0 | 21.8 | 30.1 | 20.3 | 13.0 |
| United Kingdom | 0.1 | 0.2 | 1.6 | 2.3 | 0.3 |
| Other EU Members | 6.0 | - | - | - | - |
| **Sub-Total: EU Partners** | **200.6** | **168.7** | **169.8** | **224.6** | **111.6** |
| Australia | 64.9 | 55.9 | 51.9 | 56.3 | 41.3 |
| Canada | 5.7 | 3.8 | 3.0 | 1.6 | 0.7 |
| China | 347.8 | 339.4 | 265.3 | 223.5 | 251.4 |
| Japan | 111.4 | 110.4 | 119.7 | 126.4 | 168.0 |
| New Zealand | 6.0 | 4.9 | 4.0 | 5.3 | 5.5 |
| Republic of Korea | 80.3 | 61.7 | 31.9 | 51.2 | 24.6 |
| Switzerland | 11.8 | 13.0 | 15.8 | 13.8 | 10.0 |
| USA | 91.6 | 101.0 | 71.1 | 76.0 | 35.7 |
| **Sub-Total: Other** | **719.6** | **690.0** | **562.6** | **554.2** | **537.2** |
| **NGOs (core funds)** | 230.7 | 237.7 | 250.3 | 211.3 | 122.7 |
| **Pipeline Projects** | | | | 14.2 | 147.2 |
| **Grand total** | **1445.2** | **1350.7** | **1214.2** | **1348.9** | **1220.3** |

ប្រភព: ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ( ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៧)

ការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៤-២០១៨ សម្រេចបានលទ្ធផលគួរជាទីគាប់ចិត្ត ដោយសារភាពដឹកនាំរបស់រាជរដ្ឋាភិបាល និងការប្តេជ្ញារបស់ដៃគូអភិវឌ្ឍន៍ក្នុងការអនុវត្តគោលការណ៍ស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ។ ការបើកផ្តល់ធនធានសហប្រតិបត្តិការ ក្នុងចន្លោះឆ្នាំ ២០១៤-២០១៨ បានតម្រឹមនឹងតម្រូវការធនធានដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ យន្តការក្រុមការងារបច្ចេកទេសចម្រុះបានរួមចំណែកគាំទ្រដល់វឌ្ឍនភាពទាំងនេះ ព្រោះថា បន្ទាប់ពីការវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៤-២០១៨, ការធ្វើមូលដ្ឋានីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការរៀបចំគោលនយោបាយថ្មីៗតាមវិស័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអនុម័តសូចនាករតាមដានរួមគ្នា ឆ្នាំ ២០១៧-២០១៨ ។ ក្នុងឆ្នាំ ២០១៧ ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់បានសម្របសម្រួលគម្រោងចំនួន ២៩៦ ដែលមានធនធាន ៦៩៣ លានដុល្លារ ។ ក្រុមការងារបច្ចេកទេសចម្រុះស្តីពីហេដ្ឋារចនាសម្ព័ន្ធ និងសមាហរណកម្មក្នុងតំបន់ បានសម្របសម្រួលធនធានច្រើនជាងក្រុមការងារដទៃទៀត ។

ក្នុងឆ្នាំ ២០១៧ ធនធានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាល មានប្រមាណ ១៦% នៃហិរញ្ញប្បទានសរុប ។ ធនធានទាំងនេះត្រូវបានប្រើប្រាស់សម្រាប់គាំទ្រវិស័យសុខាភិបាល, អប់រំ, សុខុមាលភាពសង្គម

និងអភិវឌ្ឍន៍ជនបទ ។ ក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាល ៤៦០ ដែលបានផ្តល់របាយការណ៍សកម្មភាពមកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឆ្នាំ ២០១៧, អង្គការ ២៥ បានប្រើប្រាស់ធនធានប្រមាណ ៦០% នៃធនធានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាល ។

## *ស្ថានភាពកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្នុងអន្តរវិស័យ*

ក្នុងពេលដែលការកែទម្រង់នៅកម្ពុជាកំពុងបោះជំហានទៅមុខ ទន្ទឹមនឹងការអភិវឌ្ឍសេដ្ឋកិច្ចកាន់តែឿនលឿន បញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍កាន់តែមានលក្ខណៈស្មុគស្មាញ និងមានចរិតអន្តរវិស័យ ។ ការដោះស្រាយបញ្ហាប្រឈមទាំងនេះ ទាមទារឱ្យរាជរដ្ឋាភិបាលប្តេជ្ញាកៀរគរ និងសម្របសម្រួលធនធានបន្ថែមទៀតជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ។ របាយការណ៍នេះក៏បានវិភាគលើ «វិស័យសម្គាល់បន្ថែម» ក្នុងប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីឆ្លុះបញ្ចាំងអំពីគម្រោងអភិវឌ្ឍន៍ទាំងឡាយដែលមានគោលដៅគាំទ្រវិស័យច្រើន ។

### *ហិរញ្ញប្បទានគាំទ្រដល់ការពង្រឹងសមភាពយេនឌ័រ*

ក្នុងឆ្នាំ ២០១៧ ហិរញ្ញប្បទានសហប្រតិបត្តិការទំហំ ៣៧៤ លានដុល្លារ ស្មើនឹង ២៨%នៃហិរញ្ញប្បទានសរុប ត្រូវបានបើកផ្តល់សម្រាប់លើកកម្ពស់សមភាពយេនឌ័រ ហើយបានកើន ១៧% ធៀបនឹងឆ្នាំ ២០១៦ ។ វិស័យកសិកម្ម, សុខាភិបាល និងវិស័យរដ្ឋបាល និងអភិបាលកិច្ច បានទទួលហិរញ្ញប្បទានបញ្រ្ជាបយេនឌ័រច្រើនជាងគេ សរុបប្រមាណ ១៧៦ លានដុល្លារ ក្នុងនោះ វិស័យសុខាភិបាល និងវិស័យអប់រំ បានទទួលហិរញ្ញប្បទានសម្រាប់បញ្រ្ជាបយេនឌ័រក្នុងកម្រិតខ្ពស់ សរុប ២៦ លានដុល្លារ ។

### *ហិរញ្ញប្បទានគាំទ្រការប្រែប្រួលអាកាសធាតុ*

ក្នុងឆ្នាំ ២០១៧ ហិរញ្ញប្បទានទំហំ ៣០៦ លានដុល្លារ ស្មើនឹង ២៣% នៃហិរញ្ញប្បទានសរុប បានគាំទ្រការប្រែប្រួលអាកាសធាតុ ពោលគឺកើន ១២% ធៀបនឹងឆ្នាំ ២០១៦ ។ វិស័យកសិកម្ម និងវិស័យដឹកជញ្ជូន គឺជាវិស័យចម្បងដែលបានទទួលហិរញ្ញប្បទានបញ្រ្ជាបការប្រែប្រួលអាកាសធាតុ ១៧១ លានដុល្លារ ស្មើនឹង ៥៦% នៃហិរញ្ញប្បទានសរុបសម្រាប់បញ្រ្ជាបការប្រែប្រួលអាកាសធាតុ ។ វិស័យដែលបានទទួលហិរញ្ញប្បទានច្រើន សម្រាប់បញ្រ្ជាបការប្រែប្រួលអាកាសធាតុ រួមមាន វិស័យកសិកម្ម, ការអភិវឌ្ឍន៍ជនបទ និងសុខាភិបាល ក្នុងទំហំប្រមាណ ២៤,៥ លានដុល្លារ ។

### *ហិរញ្ញប្បទានគាំទ្រការអភិវឌ្ឍវិស័យឯកជន*

ក្នុងឆ្នាំ ២០១៧ គម្រោងដែលមានធនធាន ៤៦៤ លានដុល្លារ ស្មើ ៣៥% នៃធនធានសរុប បានរួមចំណែកដល់ការអភិវឌ្ឍវិស័យឯកជន ពោលគឺបានកើន ៤០% ធៀបនឹងឆ្នាំ ២០១៦ ។ វិស័យកសិកម្ម, ដឹកជញ្ជូន និងថាមពល ទទួលបានធនធានច្រើនជាងគេ ២៨០ លានដុល្លារ ស្មើនឹង ៦០% នៃធនធានសរុបសម្រាប់បញ្រ្ជាបការអភិវឌ្ឍវិស័យឯកជន ។ វិស័យកសិកម្ម, ថាមពល និងទឹកស្អាត ទទួលបានធនធានច្រើនសម្រាប់ការបញ្រ្ជាបវិស័យឯកជន សរុបប្រមាណ ២៩ លានដុល្លារ ។

## *ហិរញ្ញប្បទានគាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្ម*

បន្ទាប់ពីដាក់ឱ្យអនុវត្តជាផ្លូវការនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥ នាខែ សីហា ឆ្នាំ ២០១៥ រាជរដ្ឋាភិបាលបានសម្រេចវឌ្ឍនភាពជាច្រើន ក្នុងការអនុវត្តវិធានការគន្លឹះបួនជាក់ស្តែងនៃគោលនយោបាយនេះ ។ ក្រសួង និងស្ថាប័នពាក់ព័ន្ធបានរៀបចំគោលនយោបាយតាមវិស័យដើម្បីគាំទ្រការអនុវត្ត ដូចជាការសិក្សាសមិទ្ធិលទ្ធភាព, ការរៀបចំផែនការសកម្មភាព និងតម្រូវការធនធាន ក៏ដូចជាការបង្កើនការផ្គត់ផ្គង់អគ្គិសនីឱ្យបានពាក់កណ្តាលតំបន់ឧស្សាហកម្មគោលដៅ ។

តាមប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ដែលបានកែសម្រួលឱ្យស្របតាមអាទិភាពនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម, ធនធាន ១៤៤ លានដុល្លារ ស្មើនឹង ១៣% នៃហិរញ្ញប្បទានសរុបក្នុងឆ្នាំ ២០១៧ ត្រូវបានផ្តល់សម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ។ សម្រាប់រយៈពេល ៥ ឆ្នាំ ២០១៤-២០១៨ ហិរញ្ញប្បទានសហប្រតិបត្តិការដែលបានគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម បានកើនដល់ ៦៩៧ លានដុល្លារ គិតជាមធ្យម ១៣៩ លានដុល្លារ ក្នុងមួយឆ្នាំ ។

តាមរយៈការប្រើប្រាស់ «វិស័យសម្គាល់បន្ថែម» ក្នុងឆ្នាំ ២០១៧ គម្រោងនានាដែលមានធនធានសរុបប្រមាណ ៣៣៣ លានដុល្លារ ស្មើនឹង ២៥% នៃហិរញ្ញប្បទានសរុប បានរួមចំណែកដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ពោលគឺបានកើន ៥៩% ធៀបនឹងឆ្នាំ ២០១៦ ។ វិស័យកសិកម្ម, ដឹកជញ្ជូន និងទឹកស្អាត គឺជាវិស័យដែលទទួលធនធានច្រើនជាងគេ ប្រមាណ ២២៨លានដុល្លារ ស្មើនឹង ៦៩% នៃហិរញ្ញប្បទានសរុបសម្រាប់បញ្ជ្រាបការអភិវឌ្ឍវិស័យឧស្សាហកម្ម ។ វិស័យដែលទទួលជោគជ័យខ្ពស់ក្នុងការបញ្ជ្រាបការអភិវឌ្ឍវិស័យឧស្សាហកម្ម គឺវិស័យដឹកជញ្ជូន និងអប់រំ ដែលមានធនធានសរុបប្រមាណ ៥២,៧ លានដុល្លារ ។

របាយការណ៍នេះបានឆ្លុះបញ្ចាំងអំពីសក្តិកម្មជាក់ស្តែងនៃការបន្តកិច្ចសហការរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីសម្រេចលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ ។ របាយការណ៍នេះបានបង្ហាញអំពីកិច្ចប្រឹងប្រែង និងការប្តេជ្ញារបស់រាជរដ្ឋាភិបាល ក្នុងការកៀរគរ និងការតម្រឹមធនធានសហប្រតិបត្តិការជាមួយអាទិភាពជាតិនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៤-២០១៨ ។ លទ្ធផលវិភាគបានបង្ហាញថា ការបើកផ្តល់ធនធានសហប្រតិបត្តិការ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ បានតម្រឹមជាមួយតម្រូវការធនធាននៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ក្នុងបរិការណ៍កម្ពុជាក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប ទោះបីទម្រង់នៃការផ្តល់ធនធានរបស់ដៃគូមានការប្រែប្រួល ក៏ហិរញ្ញប្បទានឥតសំណងបន្តរក្សាទំហំនឹងនរ ទន្ទឹមនឹងការកើនឡើងនៃកម្ចីសម្បទាន ។ ស្ថានការណ៍របស់កម្ពុជានេះមានសង្គតិភាពជាមួយស្ថានការណ៍របស់ប្រទេសដទៃដែលសម្រេចបានឋានៈប្រទេសមានចំណូលមធ្យម ។

# ជំពូក ១
# សេចក្តីផ្តើម

ក្នុងបរិការណ៍នៃការអភិវឌ្ឍសកលដែលកំពុងវិវត្តយ៉ាងឆាប់រហ័ស ព្រះរាជាណាចក្រកម្ពុជាបានសម្រេចវឌ្ឍនភាពយ៉ាងធំធេង ក្នុងការអនុវត្តរបៀបវារៈអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ។ របៀបវារៈសកលស្តីពីកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ ២០៣០ បានរំលេចអំពីក្របខ័ណ្ឌអភិវឌ្ឍន៍ប្រកបដោយមហិច្ឆតា និងបានគូសបញ្ជាក់ជាថ្មីម្តងទៀតអំពីការប្តេជ្ញាសកល ក្នុងការលើកកម្ពស់ភាពដឹកនាំ និងភាពជាដៃគូប្រកបដោយបរិយាប័ន្ន ដើម្បីសម្រេចបានកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព ។ វេទិកាគោលនយោបាយសកលកម្រិតខ្ពស់លើកទី ១ ស្តីពីកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលរៀបចំឡើងនាខែ សីហា ឆ្នាំ ២០១៧ បានអំពាវនាវតួអង្គអភិវឌ្ឍន៍ទាំងអស់រួមដៃគ្នា ដើម្បីចូលរួម និងអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្នុងគោលដៅសម្រេចវឌ្ឍនភាពក្នុងទិដ្ឋភាពទាំង ៣ នៃកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព គឺ ÷ ទិដ្ឋភាពសង្គម, សេដ្ឋកិច្ច និងបរិស្ថាន ។

ក្នុងឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប កម្ពុជាបានខិតខំរក្សា និងពង្រឹងវឌ្ឍនភាពក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ ការសម្រេចចក្ខុវិស័យរបស់កម្ពុជា ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ ២០៣០ និងការអនុវត្តរបៀបវារៈស្តីពីកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ ២០៣០ តម្រូវឱ្យរាជរដ្ឋាភិបាលរៀបចំចក្ខុវិស័យទូលំទូលាយ, គ្រប់ជ្រុងជ្រោយជាងមុន និងប្រកបដោយមហិច្ឆតាខ្ពស់ជាងមុន ។ លើមូលដ្ឋាននេះ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ ក៏ដូចជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព រាជរដ្ឋាភិបាលនឹងបន្តកៀរគរធនធានថែមទៀត និងរៀបចំប្រព័ន្ធគ្រប់គ្រងធនធានគ្រប់ជ្រុងជ្រោយ សម្រាប់គ្រប់គ្រងហិរញ្ញប្បទានពីវិស័យសាធារណៈ និងវិស័យឯកជន ។

យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៤-២០១៨ គឺជាក្របខ័ណ្ឌមគ្គុទ្ទេសក៍គោលនយោបាយរបស់រាជរដ្ឋាភិបាល សម្រាប់អនុវត្តប្រកបដោយប្រសិទ្ធភាព នូវបណ្តាអាទិភាពជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ដើម្បីសម្រេចរបៀបវារៈនៃការអភិវឌ្ឍជាតិ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ។ ដើម្បីគាំទ្រអាទិភាពទាំងនេះ រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងកម្មវិធីកែទម្រង់ស្នូលជាច្រើន និងកែសម្រួលយន្តការស្ថាប័ន ។ ជាក់ស្តែង ការដាក់ឱ្យអនុវត្តនូវ«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥» ដែលជាយុទ្ធសាស្ត្រជំរុញកំណើនសេដ្ឋកិច្ចថ្មី ដើម្បីឆ្លើយតបនឹងការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងស្រុក និងការប្រែប្រួលនៃនិម្មាបនកម្មសេដ្ឋកិច្ចតំបន់ និងសកលលោក ។ គោលនយោបាយនេះនឹងរួមចំណែករក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច, ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព ។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨ ដើម្បីកំណត់ការងារអាទិភាពគន្លឹះ សម្រាប់ណែនាំដល់ការរៀបចំផែនការជាតិ ក្នុងដំណាក់កាលបន្ទាប់ ។ ការវាយតម្លៃពាក់កណ្តាលអាណត្តិបានកំណត់អាទិភាពសំខាន់ៗ ដែលរាជរដ្ឋាភិបាលបន្តយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ÷ ការកាត់បន្ថយភាពក្រីក្រ និងកំណើនប្រកបដោយបរិយាប័ន្ន, ការលើកកម្ពស់វិស័យកសិកម្ម, ការប្រកួតប្រជែង, ចំណាកស្រុក និងកំណើនប្រជាជននៅទីក្រុង, ការប្រែប្រួលអាកាសធាតុ និងការកាប់ព្រៃឈើ, អភិបាលកិច្ច និងការអភិវឌ្ឍធនធានមនុស្ស ។ ទាំងនេះគឺជាមូលដ្ឋាន សម្រាប់ដោះស្រាយបញ្ហាប្រឈមនានា ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ និងចូលរួមលើកកម្ពស់លទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ ។

រាជរដ្ឋាភិបាលបានអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូឆ្នាំ ២០១៤-២០១៨ ប្រកបដោយប្រសិទ្ធភាព និងមានសង្គតិភាពជាមួយបរិការណ៍អភិវឌ្ឍន៍កម្ពុជា ដែលជាប្រទេសមានចំណូលមធ្យមកម្រិតទាប ក៏ដូចជាផ្តល់ក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយ ដើម្បីលើកកម្ពស់ភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍ជាតិ ។ ទន្ទឹមនឹងនេះ យុទ្ធសាស្ត្រនេះបានរំលេចអំពីការប្តេជ្ញារបស់រាជរដ្ឋាភិបាល សម្រាប់អនុវត្តការប្តេជ្ញាសកល ដូចជាសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស, ផែនការសកម្មភាពទីក្រុងអាក្រា និងភាពជាដៃគូសកលទីក្រុងប៊ូសាន ដែលបានផ្តោតសំខាន់លើការរៀបចំស្ថាប័នប្រកបដោយប្រសិទ្ធភាព, ភាពជាដៃគូប្រកបដោយបរិយាប័ន្ន និងលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ ។ ជាមួយគ្នានេះ, ភាពជាដៃគូនៅកម្រិតវិស័យក៏មានវឌ្ឍនភាពល្អប្រសើរ ដោយរាជរដ្ឋាភិបាលបានរៀបចំសេចក្តីណែនាំស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារបច្ចេកទេសចម្រុះ ឆ្នាំ ២០១៥ និងសូចនាករតាមដានរួមគ្នា ឆ្នាំ ២០១៤-២០១៨ សម្រាប់ជាក្របខ័ណ្ឌពង្រឹងសង្គតិភាពរវាងផែនការអភិវឌ្ឍន៍ជាតិ និងអាទិភាពតាមវិស័យ ក៏ដូចជាមូលដ្ឋានសម្រាប់ពង្រឹងគុណផលការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះ និងគណនេយ្យភាពទ្វេទិសដោយផ្តោតលើលទ្ធផល ។

រាជរដ្ឋាភិបាលបានទទួលស្គាល់ថា ការអនុវត្តដោយជោគជ័យនូវគោលនយោបាយអាទិភាពទាំងនេះទាមទារឱ្យមានការប្តេជ្ញាចូលរួមកែទម្រង់ពីគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ ។ លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្ត នូវកម្មវិធីកែទម្រង់សាធារណៈ រួមមាន ÷ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការកែទម្រង់រដ្ឋបាលសាធារណៈ និងការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ដែលសុទ្ធសឹងជាអាទិភាពស្នូលនៃយុទ្ធសាស្ត្រចតុកោណ តាមរយៈការពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីរក្សាកំណើនប្រកបដោយចីរភាព និងបរិយាប័ន្ន និងដើម្បីលើកកម្ពស់គុណភាពសេវាសាធារណៈ ។ ជាក់ស្តែង កម្មវិធីជាតិស្តីពីការកែទម្រង់រដ្ឋបាលសាធារណៈ ដែលត្រូវបានអនុម័តនាខែ មករា ឆ្នាំ ២០១៥ បានបំពេញបន្ថែម និងជួយលើកកម្ពស់ប្រសិទ្ធភាពនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការកែទម្រង់នៅថ្នាក់ក្រោមជាតិ តាមរយៈការពង្រឹងគុណផលការងារតាមស្ថាប័ន និងពង្រឹងគុណភាពសេវាសាធារណៈ ។ ក្នុងការបោះជំហានទៅមុខ រាជរដ្ឋាភិបាលនឹងបន្តខិតខំបន្ថែមទៀត ដើម្បីដោះស្រាយរាល់បញ្ហាប្រឈមនានា ដោយផ្អែកលើចក្ខុវិស័យ

ច្បាស់លាស់ និងនីតិរដ្ឋ និងទាញយកគុណប្រយោជន៍រយៈពេលវែងពីការកែទម្រង់ទាំងនេះ ស្របតាមចក្ខុវិស័យច្បាស់លាស់សម្រាប់ការអភិវឌ្ឍប្រទេស ។

ដោយមានការប្តេជ្ញាដូចបានបញ្ជាក់ខាងដើម និងការចូលរួមពីបណ្តាតួអង្គអភិវឌ្ឍន៍ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលគួរជាទីមោទនៈក្នុងកិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ។ ជាក់ស្តែង កម្ពុជាសម្រេចកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់ ៧,៧% ក្នុងមួយឆ្នាំ និងបានកាត់បន្ថយភាពក្រីក្រឱ្យធ្លាក់ចុះពី ៥៣,២% ក្នុងឆ្នាំ ២០០៤ មកត្រឹម ១៣,៥% ក្នុងឆ្នាំ ២០១៤ និងចំណូលជាតិសរុបសម្រាប់ប្រជាជនម្នាក់ បានកើនពី ៥៩០ ដុល្លារ ក្នុងឆ្នាំ ២០០៧ ដល់ ១ ៣០០ ដុល្លារ ក្នុងឆ្នាំ ២០១៦ ហើយរំពឹងថាអាចកើនដល់ ១ ៤២៩ ដុល្លារ ក្នុងឆ្នាំ ២០១៧ ។ គុណផលសេដ្ឋកិច្ចទាំងនេះបានជំរុញកំណើននៃការប្រើប្រាស់របស់ប្រជាជន, ទាក់ទាញការវិនិយោគឯកជន, បង្កើតកាលានុវត្តភាពការងារ និងកែលម្អជីវភាពរស់នៅទូទៅរបស់ប្រជាជនកម្ពុជា ។

កម្ពុជាទទួលបានចំណាត់ថ្នាក់ទី ៥ ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដែលសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ រួមមាន ÷ គោលដៅទី ១ ស្តីពីការកាត់បន្ថយអត្រាភាពក្រីក្រត្រឹមពាក់កណ្តាល, គោលដៅទី ២ ស្តីពីការចុះឈ្មោះចូលរៀននៅបឋមសិក្សា, គោលដៅទី ៤ ស្តីពីការកាត់បន្ថយអត្រាមរណភាពទារក និងកុមារ, គោលដៅទី ៥ ស្តីពីការកាត់បន្ថយអត្រាមរណភាពមាតា និងគោលដៅទី ៦ ស្តីពីការប្រយុទ្ធប្រឆាំងជម្ងឺអេដស៍ ។ រីឯគោលដៅទី ៩ ស្តីពីការដោះមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ក៏សម្រេចបានសមិទ្ធផលគួរជាទីមោទនៈផងដែរ ។ តាមការគិតគូររបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ សន្ទស្សន៍ស្តីពីការអភិវឌ្ឍធនធាននៅកម្ពុជាសម្រេចបានកំណើន ១,៨% ក្នុងមួយឆ្នាំ ។ ទាំងនេះធ្វើឱ្យកម្ពុជាត្រូវបានចាត់ទុកជាប្រទេសដែលបានសម្រេចកិច្ចអភិវឌ្ឍន៍ល្អបំផុតក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ហើយបានក្លាយជាប្រទេសមួយក្នុងបណ្តាប្រទេសដែលមានសន្ទុះអភិវឌ្ឍន៍លឿនជាងគេលើសកលលោក ។

ទន្ទឹមនឹងការសម្រេចសមិទ្ធផលដ៏ច្រើនលើសលប់ កម្ពុជានៅជួបប្រទះបញ្ហាប្រឈមមួយចំនួន ហើយនឹងបន្តឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួចក្នុងប្រមាណ ១ ទសវត្សរ៍ខាងមុខ ។ ប្រការនេះទាមទារឱ្យរាជរដ្ឋាភិបាលបន្តកិច្ចប្រឹងប្រែងបន្ថែម ដើម្បីកាត់បន្ថយភាពងាយរងគ្រោះខាងសេដ្ឋកិច្ច និងបន្តកែលម្អការកែទម្រង់ស្ថាប័ន និងការផ្តល់សេវាសាធារណៈ សម្រាប់គាំទ្រការអភិវឌ្ឍ ។ ការចាកផុតពីប្រទេសមានការអភិវឌ្ឍតិចតួច នឹងជះឥទ្ធិពលដល់ការទទួលភាពអនុគ្រោះខាងពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលទាមទារឱ្យរាជរដ្ឋាភិបាលរៀបចំយុទ្ធសាស្ត្រអន្តរកាលមួយ ដែលផ្អែកលើកត្តានៃបម្រែបម្រួលសេដ្ឋកិច្ចកម្ពុជា និងគំរូកំណើនសេដ្ឋកិច្ចថ្មី ។ ដើម្បីឆ្លើយតបនឹងបញ្ហានេះ រាជរដ្ឋាភិបាលបានទទួលស្គាល់ថាហិរញ្ញប្បទានសហប្រតិបត្តិការនៅរក្សាតួនាទីសំខាន់ សម្រាប់អនុវត្តរបៀបវារៈអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចកម្ពុជា និងជាកាតាលីករសម្រាប់កៀរគរប្រភពធនធានដទៃទៀត ទាំងពីវិស័យសាធារណៈ និងវិស័យឯកជន ដើម្បីបន្តជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន និងការអភិវឌ្ឍប្រកបដោយចីរភាព ។

របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនៅកម្ពុជា ឆ្នាំ ២០១៧ នេះ ត្រូវបានរៀបចំ ដើម្បីឆ្លុះបញ្ចាំងពីការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ ដែលផ្សារភ្ជាប់នឹងបរិការណ៍ថ្មីនៃកិច្ចអភិវឌ្ឍន៍កម្ពុជា ។ របាយការណ៍នេះបានប្រើប្រាស់ទិន្នន័យក្នុងប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ ត្រឹមថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៧ សម្រាប់ជាមូលដ្ឋានក្នុងការវិភាគអំពីនិន្នាការនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា ។ លទ្ធផលដែលទទួលបានពីការវិភាគ នឹងត្រូវប្រើប្រាស់សម្រាប់រួមចំណែកកែលម្អគោលនយោបាយស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងផ្តល់ប្រយោជន៍ដល់អ្នករៀបចំគោលនយោបាយ អំពីលំហូរហិរញ្ញប្បទានសហប្រតិបត្តិការ និងការតម្រឹមជាមួយអាទិភាព ក្នុងកិច្ចអភិវឌ្ឍន៍ជាតិ ។ របាយការណ៍នេះនឹងត្រូវប្រើប្រាស់សម្រាប់ជាធាតុចូលផ្អែកលើសក្ខីកម្ម សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងអស់ និងដើម្បីលើកកម្ពស់តម្លាភាពក្នុងការប្រើប្រាស់ធនធានទាំងនេះ ។

# ជំពូក ២

## កម្ពុជាក្នុងឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួច

កម្ពុជាបានឆ្លងផុតពីឋានៈប្រទេសមានចំណូលទាបមកជាប្រទេសមានចំណូលមធ្យមកម្រិតទាប នាខែកក្កដា ឆ្នាំ ២០១៦ ដោយសារចំណូលជាតិសរុបរបស់ប្រជាជនម្នាក់បានកើនលើសពី ១ ០២៥ ដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៥ ។ ជាមួយនឹងវឌ្ឍនភាពល្អប្រសើរនៃសូចនាករខាងការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច កម្ពុជាកំពុងត្រៀមខ្លួន ដើម្បីចាកផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច ។

ចំណាត់ថ្នាក់របស់ធនាគារពិភពលោកសម្រាប់ប្រទេសនីមួយៗ បានផ្អែកលើចំណូលជាតិសរុបរបស់ប្រជាជនម្នាក់តែប៉ុណ្ណោះ ។ ផ្ទុយទៅវិញ ចំណាត់ថ្នាក់របស់អង្គការសហប្រជាជាតិសម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួច ដែលកំណត់ដោយគណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍នៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិ បានផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យ ៣ គឺ ÷ ១- ចំណូលជាតិសរុបសម្រាប់ប្រជាជនម្នាក់, ២- ធនធានមនុស្ស និង ៣- ភាពងាយរងគ្រោះខាងសេដ្ឋកិច្ច ។ ដើម្បីឆ្លងផុតពីប្រទេសមានការអភិវឌ្ឍតិចតួច ប្រទេសនីមួយៗត្រូវសម្រេចលក្ខខណ្ឌវិនិច្ឆ័យ ២ ក្នុងចំណោមលក្ខខណ្ឌវិនិច្ឆ័យទាំង ៣ ខាងលើ ឬសម្រេចឱ្យបានទ្វេដងនូវលក្ខខណ្ឌវិនិច្ឆ័យស្តីពីចំណូល ។ ទោះជាយ៉ាងនេះក្តី ការសម្រេចតម្លើងឋានៈត្រូវឆ្លងកាត់ការត្រួតពិនិត្យ និងការពិភាក្សាយ៉ាងល្អិតល្អន់ ដែលត្រូវគិតគូរទៅដល់ភាពងាយរងគ្រោះ និងភាពប្រឈមនឹងវិបត្តិរបស់ប្រទេសនីមួយៗ ។

**គំនូរទី ២.១ : លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ឆ្លងផុតពីប្រទេសមានការអភិវឌ្ឍតិចតួច**

| ចំណូលសម្រាប់ប្រជាជនម្នាក់ | ធនធានមនុស្ស | ភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច |
|---|---|---|
| | - អត្រាប្រជាជនគ្មានអាហារគ្រប់គ្រាន់<br>- អត្រាមរណភាពកុមារក្រោមអាយុ ៥ ឆ្នាំ<br>- អត្រាមរណភាពមាតា<br>- អត្រាចុះឈ្មោះសិក្សានៅកម្រិតមធ្យមសិក្សា<br>- អត្រាអនក្ខរកម្មរបស់ប្រជាជនពេញវ័យ | **សន្ទស្សន៍ភាពងាយរងគ្រោះរបស់ប្រជាជន**<br>- ចំនួនប្រជាជន<br>- តំបន់ដាច់ស្រយាល<br>- ការប្រមូលផ្តុំនៃការនាំចេញទំនិញ<br>- កសិកម្ម/ព្រៃឈើ/ជលផលជាភាគរយនៃផលិតផលក្នុងស្រុកសរុប<br>- ភាគរយនៃប្រជាជនក្នុងតំបន់ទំនាបនៃឆ្នេរសមុទ្រសន្ទស្សន៍ផលប៉ះពាល់<br>- ជនរងគ្រោះដោយគ្រោះធម្មជាតិ<br>- អស្ថិរភាពនៃទិន្នផលកសិកម្ម<br>- អស្ថិរភាពនៃការនាំចេញទំនិញ និងសេវាកម្ម |

ការចាត់ថ្នាក់តាមកម្រិតចំណូល គឺគ្រាន់តែជាឧបករណ៍របស់ធនាគារពិភពលោក សម្រាប់កំណត់ទំហំផ្តល់ហិរញ្ញប្បទានរបស់ធនាគារនេះប៉ុណ្ណោះ ប៉ុន្តែមិនសំដៅដល់ការវាស់វែងស្ថានការណ៍សំខាន់ដទៃទៀតរបស់ប្រទេស ដូចជា ភាពម្ចាស់ការក្នុងការគ្រប់គ្រងបំណុល, លទ្ធភាពក្នុងការទទួលបានទីផ្សារសម្រាប់នាំចេញ, ភាពទាក់ទាញផ្នែកវិនិយោគ ឬ លទ្ធភាពក្នុងការទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការនោះឡើយ ។ យ៉ាងណាមិញ អ្នកវិនិយោគ និងដៃគូអភិវឌ្ឍន៍បានយកចិត្តទុកដាក់ និងកត់សម្គាល់លើការចាត់ថ្នាក់នេះ ដើម្បីធ្វើការសម្រេចចិត្តខាងហិរញ្ញប្បទាន ។

ក្នុងក្របខ័ណ្ឌនៃហិរញ្ញប្បទានសហប្រតិបត្តិការ ដៃគូអភិវឌ្ឍន៍អាចពិនិត្យលើកម្មវិធីរបស់ខ្លួនឡើងវិញ បន្ទាប់ពីប្រទេសមួយបានឆ្លងផុតពីឋានៈប្រទេសមានចំណូលទាប ដោយពួកគេអាចពិនិត្យផ្លាស់ប្តូរលក្ខខណ្ឌក្នុងការផ្តល់ហិរញ្ញប្បទាន ពីហិរញ្ញប្បទានឥតសំណងទៅជាកម្ចីសម្បទាន ឬតម្រូវឱ្យបង្កើនថវិកាបដិភាគរបស់រាជរដ្ឋាភិបាល ។ ជាក់ស្តែង ប្រភេទកម្ចីសម្បទានរបស់ធនាគារពិភពលោក នឹងត្រូវចាប់ផ្តើមផ្លាស់ប្តូរ និងជំនួសដោយក្របខ័ណ្ឌហិរញ្ញប្បទាន Blend របស់ធនាគារអន្តរជាតិសម្រាប់ការស្តារ និងអភិវឌ្ឍន៍ (IBRD blended) ទោះបីកម្ចីសម្បទានក្នុងក្របខ័ណ្ឌសមាគមអភិវឌ្ឍន៍អន្តរជាតិ (IDA) នឹងនៅតែបន្តក៏ដោយ ។ ការសិក្សាស្រាវជ្រាវមួយចំនួនបានបង្ហាញថា «បន្ទាប់ពីប្រទេសមួយក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប ការទទួលហិរញ្ញប្បទានក្នុងក្របខ័ណ្ឌ IDA និងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍អាចនឹងធ្លាក់ចុះក្នុងទំហំមធ្យម ប្រមាណ ៥៩% ធៀបនឹងចំណូលជាតិសរុប» ។ ទន្ទឹមនឹងនេះ សន្និសិទស្តីពីហិរញ្ញប្បទានសម្រាប់កិច្ចអភិវឌ្ឍន៍ កាលពីខែ កក្កដា ឆ្នាំ ២០១៥ ក៏បានកត់សម្គាល់អំពីកង្វល់របស់ប្រទេសនានា ដែលលទ្ធភាពទទួលឥណទានសម្បទានមានការធ្លាក់ចុះ ក្នុងពេលដែលចំណូលជាតិបានកើនឡើង ហើយប្រទេសទាំងនោះមិនអាចកៀរគរហិរញ្ញប្បទានគ្រប់គ្រាន់ពីប្រភពដទៃទៀត សម្រាប់បំពេញតម្រូវការអភិវឌ្ឍន៍ ។

## *អត្ថប្រយោជន៍សម្រាប់កម្ពុជា និងប្រទេសមានការអភិវឌ្ឍតិចតួចដទៃទៀត*

ប្រទេសមានការអភិវឌ្ឍតិចតួចទទួលការគាំទ្រជាច្រើន ក្នុងនោះ ការគាំទ្រផ្នែកពាណិជ្ជកម្ម គឺជាអត្ថប្រយោជន៍ដ៏សំខាន់ ។ ក្នុងឆ្នាំ ២០១៥ ការនាំចេញរបស់កម្ពុជាមាន ២/៣ នៃផលិតផលក្នុងស្រុកសរុប ក្នុងនោះ សហភាពអឺរ៉ុប, អាមេរិក និងជប៉ុន គឺជាដៃគូពាណិជ្ជកម្មសំខាន់ ។ ការនាំចេញទៅកាន់សហភាពអឺរ៉ុបមាន ៤,១ ពាន់លានដុល្លារ ស្មើនឹង ៣៥% នៃការនាំចេញសរុប ខណៈដែលការនាំចេញទៅសហរដ្ឋអាមេរិក និងជប៉ុន មានប្រមាណ ៣០% ។ លើមូលដ្ឋាននេះ ការនាំចេញប្រមាណ ២/៣ នៃការនាំចេញសរុប បានបម្រើទីផ្សារធំៗ ៣ របស់កម្ពុជា ។

សហភាពអឺរ៉ុបបានរួមចំណែកយ៉ាងសំខាន់ ក្នុងការគាំទ្រវិស័យពាណិជ្ជកម្មសម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួច ។ ប្រព័ន្ធអនុគ្រោះ «ទំនិញគ្រប់ប្រភេទ លើកលែងតែអាវុធ (EBA)» របស់សហភាពអឺរ៉ុបបានផ្តល់ការអនុគ្រោះពន្ធ និងការកំណត់កូតាសម្រាប់រាល់ការនាំចូលផលិតផលពីប្រទេសមានការអភិវឌ្ឍតិចតួច ដោយលើកលែងតែគ្រឿងសព្វាវុធ ។ បន្ទាប់ពីកម្ពុជាឆ្លងផុតពីប្រទេសមានការអភិវឌ្ឍតិចតួច ប្រព័ន្ធ

អនុគ្រោះនេះនឹងត្រូវផ្ទេរទៅជាប្រព័ន្ធមួយទៀត ដែលមានលក្ខណៈសម្បទានខ្ពស់ប្រហាក់ប្រហែលនឹងប្រព័ន្ធអនុគ្រោះទូទៅ (GSPs) ហើយដែលកំពុងអនុវត្តនៅបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ ។ ប្រព័ន្ធ GSP+ ផ្ដល់ភាពអនុគ្រោះស្រដៀងនឹងប្រព័ន្ធអនុគ្រោះ EBA ដែរ ប៉ុន្តែតម្រូវឱ្យប្រទេសដែលទទួលផលពីប្រព័ន្ធនេះ ចុះហត្ថលេខាលើការប្ដេជ្ញាលើកកម្ពស់សិទ្ធិមនុស្ស និងបទដ្ឋានការងារ ។ ទន្ទឹមនឹងនេះ ការចាកផុតពីប្រទេសមានការអភិវឌ្ឍតិចតួច ក៏ផ្ដល់លទ្ធភាពឱ្យកម្ពុជាចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី ដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀងស្ដីពីភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការ ។

| ការនាំចេញរបស់កម្ពុជា (ពាន់លានដុល្លារ) | ភាគរយនៃការនាំចេញក្នុងឆ្នាំ ២០១៥ | អនុបាតការនាំចេញធៀបនឹងផលិតផលក្នុងស្រុកសរុប |
|---|---|---|
| ការនាំចេញកើនឡើង ៨ ដង ពីឆ្នាំ ២០០០-២០១៥ ដល់ ១២ ពាន់លានដុល្លារ | ផលិតផលប្រមាណ ៦០% ត្រូវបាននាំចេញទៅកាន់ទីផ្សារសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក | ការនាំចេញផលិតផលបានកើនឡើងពី៣៧% ក្នុងឆ្នាំ ២០០០ ដល់ ៦៦% ក្នុងឆ្នាំ ២០១៥ |










សហភាពអឺរ៉ុប | សហរដ្ឋអាមេរិក | ជប៉ុន | ចិន
កាណាដា | វៀតណាម | ថៃឡង់ដ៍ | ផ្សេងៗ

ប្រភព : IMF Direction of Trade statistics

សហរដ្ឋអាមេរិកគឺជាទីផ្សារនាំចេញសំខាន់ទីពីររបស់កម្ពុជា ។ វិធានការសម្រាប់ជំរុញកិច្ចសម្រួលពាណិជ្ជកម្ម ត្រូវអនុវត្តតាមរយៈកិច្ចព្រមព្រៀងស្ដីពីការជំរុញពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក ដែលសហរដ្ឋអាមេរិកបានចូលរួមអនុម័ត ហើយកម្ពុជាអាចទទួលប្រយោជន៍ក្នុងនាមជាប្រទេសហត្ថលេខី ។ ពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិក ប្រព្រឹត្តទៅក្នុងក្របខ័ណ្ឌប្រព័ន្ធអនុគ្រោះទូទៅ (GSP) ដែលផ្ដល់ភាពអនុគ្រោះពន្ធ និងការកំណត់ចំនួនកូតាស្មើៗគ្នាលើមុខទំនិញជាក់លាក់ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍នាំចូលផលិតផលមកកាន់ទីផ្សារសហរដ្ឋអាមេរិក ។ ចាប់ពីឆ្នាំ ១៩៩៤ សហរដ្ឋអាមេរិកបានបញ្ចូលបទប្បញ្ញត្តិស្ដីពីបទដ្ឋានការងារក្នុងគ្រប់កិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីរបស់ខ្លួន ។ ក្នុងកិច្ចព្រមព្រៀងទ្វេភាគីស្ដីពីវិស័យវាយនភណ្ឌជាមួយកម្ពុជា សហរដ្ឋអាមេរិកបានភ្ជាប់ការលើកកម្ពស់បទដ្ឋានការងារជាមួយការបង្កើនចំនួនកូតាសម្បទានពាណិជ្ជកម្ម (ពិសេសការបង្កើតក្រុមប្រឹក្សាមជ្ឈត្តវិនិច្ឆ័យ និងការអនុវត្តគម្រោង «រោងចក្រល្អ» របស់អង្គការពលកម្មអន្តរជាតិ ។ លើសពីនេះ ក្នុងឆ្នាំ ២០០៦ កម្ពុជា និងសហរដ្ឋអាមេរិកបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្ដីពីក្របខ័ណ្ឌវិនិយោគ និងពាណិជ្ជកម្មទ្វេភាគី ។ ក្នុងឆ្នាំ ២០១២ កម្ពុជា និងសហរដ្ឋអាមេរិក បានឯកភាពចាប់ផ្ដើមពិភាក្សាលើសន្ធិសញ្ញាស្ដីពីការវិនិយោគទ្វេភាគី ។

លើសពីនេះ ប្រទេសមានការអភិវឌ្ឍតិចតួចអាចទទួលការគាំទ្រជាច្រើនពីវិធានការពិសេសអន្តរជាតិពិសេសក្នុងផ្នែកពាណិជ្ជកម្ម, ហិរញ្ញប្បទានសហប្រតិបត្តិការ និងកិច្ចសហប្រតិបត្តិការបច្ចេកទេស ។ ភាពអនុគ្រោះក្នុងផ្នែកពាណិជ្ជកម្មក្នុងក្របខ័ណ្ឌអន្តរជាតិនេះ ត្រូវបានផ្តល់តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា (TRIPS) និងកិច្ចព្រមព្រៀងស្តីពីវិធានការសម្រាប់ការវិនិយោគដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម (TRIMs) ។ លើសពីនេះ ប្រទេសមានការអភិវឌ្ឍតិចតួចអាចទទួលការគាំទ្រ តាមរយៈផែនការសកម្មភាពសម្រាប់ប្រទេសទាំងនេះ (LDC Programme of Action) ដែលអនុម័តក្នុងឆ្នាំ ២០១១ ហើយបច្ចុប្បន្ន បាននិងកំពុងអនុវត្តដំណាក់កាលទី ៤ ដែលផ្តោតសំខាន់លើសមត្ថភាពផលិតកម្ម និងការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច ដូចជាការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ការអភិវឌ្ឍធនធានមនុស្ស និងមូលធនសង្គម ។ ផែនការសកម្មភាពនេះបានកំណត់អាទិភាព ៨ គឺ ÷ សមត្ថភាពផលិតកម្ម, កសិកម្ម, ពាណិជ្ជកម្ម, ទំនិញ, ការអភិវឌ្ឍធនធានមនុស្ស និងសង្គម, ការដោះស្រាយវិបត្តិ និងបញ្ហាប្រឈមថ្មីៗ និងការកៀរគរហិរញ្ញប្បទាន និងអភិបាលកិច្ច ។

ឧទាហរណ៍ស្តីពីការគាំទ្រដែលប្រទេសមានការអភិវឌ្ឍតិចតួចអាចទទួលបាន គឺ ÷

- ផ្នែកពាណិជ្ជកម្មៈ ការអនុគ្រោះក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និងកិច្ចសហប្រតិបត្តិការបច្ចេកទេសសម្រាប់ជំរុញពាណិជ្ជកម្ម ។
- កិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្មៈ ជួយដល់ប្រទេសមានការអភិវឌ្ឍតិចតួច ក្នុងការទទួលអត្ថប្រយោជន៍ ដូចជា ការអនុគ្រោះពន្ធ, ការមិនកំណត់ចំនួនកូតានាំចូល និងកិច្ចសម្រួលពាក់ព័ន្ធនឹងពន្ធគយ ក៏ដូចជាធានាឱ្យបាននូវអនុលោមភាពសម្រាប់នាំចេញ ។
- ការអនុគ្រោះពិសេសតាមរយៈកិច្ចព្រមព្រៀង TRIPS និង TRIMSៈ ពាក់ព័ន្ធនឹងច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា និងច្បាប់ស្តីពីការវិនិយោគ ។
- ផ្នែកហិរញ្ញប្បទានសហប្រតិបត្តិការ : ការប្តេជ្ញារបស់ដៃគូអភិវឌ្ឍន៍ក្នុងការវិភាជ ០,១៥%-០,២០% នៃចំណូលជាតិរបស់ខ្លួន សម្រាប់ផ្តល់ហិរញ្ញប្បទានដល់ប្រទេសមានការអភិវឌ្ឍតិចតួច ។
- ការគាំទ្រផ្នែកបច្ចេកទេស និងការគាំទ្រទូទៅ រួមមាន ÷ ធនាគារបច្ចេកវិទ្យានៃអង្គការសហប្រជាជាតិសម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួច (UN's Technology Bank for LDCs), ការផ្តល់ប្រឹក្សាផ្នែកច្បាប់របស់អង្គការពាណិជ្ជកម្មពិភពលោក និងអាហារូបករណ៍ផ្សេងៗ ។

ការបន្តឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួច ទន្ទឹមនឹងការប្តេជ្ញារបស់កម្ពុជាក្នុងការបន្តពង្រឹងអភិក្រមដោយផ្តោតលើភាពជាដៃគូសម្រាប់អនុវត្តគោលដៅអភិវឌ្ឍន៍ជាតិ ដូចជាគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គឺជាកត្តាសំខាន់សម្រាប់ជំរុញកិច្ចសហការរបស់ដៃគូអភិវឌ្ឍន៍ក្នុងកិច្ចអភិវឌ្ឍន៍ប្រទេស ។

### *វឌ្ឍនភាពរបស់កម្ពុជាក្នុងការឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច*

តាមរយៈការសម្រេចកំណើនសេដ្ឋកិច្ចខ្ពស់ និងការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាលទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ កម្ពុជាបានសម្រេចសន្ទស្សន៍ស្តីពីការអភិវឌ្ឍធនធានមនុស្សសម្រាប់ឆ្លងផុតពីឋានៈប្រទេសអភិវឌ្ឍតិចតួច ហើយជិតបានសម្រេចលក្ខខណ្ឌស្តីពីភាពងាយរងគ្រោះខាងសេដ្ឋកិច្ច ។ ទោះជាយ៉ាងនេះក្តី កម្ពុជានឹងបន្តខិតខំបន្ថែមទៀត ដើម្បីសម្រេចលក្ខខណ្ឌស្តីពីប្រាក់ចំណូល ១ ២៤២ ដុល្លារ ដែលកំណត់ដោយធនាគារពិភពលោក ។

**១. វឌ្ឍនភាពក្នុងការសម្រេចលក្ខខណ្ឌទាំង ៣ គិតជាសន្ទស្សន៍ (ឆ្នាំ ២000 = ១00)**




**២. លក្ខខណ្ឌស្តីពីប្រាក់ចំណូលដែលមិនទាន់សម្រេចបាន**




**៣. កម្ពុជាបានសម្រេចលើសសន្ទស្សន៍ស្តីពីធនធានមនុស្ស**




**៤. កម្ពុជាជិតសម្រេចបានសន្ទស្សន៍ស្តីពីភាពងាយរងគ្រោះខាងសេដ្ឋកិច្ច**




ប្រភព: លេខាធិការដ្ឋាននៃគណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ តាមរយៈទិន្នន័យឆ្នាំ ២000-២០១៥

ជាទូទៅ ដើម្បីឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច ប្រទេសនីមួយៗត្រូវសម្រេចលក្ខខណ្ឌ ២ ក្នុងចំណោម ៣ និងរក្សាលទ្ធផលទាំងនេះឱ្យបាន ២ សម័យកាលជាប់ៗគ្នានៃកិច្ចប្រជុំត្រួតពិនិត្យរបស់គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ ។ សម័យប្រជុំប្រព្រឹត្តទៅរៀងរាល់ ៣ ឆ្នាំម្តង ហើយសម័យប្រជុំបន្ទាប់នឹងប្រព្រឹត្តនាឆ្នាំ ២០១៨ នេះ ។ ការឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច ទាមទាររយៈពេលយូរ ដើម្បីធានាចីរភាពនៃវឌ្ឍនភាព និងដើម្បីទប់ស្កាត់នូវហានិភ័យដែលអាចបង្កដោយសារការធ្លាក់ថយក្រោយនៃកិច្ចអភិវឌ្ឍន៍ ។ ជាដំបូង គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ ត្រូវទទួលស្គាល់ជាផ្លូវការអំពីការបំពេញលក្ខណសម្បត្តិគ្រប់គ្រាន់ ហើយរៀបចំបញ្ជីបេក្ខភាពប្រទេសត្រៀមឆ្លងផុតពីប្រទេសមានការអភិវឌ្ឍតិចតួច ព្រមទាំងតាមដានរាល់ ៣ ឆ្នាំម្តង (ការ

ពិនិត្យបន្ទាប់នៅឆ្នាំ ២០១៨) សម្រាប់ប្រទេសដែលស្ថិតក្នុងបញ្ជី ។ បន្ទាប់មក តម្រូវរយៈពេល ៣ ឆ្នាំបន្ថែមទៀត ដើម្បីប្រទេសដែលជាបេក្ខភាពរៀបចំខ្លួនក្នុងការឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួចជាផ្លូវការ ។ ទោះជាយ៉ាងនេះក្តី បន្ទាប់ពីប្រទេសមួយសម្រេចជាផ្លូវការក្នុងការឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច រយៈពេលអន្តរកាលនឹងត្រូវផ្តល់ដើម្បីកំណត់លទ្ធភាពស្វែងរកការគាំទ្រ និងការអនុគ្រោះផ្សេងៗ ដែលប្រទេសនោះធ្លាប់ទទួលបាន ក្នុងឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួច ។ ដូចបានបង្ហាញក្នុងតារាងទី ២.១ ការឆ្លងផុតជាផ្លូវការពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច ត្រូវចំណាយពេល ៦ ឆ្នាំ ។ ប៉ុន្តែ ការបាត់បង់អត្ថប្រយោជន៍ផ្នែកសម្បទានដែលធ្លាប់ទទួលបានក្នុងពេលជាប្រទេសមានការអភិវឌ្ឍតិចតួច អាចអូសបន្លាយរហូតដល់ ៩ ឆ្នាំ ។

**តារាងទី ២.១: ដំណើរការឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច**

| | |
|---|---|
| ឆ្នាំទី០- ឆ្នាំទី ១ ការពិនិត្យ ៣ ឆ្នាំម្តង របស់គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍ | គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍ពិនិត្យវឌ្ឍនភាព និងបញ្ជាក់អំពីលក្ខណសម្បត្តិគ្រប់គ្រាន់ (របកគំហើញលើកទី ១) |
| ឆ្នាំទី០- ឆ្នាំទី ៣ | ការវាយតម្លៃរបស់អង្គការសហប្រជាជាតិសម្រាប់ត្រៀមលក្ខណៈឡើងឋានៈ |
| ឆ្នាំទី ៣ (កិច្ចប្រជុំបន្ទាប់នៃគណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍) | គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍បញ្ជាក់ជាថ្មីអំពីលក្ខណសម្បត្តិគ្រប់គ្រាន់ (របកគំហើញលើកទី ២) និងផ្តល់អនុសាសន៍ស្តីពីការឡើងឋានៈទៅក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ (អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ) |
| ឆ្នាំទី៣- ឆ្នាំទី ៦ | ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍អន្តរកាលសម្រាប់ការឆ្លងផុតពីប្រទេសមានការអភិវឌ្ឍតិចតួច |
| ឆ្នាំទី ៦ | ការឡើងឋានៈផ្លូវការ និងចាប់ផ្តើមមានប្រសិទ្ធភាពបន្ទាប់ពីបំពេញលក្ខខណ្ឌ ក្នុងរយៈពេលអន្តរកាល |
| បន្ទាប់ពីឆ្នាំទី ៦ | ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍អន្តរកាល (តាមដានដោយគណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍) ដើម្បីធានាបាននិរន្តរភាព |

## *ស្ថានភាពកម្ពុជាក្នុងការសម្រេចលក្ខខណ្ឌសម្រាប់ឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច*

ទោះបីកម្ពុជាសម្រេចលក្ខខណ្ឌសម្រាប់ឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច ក្នុងកិច្ចប្រជុំត្រួតពិនិត្យ នាឆ្នាំ ២០១៨ នេះ កម្ពុជាត្រូវការរយៈពេលរហូតដល់ឆ្នាំ ២០២៤ ទន្ទឹមនឹងរយៈពេលអន្តរកាល ៣ ឆ្នាំបន្ថែមទៀត ។

កម្ពុជាអាចមិនសម្រេចបានលក្ខខណ្ឌស្តីពីប្រាក់ចំណូល សម្រាប់ពិនិត្យក្នុងឆ្នាំ ២០១៨ នេះ ដោយសារគណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍បានប្រើប្រាស់ប្រាក់ចំណូលមធ្យម ឆ្នាំ ២០១១-២០១៣ សម្រាប់ពិនិត្យក្នុងឆ្នាំ ២០១៥ ។ ទោះបីប្រើប្រាស់ទិន្នន័យឆ្នាំ ២០១៤-២០១៦ ក៏ប្រាក់ចំណូលរបស់ប្រជាជនម្នាក់អាច

មានត្រឹមប្រមាណ ១ ១០០ ដុល្លារ ប៉ុណ្ណោះ ។ ទន្ទឹមនឹងនេះ ពិន្ទុនៃភាពងាយរងគ្រោះខាងសេដ្ឋកិច្ចរបស់កម្ពុជា បានកាត់បន្ថយប្រមាណ ១២,២ ពិន្ទុ ពី ៥០,៥ មក ៣៨,៣ ហើយបច្ចុប្បន្ន កម្ពុជាត្រូវកាត់បន្ថយ ៦,៣ ពិន្ទុ បន្ថែមទៀត ឱ្យមកត្រឹម ៣២ ពិន្ទុ ដើម្បីសម្រេចលក្ខខណ្ឌនេះ ក្នុងឆ្នាំ ២០១៨ ។

គួរបញ្ជាក់ថា លក្ខខណ្ឌភាពងាយរងគ្រោះខាងសេដ្ឋកិច្ចត្រូវបានចែកចេញជា ៣ អនុសន្ទស្សន៍ (គំនូរទី ២.៣ ខាងក្រោម) គឺ ÷ ក)ភាពងាយរងគ្រោះរបស់ប្រជាជន (ចំនួនប្រជាជននៅតំបន់ដាច់ស្រយាល និងចំនួនប្រជាជនដែលរស់នៅតំបន់ឆ្នេរសមុទ្រ) ខ)រចនាសម្ព័ន្ធសេដ្ឋកិច្ច (លក្ខណៈប្រមូលផ្តុំនៃការនាំចេញទំនិញ និងចំណែករបស់វិស័យកសិកម្ម, ព្រៃឈើ និងជលផល) និង គ)ហានិភ័យនៃគ្រោះធម្មជាតិ និងពាណិជ្ជកម្ម ។ ចាប់ពីឆ្នាំ ២០០៩ ការកាត់បន្ថយហានិភ័យផ្នែកពាណិជ្ជកម្ម គឺជាកត្តាចម្បងក្នុងការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌភាពងាយរងគ្រោះខាងសេដ្ឋកិច្ច ។

**គំនូរទី ២.២ : សន្ទស្សន៍នៃភាពងាយរងគ្រោះខាងសេដ្ឋកិច្ច**



ប្រភព: លេខាធិការដ្ឋាននៃគណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍ ឆ្នាំ ២០១៥

## *អាទិភាពគោលនយោបាយសម្រាប់កម្ពុជាឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច*

អនុសន្ទស្សន៍ផ្នែកភាពងាយរងគ្រោះរបស់ប្រជាជន នឹងមិនអាចមានវឌ្ឍនភាពឆាប់រហ័ស ដោយចំនួនប្រជាជន និងចម្ងាយទៅកាន់ទីផ្សារនៅមានគម្លាតខ្លាំង ។ ក្នុងន័យនេះ ដើម្បីសម្រេចបានលក្ខខណ្ឌភាពងាយរងគ្រោះខាងសេដ្ឋកិច្ច សម្រាប់ឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច រាជរដ្ឋាភិបាលនឹងបន្តពង្រីក និងធ្វើឱស្សាហូបនីយកម្មវិស័យកម្មន្តសាល និងសេវាកម្ម, ធ្វើពិពិធកម្មការនាំចេញ និងទំនើបកម្មវិស័យកសិកម្ម និងត្រៀមដោះស្រាយហានិភ័យគ្រោះមហន្តរាយនានា ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងបន្តទាញយកអត្ថប្រយោជន៍ពីការគាំទ្រ និងភាពអនុគ្រោះផ្នែកពាណិជ្ជកម្ម ដែលត្រូវផ្តល់ឱ្យប្រទេសមានការអភិវឌ្ឍតិចតួច ។

ដូចបានបញ្ជាក់ខាងលើ ដោយកម្ពុជាសម្រេចបានលក្ខខណ្ឌផ្នែកធនធានមនុស្ស ការបន្តធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌស្តីពីភាពងាយរងគ្រោះខាងសេដ្ឋកិច្ច គឺជាកម្លាំងចលករ ដើម្បីកម្ពុជាក្លាយជាបេក្ខភាពក្នុងការឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច នាឆ្នាំ ២០១៨ នេះ ហើយបន្ទាប់មក អាចឆ្លងផុតជាផ្លូវការ

ពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច នាឆ្នាំ ២០២៤ ។ ម្យ៉ាងវិញទៀត កម្ពុជាក៏មានលទ្ធភាពខ្ពស់ក្នុងការសម្រេចលក្ខខណ្ឌ ២ ក្នុងចំណោមលក្ខខណ្ឌទាំង ៣ នាឆ្នាំ ២០២១ ហើយអាចឆ្លងផុតជាផ្លូវការ ពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច យ៉ាងយូរត្រឹមឆ្នាំ ២០២៧ ។ ទោះជាយ៉ាងនេះក្តី រយៈពេលអន្តរកាលនឹងផ្តល់ឱ្យកម្ពុជាបន្តទទួលអត្ថប្រយោជន៍ និងភាពអនុគ្រោះផ្សេងៗបន្តទៀត នៅក្រោយឆ្នាំ ២០២៧ ។

### ផលប៉ះពាល់បន្ទាប់ពីឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច

បន្ទាប់ពីឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច ការពិនិត្យតាមដាននៅតែបន្តអនុវត្ត ហើយផែនការអន្តរកាលសម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួច ត្រូវបានរៀបចំឡើង និងអនុវត្ត ដើម្បីសម្របខ្លួនទៅនឹងការកាត់បន្ថយបន្តិចម្តងៗ នៃការផ្តល់ការគាំទ្រនានារបស់អង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ដទៃទៀត ដែលធ្លាប់បានផ្តល់ឱ្យប្រទេសមានការអភិវឌ្ឍតិចតួច ។ ដោយឡែក បន្ទាប់ពីការឡើងឋានៈកម្ពុជាមិនអាចបន្តទទួលការគាំទ្រនានា តាមរយៈវិធានការពិសេសអន្តរជាតិដែលអង្គការសហប្រជាជាតិធ្លាប់ផ្តល់ឱ្យប្រទេសមានការអភិវឌ្ឍតិចតួច បន្ទាប់ពីបានឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច ។

ការឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច អាចមានផលប៉ះពាល់ខ្លាំងលើការធ្វើពាណិជ្ជកម្មរបស់កម្ពុជា ពិសេសជាមួយសហភាពអឺរ៉ុប ដែលតម្រូវឱ្យចរចា និងបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មថ្មីរវាងកម្ពុជា និងសហភាពអឺរ៉ុប ដូចជាៈ ១) កិច្ចព្រមព្រៀងពាណិជ្ជកម្ម ដែលផ្តល់ការអនុគ្រោះពន្ធ (ដូចធ្លាប់អនុវត្តនៅម៉ាលឌីវ) និងកូតាសម្រាប់នាំចេញមុខទំនិញជាក់លាក់ ឬ ២) កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី ដែលផ្តល់ការអនុគ្រោះស្រដៀងគ្នានឹងការអនុគ្រោះ ដែលផ្តល់ឱ្យប្រទេសមានការអភិវឌ្ឍតិចតួច ដូចបានធ្លាប់អនុវត្តជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ឆ្នាំ ២០១៦ ។ ដោយឡែក ពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិក និងជប៉ុន ក្នុងរយៈពេលរហូតដល់ការឆ្លងផុតជាផ្លូវការពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច សម្រាប់ត្រៀមខ្លួនចូលរួមក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មថ្នាក់តំបន់ ។

### ផលប៉ះពាល់លើភាពប្រកួតប្រជែងរបស់កម្ពុជា បន្ទាប់ពីឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច

បញ្ហារបស់កម្ពុជាពាក់ព័ន្ធនឹងពាណិជ្ជកម្ម គឺភាពប្រកួតប្រជែងផ្នែកពាណិជ្ជកម្មរបស់កម្ពុជា ពិសេសជាមួយប្រទេសមីយ៉ាន់ម៉ា និងបង់ក្លាដេស ដែលជាប្រទេសមានការអភិវឌ្ឍតិចតួច និងមានទីផ្សារនាំចេញស្រដៀងគ្នានឹងកម្ពុជា ។ ទិន្នន័យឆ្នាំ ២០១៥ នៃរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃរបស់គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ បានបង្ហាញថា មីយ៉ាន់ម៉ា និងបង់ក្លាដេស សុទ្ធតែមានកម្រិតប្រាក់ចំណូល និងភាពងាយរងគ្រោះខាងសេដ្ឋកិច្ចល្អប្រសើរជាងកម្ពុជា ហើយអាចឈានទៅសម្រេចលក្ខខណ្ឌក្នុងការឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួចទន្ទឹមនឹងកម្ពុជាដែរ ។ ក្នុងន័យនេះ បន្ទាប់ពីឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច ការពង្រឹងភាពប្រកួតប្រជែងផ្នែកពាណិជ្ជកម្មជាមួយមីយ៉ាន់ម៉ា និងបង់ក្លាដេស គឺជាអាទិភាពខ្ពស់របស់កម្ពុជា ។

| លេខរៀង | ចំណូលជាតិសម្រាប់ប្រជាជនម្នាក់ៗ (ដុល្លារអាមេរិក) (លក្ខខណ្ឌ > ១ ២៤២ដុល្លារអាមេរិក) | ផ្នែកធនធានមនុស្ស (លក្ខខណ្ឌ > ៦៦ ពិន្ទុ) | ភាពងាយរងគ្រោះខាងសេដ្ឋកិច្ច (លក្ខខណ្ឌ < ៣២ ពិន្ទុ) |
|---|---|---|---|
| ១ | ប្រទេសមីយ៉ាន់ម៉ា- ១ ០៦៣ | ប្រទេសមីយ៉ាន់ម៉ា- ៧២,៧ | ប្រទេសបង់ក្លាដេស- ២៥,១ |
| ២ | ប្រទេសបង់ក្លាដេស- ៩២៦ | ប្រទេសកម្ពុជា- ៦៧,២ | ប្រទេសមីយ៉ាន់ម៉ា- ៣៣,៧ |
| ៣ | ប្រទេសកម្ពុជា- ៨៥២ | ប្រទេសបង់ក្លាដេស- ៦៣,៨ | ប្រទេសកម្ពុជា- ៣៨,៣ |

ប្រភពពី៖ UNDESA LDC Handbook ឆ្នាំ ២០១៥ (ទំព័រទី ៦៨)

## *ទិសដៅអាទិភាពរបស់កម្ពុជា*

កម្ពុជាអាចឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួចក្នុងរង្វង់ ១០ ឆ្នាំខាងមុខ និងត្រូវប្រឈមនឹងភាពលំបាក និងភាពស្មុគស្មាញជាច្រើន ដែលតម្រូវឱ្យមានការសិក្សាស្រាវជ្រាវបន្ថែមលើលក្ខខណ្ឌវិនិច្ឆ័យទាំង ៣ ឱ្យបានច្បាស់លាស់ និងគ្រប់គ្រងកិច្ចការពាក់ព័ន្ធ ដូចជាការរៀបចំយុទ្ធសាស្ត្រម៉ាក្រូសេដ្ឋកិច្ច និងការកែទម្រង់តាមវិស័យ ដើម្បីធានាការឆ្លងផុតដោយជោគជ័យពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច និងអាចសម្របតាមបរិការណ៍អភិវឌ្ឍន៍ថ្មី ។ ក្នុងរយៈពេល ១០ ឆ្នាំ ខាងមុខ ហិរញ្ញប្បទានសហប្រតិបត្តិការក៏ដូចជាកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងដៃគូអភិវឌ្ឍន៍ អាចមានការប្រែប្រួល ។ ដៃគូអភិវឌ្ឍន៍អាចពិនិត្យការគាំទ្ររបស់ខ្លួនឡើងវិញ, អាចសម្រេចបញ្ចប់កិច្ចសហប្រតិបត្តិការនៅកម្ពុជា ឬអាចស្នើបន្ថែមថវិកាបដិភាគ ឬប្តូរពីហិរញ្ញប្បទានឥតសំណងទៅជាហិរញ្ញប្បទានកម្ចី ។ ដោយឡែក ការធ្វើពាណិជ្ជកម្មជាមួយសហភាពអឺរ៉ុបអាចប្រែប្រួល ប៉ុន្តែអាចបន្តផ្តល់ភាពអនុគ្រោះ ។

ទោះបីដៃគូអភិវឌ្ឍន៍ពិនិត្យការគាំទ្ររបស់ខ្លួនឡើងវិញ ការបន្តឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួចទន្ទឹមនឹងការប្តេជ្ញាសកលក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ គឺជាកាលានុវត្តភាព សម្រាប់កម្ពុជាបន្តពង្រឹងការកៀរគរធនធានហិរញ្ញប្បទាន និងវិភាជប្រកបដោយប្រសិទ្ធភាពខ្ពស់ ស្របតាមគោលដៅអភិវឌ្ឍន៍ជាតិ ។

ការរៀបចំយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរបស់រាជរដ្ឋាភិបាល ដើម្បីធានាការឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច (ដែលផ្តោតសំខាន់លើការបង្កើនប្រាក់ចំណូល, ការពង្រឹងវិស័យសុខាភិបាល និងអប់រំ, ការកែទម្រង់វិស័យឧស្សាហកម្ម និងកសិកម្ម, និងកិច្ចសម្រួលពាណិជ្ជកម្ម) នឹងរួមចំណែកយ៉ាងសំខាន់ ក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងបន្តប្តេជ្ញាអនុវត្តឱ្យបានសម្រេចនូវគោលដៅអភិវឌ្ឍន៍ជាតិ និងសកល ព្រមទាំងបន្តគ្រប់គ្រង និងអនុវត្តកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ដើម្បីធានាប្រសិទ្ធភាពនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ ក្នុងទិសដៅគាំទ្រផ្ទាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច, ការពង្រឹងស្ថាប័ន និងការផ្តល់សេវាសាធារណៈ ។ លើសពីនេះ កម្ពុជានឹងបន្តទាញយកអត្ថប្រយោជន៍ឱ្យអស់លទ្ធភាពពីការគាំទ្រនិងការអនុគ្រោះក្នុងក្របខ័ណ្ឌអន្តរជាតិ ដែលផ្តល់ឱ្យប្រទេសមានការអភិវឌ្ឍតិចតួច ។

# ជំពូក ៣
# ការវិវត្តនៃហិរញ្ញប្បទានសហប្រតិបត្តិការ

ក្នុងបណ្តាទស្សវត្សរ៍ចុងក្រោយនេះ ហិរញ្ញប្បទានក្រៅប្រទេសរាប់ពាន់លានដុល្លារបានចូលរួមគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្ស, ការពង្រឹងសមត្ថភាពជាតិ និងកែលម្អបរិស្ថានធុរកិច្ច និងសុខុមាលភាពសង្គម ។ ផ្អែកលើផែនការយុទ្ធសាស្ត្រ និងការកែទម្រង់ឥតឈប់ឈរ រាជរដ្ឋាភិបាលបានដឹកនាំការអភិវឌ្ឍប្រទេស ដោយបានសម្រេចកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្ន និងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាដៃគូអភិវឌ្ឍន៍ ដែលបានផ្តល់ភាពងាយស្រួល ដើម្បីក្រសួងនិងស្ថាប័នកៀរគរធនធាន សម្រាប់គាំទ្រការអភិវឌ្ឍជាតិ ។

ជំពូកនេះបង្ហាញពីការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ដោយបានវិភាគអំពីទម្រង់, លក្ខខណ្ឌ និងការប្រែប្រួលសំខាន់ៗនៃការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ។ ការវិភាគនេះក៏ពិនិត្យផងដែរ អំពីការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍សម្រាប់រយៈពេលមធ្យម ដោយផ្តោតការយកចិត្តទុកដាក់ពិសេសលើការបើកផ្តល់ក្នុងឆ្នាំ ២០១៧ និងរំលេចអំពីយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលសម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការ ដើម្បីសម្រេចលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ ។

## *ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ ឆ្នាំ ២០០៨-២០១៨*

ការបើកផ្តល់ហិរញ្ញប្បទានក្រៅប្រទេសនៅកម្ពុជា ត្រូវបានបែងចែកជា ៣ ប្រភេទ គឺ ÷ ហិរញ្ញប្បទានឥតសំណង, កម្ចីសម្បទាន និងធនធានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាល ។ គំនូរទី ៣.១ បង្ហាញថា ការបើកផ្តល់ហិរញ្ញប្បទានបានកើនពី ៩៧៩ លានដុល្លារ ក្នុងឆ្នាំ ២០០៨ ដល់ ១ ៣៥០ លានដុល្លារ ក្នុងឆ្នាំ ២០១៧ ។ គួរកត់សម្គាល់ថា ការបើកផ្តល់ហិរញ្ញប្បទានបានកើនលឿនចាប់ពីឆ្នាំ ២០០៨ ។ ហិរញ្ញប្បទានបានកើនខ្ពស់បំផុត ប្រមាណ ១ ៥០០ លានដុល្លារ ក្នុងឆ្នាំ ២០១២ ប៉ុន្តែ បានធ្លាក់ចុះបន្តិចមកត្រឹម ១ ៤៥០ លានដុល្លារ ក្នុងឆ្នាំ ២០១៤ និង ១ ២៧០ លានដុល្លារ ក្នុងឆ្នាំ ២០១៦ ។ ការព្យាករណ៍ការបើកផ្តល់ហិរញ្ញប្បទានក្នុងឆ្នាំ ២០១៧ (គិតបញ្ចូលគម្រោងដែលគ្រោងអនុវត្ត ១៤,២ លានដុល្លារ) មាន ១ ៣៥០ លានដុល្លារ ។

ការបើកផ្តល់ហិរញ្ញប្បទានបានចាប់កើនឡើងក្នុងឆ្នាំ ២០១០ ដោយសារកំណើនហិរញ្ញប្បទានឥតសំណង ប៉ុន្តែ ហិរញ្ញប្បទានបានកើនខ្ពស់បំផុត ក្នុងឆ្នាំ ២០១២ ដោយសារកំណើនកម្ចីសម្បទាន ។ កម្ចីសម្បទានបន្តកើនដល់ឆ្នាំ ២០១៣ ហើយបានធ្លាក់ចុះពី ៥៨៣ លានដុល្លារ ក្នុងឆ្នាំ ២០១៤ មកត្រឹម ៤២០

លានដុល្លារ ក្នុងឆ្នាំ ២០១៦ ។ ដោយឡែក ក្នុងឆ្នាំ ២០១៧ កម្ចីសម្បទានបានកើនឡើងជាថ្មី ដល់ ៥២៦ លានដុល្លារ ដែលនាំឱ្យហិរញ្ញប្បទានសរុបបានកើនឡើងម្តងទៀត ក្នុងអត្រាកំណើនប្រចាំឆ្នាំ ប្រមាណ ៩% ។

ទោះបីការបើកផ្តល់ហិរញ្ញប្បទានឥតសំណងពុំមានការប្រែប្រួលខ្លាំងក្នុងចន្លោះឆ្នាំ ២០១២-២០១៧ ក៏ដោយ ក៏ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលបានធ្លាក់ចុះពី ២៥០ លានដុល្លារ ក្នុងឆ្នាំ ២០១៦ មកត្រឹម ២១១ លានដុល្លារ ក្នុងឆ្នាំ ២០១៧ ក្នុងពេលដែលហិរញ្ញប្បទានឥតសំណងបានកើន ៥០ លានដុល្លារ ពោលគឺបានកើនឡើងប្រមាណ ១០% ធៀបនឹងហិរញ្ញប្បទានឥតសំណងឆ្នាំ ២០១៦ ។

**គំនូសទី ៣.១ ការបើកផ្តល់ហិរញ្ញប្បទាន ឆ្នាំ ២០០៨-២០១៨**




**គំនូសទី ៣.២ ហិរញ្ញប្បទានសម្រាប់ប្រជាជនម្នាក់ និង អនុបាតហិរញ្ញប្បទានធៀបនឹង ផ.ស.ស ឆ្នាំ ២០០៧-២០១៧**




ហិរញ្ញប្បទានក្រៅប្រទេសបានរួមចំណែកមួយផ្នែកដល់កំណើនសេដ្ឋកិច្ចរបស់កម្ពុជា ។ ទោះជាយ៉ាងនេះក្តី អនុបាតធនធានក្រៅប្រទេស ធៀបនឹងផលិតផលក្នុងស្រុកសរុប (ផ.ស.ស) បានធ្លាក់ចុះពី ១០% ក្នុងឆ្នាំ ២០១៣ មកត្រឹម ៦% ក្នុងឆ្នាំ ២០១៧ (គំនូសទី ៣.២) ដោយសារ ផ.ស.ស បានកើនលឿនជាងហិរញ្ញប្បទានសហប្រតិបត្តិការ ។ ក្នុងរយៈពេលដូចគ្នានេះ ហិរញ្ញប្បទានសម្រាប់ប្រជាជនម្នាក់មានប្រមាណ ៩០ ដុល្លារ ក្នុងមួយឆ្នាំ ។ លើមូលដ្ឋាននេះ ហិរញ្ញប្បទានសហប្រតិបត្តិការបានដើរតួនាទីសំខាន់ សម្រាប់កម្ពុជាត្រៀមខ្លួនក្នុងដំណាក់កាលអន្តរកាលសម្រាប់ចាកចេញពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច ពីព្រោះរាជរដ្ឋាភិបាលត្រូវដោះស្រាយបញ្ហាប្រឈមចំពោះមុខមួយចំនួន ដែលពាក់ព័ន្ធនឹងការកាត់បន្ថយភាពងាយរងគ្រោះខាងសេដ្ឋកិច្ច, ការអភិវឌ្ឍធនធានមនុស្ស និងការពង្រឹងសមត្ថភាពស្ថាប័ន ។

ផ្អែកតាមចំណាត់ថ្នាក់អភិវឌ្ឍន៍របស់ប្រទេស កំណើននៃកម្ចីសម្បទានរបស់កម្ពុជាក្នុងឆ្នាំ ២០១៧ អាចបញ្ជាក់ថា កម្ពុជាមិនសូវមានឱកាសទទួលហិរញ្ញប្បទានឥតសំណងតាមទំហំដូចធ្លាប់បានទទួលកន្លងមកឡើយ នៅពេលដែលកម្ពុជាក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប ។ ប៉ុន្តែជាក់ស្តែង ទិន្នន័យបានបង្ហាញថា ហិរញ្ញប្បទានឥតសំណងបន្តរក្សាទំហំនឹងនរ ទន្ទឹមនឹងការកើនឡើងនៃកម្ចីសម្បទាន ។ ប្រការដែលបានក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប តាមប្រព័ន្ធចំណាត់ថ្នាក់របស់ធនាគារពិភពលោក

អាចធ្វើឱ្យដៃគូអភិវឌ្ឍន៍មួយចំនួនផ្លាស់ប្តូរលក្ខខណ្ឌនៃការផ្តល់ហិរញ្ញប្បទាន ពីហិរញ្ញប្បទានឥតសំណងទៅជាកម្ចីសម្បទាន ។ ប៉ុន្តែ ការឡើងចំណាត់ថ្នាក់នេះមិនជះឥទ្ធិពលដល់ការទទួលហិរញ្ញប្បទានអភិវឌ្ឍន៍របស់កម្ពុជា (ហិរញ្ញប្បទានឥតសំណង និងអត្ថប្រយោជន៍ពាក់ព័ន្ធនឹងពាណិជ្ជកម្ម) ក្នុងឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួចឡើយ ។ ការបន្តឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួច តាមប្រព័ន្ធចំណាត់ថ្នាក់របស់អង្គការសហប្រជាជាតិ នឹងផ្តល់លទ្ធភាពដល់កម្ពុជាបន្ថែមទៀត ដើម្បីកៀរគរធនធានហិរញ្ញប្បទានសម្រាប់គាំទ្រកិច្ចអភិវឌ្ឍន៍ជាតិ ។

## *ការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ ២០០៨-២០១៨*

តារាងទី៣.១ បង្ហាញអំពីការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ ក្នុងចន្លោះឆ្នាំ ២០០៨-២០១៨ ។ ការបើកផ្តល់ធនធានរបស់ភ្នាក់ងារអង្គការសហប្រជាជាតិ (លើកលែងកម្ចីពីមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម) និងធនធានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាល គឺជាហិរញ្ញប្បទានឥតសំណង ។ ក្នុងឆ្នាំ ២០១៧ ការបើកផ្តល់របស់ភ្នាក់ងារអង្គការសហប្រជាជាតិបានកើន ១៣ លានដុល្លារ ធៀបនឹងឆ្នាំ ២០១៦ ។ ការបើកផ្តល់របស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិបានកើនប្រមាណ ១១០ លានដុល្លារ ក្នុង ចន្លោះឆ្នាំ ២០១៦-២០១៨ ។ ការបើកផ្តល់ហិរញ្ញប្បទានច្រើនជាងគេ មានប្រភពមកពីដៃគូទ្វេភាគី ។ ជាក់ស្តែង ជប៉ុន, អាមេរិក, អូស្ត្រាលី និងកូរ៉េ បានបើកផ្តល់ធនធានប្រមាណ ២៥០ លានដុល្លារ ក្នុងមួយឆ្នាំក្នុងចន្លោះឆ្នាំ ២០១៥-២០១៨ ។

ពិនិត្យជារួម ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការក្នុងឆ្នាំ ២០១៧ បានកើនឡើង ដោយសារកំណើនបើកផ្តល់របស់ភ្នាក់ងារអង្គការសហប្រជាជាតិ, ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ, ដៃគូអភិវឌ្ឍន៍នៃទ្វីបអឺរ៉ុប និងជប៉ុន ។ ធនាគារអភិវឌ្ឍន៍អាស៊ី និងបារាំង គឺជាដៃគូសំខាន់ដែលបានបើកផ្តល់ ១៩%នៃធនធានសរុប ។ រីឯជប៉ុនបានបើកផ្តល់ហិរញ្ញប្បទានប្រមាណ ១/១០ នៃធនធានសរុបក្នុងឆ្នាំ ២០១៧ ។ ទោះបីការបើកផ្តល់របស់សាធារណរដ្ឋប្រជាមានិតចិន ក្នុងឆ្នាំ ២០១៧ បានធ្លាក់ចុះបន្តិច ក៏សាធារណរដ្ឋប្រជាមានិតចិននៅតែជាដៃគូសំខាន់ ដែលបានបើកផ្តល់ ២២៤ លានដុល្លារ ស្មើនឹង ១៧% នៃហិរញ្ញប្បទានសរុប ។

| ដៃគូអភិវឌ្ឍន៍ | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 ប៉ាន់ស្មាន | 2018 ព្យាករណ៍ |
|---|---|---|---|---|---|---|---|---|---|---|---|

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ***ភ្នាក់ងារអង្គការសហប្រជាជាតិ*** | | | | | | | | | | | |
| Total Programmes | 118.8 | 148.9 | 114.0 | 89.5 | 88.1 | - | 107.2 | 93.7 | 93.4 | - | - |
| Total Own Funds | 73.2 | 101.8 | 73.9 | 56.5 | 53.7 | 49.8 | 53.9 | 47.2 | 63.2 | 76.3 | 57.0 |
| **ដៃគូពហុភាគី** | | | | | | | | | | | |
| World Bank | 41.7 | 60.4 | 56.9 | 73.8 | 66.0 | 35.5 | 50.6 | 17.6 | 20.1 | 39.7 | 54.2 |
| Asian Development Bank | 145.7 | 89.4 | 75.4 | 126.9 | 82.0 | 171.4 | 129.8 | 137.2 | 109.9 | 146.0 | 181.2 |
| GAVI Alliance | - | 1.7 | 3.6 | 6.7 | 4.9 | 10.7 | 5.5 | 19.0 | 10.2 | 10.9 | 9.2 |
| Global Fund | 38.6 | 46.5 | 61.2 | 60.2 | 20.1 | 45.4 | 54.6 | 33.3 | 28.2 | 71.7 | - |
| **សរុប** | **299.2** | **299.7** | **270.9** | **324.1** | **226.8** | **312.8** | **294.4** | **254.3** | **231.5** | **344.6** | **301.6** |
| ***សហភាពអឺរ៉ុប*** | | | | | | | | | | | |
| European Commission | 48.4 | 49.4 | 32.9 | 61.0 | 41.6 | 36.6 | 70.3 | 55.8 | 56.0 | 59.8 | 26.7 |
| Czech Republic | 0.0 | - | - | - | - | - | 1.2 | 1.2 | 1.3 | 1.2 | - |
| France | 29.8 | 25.4 | 22.4 | 19.5 | 24.8 | 17.8 | 59.5 | 63.3 | 31.9 | 103.3 | 40.6 |
| Germany | 36.6 | 27.9 | 35.3 | 43.7 | 44.6 | 34.3 | 29.8 | 25.8 | 48.4 | 36.5 | 29.7 |
| Ireland | | 0.7 | 0.7 | 0.7 | 0.3 | 1.2 | 0.7 | 0.6 | 0.6 | 1.3 | 1.3 |
| Sweden | 15.9 | 22.8 | 24.7 | 28.6 | 30.2 | 33.8 | 33.0 | 21.8 | 30.1 | 20.3 | 13.0 |
| United Kingdom | 29.6 | 32.6 | 24.7 | 34.2 | 28.2 | 13.7 | 0.1 | 0.2 | 1.6 | 2.3 | 0.3 |
| Other EU Member States | 30.7 | 41.9 | 52.0 | 48.3 | 18.2 | 9.9 | 6.0 | | | | |
| **សរុប** | **191.0** | **200.7** | **192.7** | **236.1** | **187.9** | **147.3** | **200.6** | **168.7** | **169.8** | **224.6** | **111.6** |
| ***ដៃគូទ្វេភាគីដទៃទៀត*** | | | | | | | | | | | |
| Australia | 49.1 | 47.8 | 63.4 | 78.2 | 79.5 | 59.3 | 64.9 | 55.9 | 51.9 | 56.3 | 41.3 |
| Canada | 11.5 | 16.7 | 12.8 | 18.5 | 20.5 | 11.8 | 5.7 | 3.8 | 3.0 | 1.6 | 0.7 |
| China | 95.4 | 114.7 | 154.1 | 332.0 | 460.7 | 436.6 | 347.8 | 339.4 | 265.3 | 223.5 | 251.4 |
| Japan | 126.4 | 134.0 | 140.0 | 114.4 | 172.3 | 130.8 | 111.4 | 110.4 | 119.7 | 126.4 | 168.0 |
| New Zealand | 2.8 | 2.3 | 5.2 | 4.4 | 3.8 | 3.2 | 6.0 | 4.9 | 4.0 | 5.3 | 5.5 |
| Republic of Korea | 33.0 | 15.8 | 35.2 | 45.3 | 46.2 | 50.1 | 80.3 | 61.7 | 31.9 | 51.2 | 24.6 |
| Switzerland | 3.9 | 3.0 | 3.1 | 4.5 | 4.3 | 7.8 | 11.8 | 13.0 | 15.8 | 13.8 | 10.0 |
| United States of America | 55.7 | 56.9 | 63.3 | 64.4 | 85.0 | 93.5 | 91.6 | 101.0 | 71.1 | 76.0 | 35.7 |
| **សរុប** | **377.6** | **391.3** | **477.2** | **661.8** | **872.3** | **793.1** | **719.6** | **690.0** | **562.6** | **554.2** | **537.2** |
| NGOs (ធនធានផ្ទាល់) | 110.8 | 108.5 | 165.0 | 200.7 | 212.3 | 220.8 | 230.7 | 237.7 | 250.3 | 211.3 | 122.7 |
| **គម្រោងពុំទាន់អនុវត្ត** | | | | | | | | | | 14.2 | 147.2 |
| **សរុប** | **978.5** | **1000.2** | **1105.8** | **1422.6** | **1499.2** | **1473.9** | **1445.2** | **1350.7** | **1214.2** | **1348.9** | **1220.3** |

**តារាងទី ៣.១ ការបើកផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ឆ្នាំ ២០០៨-២០១៨ (លានដុល្លារ)**

## ការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ ឆ្នាំ ២០០៨-២០១៨

ការអភិវឌ្ឍជាអភិក្រមទូលំទូលាយ ។ ក្នុងន័យនេះ ដើម្បីរំលេចអំពីកិច្ចការរួមគ្នារវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ក្នុងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ, ការបើកផ្តល់ហិរញ្ញប្បទានត្រូវបានវិភាជតាមវិស័យ និងអនុវិស័យអាទិភាព ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលអាចឆ្លុះបញ្ចាំងអំពីកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ។

តារាងទី ៣.២ បង្ហាញអំពីការបើកផ្តល់ហិរញ្ញប្បទាន ឆ្នាំ ២០០៨-២០១៨ ។ ក្នុងឆ្នាំ ២០១៦ វិស័យសង្គមកិច្ចបានទទួលហិរញ្ញប្បទានច្រើនជាងវិស័យដទៃ ស្មើ ៣៩% នៃហិរញ្ញប្បទានសរុប ហើយបន្ទាប់មកគឺវិស័យហេដ្ឋារចនាសម្ព័ន្ធ ២៩%, វិស័យសេដ្ឋកិច្ច ១៩% និងអន្តរវិស័យ ១៣% ។

**តារាងទី ៣.២ ការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ ឆ្នាំ ២០០៨-២០១៨ (លានដុល្លារ)**

| វិស័យ | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 បាន់ស្មាន | 2018 ព្យាករណ៍ |
|---|---|---|---|---|---|---|---|---|---|---|---|
| **វិស័យសង្គមកិច្ច** | | | | | | | | | | | |
| សុខាភិបាល | 136.7 | 161.8 | 211.4 | 205.3 | 203.0 | 203.2 | 204.8 | 203.7 | 209.3 | 213.8 | 102.0 |
| អប់រំ | 100.5 | 95.5 | 115.6 | 154.6 | 135.3 | 140.4 | 167.1 | 174.9 | 171.3 | 148.2 | 90.3 |
| ហ៊ីវ/ អេដស៍ | 57.9 | 56.3 | 46.4 | 69.4 | 33.5 | 34.7 | 45.8 | 30.2 | 23.2 | 32.2 | 6.4 |
| សហគមន៍ និងសុខុមាលភាពសង្គម | 51.7 | 54.5 | 58.9 | 138.2 | 136.4 | 81.1 | 84.8 | 98.6 | 65.9 | 53.9 | 36.5 |
| **សរុប** | **346.8** | **368.1** | **432.3** | **567.5** | **508.2** | **459.4** | **502.5** | **507.4** | **469.7** | **448.1** | **235.2** |
| **វិស័យសេដ្ឋកិច្ច** | | | | | | | | | | | |
| កសិកម្ម | 46.1 | 80.9 | 90.4 | 144.9 | 185.4 | 184.4 | 218.1 | 171.0 | 142.0 | 181.7 | 173.9 |
| អភិវឌ្ឍន៍ជនបទ | 56.8 | 64.4 | 67.8 | 48.6 | 81.3 | 77.0 | 85.5 | 93.6 | 67.6 | 74.8 | 73.9 |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | 24.5 | 11.1 | 9.0 | 13.4 | 11.4 | 11.1 | 3.2 | 4.5 | 5.3 | 18.3 | 1.3 |
| សេវាកម្មធនាគារ និងធុរកិច្ច | 44.9 | 12.8 | 30.9 | 73.1 | 4.0 | 43.8 | 14.3 | 27.0 | 14.0 | 14.8 | 4.5 |
| នគរូបនីយកម្ម និងការគ្រប់គ្រង | 4.5 | 16.1 | 10.9 | 2.7 | 11.9 | 0.3 | 6.6 | 7.4 | 6.0 | 12.1 | 24.1 |
| **សរុប** | **176.8** | **185.3** | **209.0** | **282.7** | **294.0** | **316.6** | **327.7** | **303.5** | **234.9** | **301.7** | **277.7** |
| **វិស័យហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | | | | |
| ដឹកជញ្ជូន | 161.9 | 180.3 | 184.7 | 271.2 | 383.6 | 379.0 | 309.4 | 286.8 | 164.3 | 216.6 | 226.3 |
| ទឹកស្អាត និងអនាម័យ | 25.5 | 17.3 | 24.4 | 36.1 | 52.3 | 59.3 | 63.7 | 37.8 | 39.0 | 75.7 | 37.5 |
| ថាមពល និងអគ្គិសនី | 32.8 | 21.7 | 41.5 | 57.3 | 66.7 | 59.9 | 66.5 | 54.8 | 138.8 | 88.6 | 136.1 |
| ព័ត៌មាន និងទូរគមនាគមន៍ | 7.1 | 7.5 | 1.8 | 0.2 | 1.3 | 3.0 | 10.8 | 5.0 | 12.5 | 0.9 | - |
| **សរុប** | **227.3** | **226.8** | **252.4** | **364.8** | **503.9** | **501.2** | **450.4** | **384.4** | **354.6** | **381.8** | **399.9** |
| **អន្តរវិស័យ** | | | | | | | | | | | |
| យេនឌ័រ | 5.5 | 5.2 | 6.0 | 6.4 | 8.7 | 9.8 | 8.5 | 6.1 | 6.4 | 3.8 | 2.3 |
| ទេសចរណ៍ | 5.0 | 6.0 | 4.0 | 2.2 | 0.8 | 0.7 | 0.6 | 1.8 | 1.4 | 17.2 | 9.8 |
| បរិស្ថាន និងចីរភាព | 16.7 | 11.5 | 36.8 | 18.1 | 14.2 | 24.3 | 26.8 | 33.1 | 29.5 | 19.0 | 16.5 |
| ការប្រែប្រួលអាកាសធាតុ | - | 9.1 | 5.3 | 5.9 | 7.3 | 8.8 | 7.0 | 7.7 | 8.1 | 11.3 | 14.5 |
| វប្បធម៌ និងសិល្បៈ | 6.3 | 5.9 | 6.2 | 4.3 | 4.6 | 4.6 | 5.5 | 6.2 | 3.8 | 4.6 | 39.7 |
| អភិបាលកិច្ច និងរដ្ឋបាល | 118.5 | 126.0 | 113.5 | 111.9 | 100.7 | 117.7 | 84.3 | 77.8 | 101.7 | 83.1 | 53.1 |
| ការគាំទ្រថវិកា និងជញ្ជីងទូទាត់ | 21.9 | 20.5 | 0.3 | 0.3 | 14.8 | - | - | - | - | - | - |
| ជំនួយសង្គ្រោះបន្ទាន់ និងស្បៀងអាហារ | 16.0 | 11.1 | 14.8 | 25.5 | 25.0 | 19.3 | 25.2 | 14.8 | 1.3 | 0.3 | - |
| **សរុប** | **189.9** | **195.3** | **186.9** | **174.6** | **176.1** | **185.2** | **157.9** | **147.5** | **152.2** | **139.3** | **135.9** |
| ផ្សេងៗ | 37.5 | 24.6 | 25.1 | 32.9 | 17.0 | 11.6 | 6.9 | 7.8 | 2.9 | 63.8 | 24.5 |
| គម្រោងពុំទាន់អនុវត្ត | | | | | | | | | | 14.2 | 147.2 |
| **សរុប** | **978.3** | **1,000.1** | **1,105.7** | **1,422.5** | **1,499.2** | **1,474. 0** | **1,445.4** | **1,350.6** | **1,214.3** | **1,348.9** | **1,220.4** |

ក្នុងឆ្នាំ ២០១៧ ហិរញ្ញប្បទានសរុបបានកើន ៩% ធៀបនឹងឆ្នាំ ២០១៦ ដោយសារការកើនឡើងនៃការបើកផ្តល់ក្នុងវិស័យសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធ ។ ជាក់ស្តែង ហិរញ្ញប្បទានក្នុងវិស័យសេដ្ឋកិច្ចបានកើនពី ២៣៥ លានដុល្លារក្នុងឆ្នាំ ២០១៦ ដល់ ៣០២ លានដុល្លារ ក្នុងឆ្នាំ ២០១៧ ដោយសារកំណើនហិរញ្ញប្បទានក្នុងវិស័យកសិកម្ម, សេវាកម្មធនាគារ និងធុរកិច្ច និងនគរូបនីយកម្ម ។ ក្នុងរយៈពេល ៥ ឆ្នាំ ចុងក្រោយនេះ ហិរញ្ញប្បទានក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធពុំមានភាពនឹងនរ ដោយសារគម្រោងវិនិយោគធំៗមួយចំនួនបាន

បញ្ចប់ការដ្ឋានសាងសង់ ។ បន្ទាប់ពីបានកើនខ្ពស់បំផុតក្នុងឆ្នាំ ២០១២ (៥០៤ លានដុល្លារ) ហិរញ្ញប្បទានក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធបានធ្លាក់ចុះមកត្រឹម ៣៥៥ លានដុល្លារ ក្នុងឆ្នាំ ២០១៦ ហើយបានកើនឡើងសារជាថ្មីដល់ ៣៨២ លានដុល្លារ ក្នុងឆ្នាំ ២០១៧ និង ៤០០ លានដុល្លារ ក្នុងឆ្នាំ ២០១៨ ដោយសារកំណើនហិរញ្ញប្បទានក្នុងវិស័យដឹកជញ្ជូន, ថាមពល និងវិស័យទឹកស្អាត និងអនាម័យ ។

ក្នុងចន្លោះឆ្នាំ ២០១៥-២០១៦ ហិរញ្ញប្បទានសរុបបានធ្លាក់ចុះ ១០% ហើយការបើកផ្តល់តាមវិស័យក៏មានការធ្លាក់ចុះដែរ ។ ទោះបីហិរញ្ញប្បទានបានកើនឡើងក្នុងឆ្នាំ ២០១៧ ប៉ុន្តែ ទំហំហិរញ្ញប្បទានក្នុងវិស័យសង្គមកិច្ច និងអន្តរវិស័យពុំបានកើនឡើងឡើយ ហើយតាមការព្យាករណ៍ ទំហំហិរញ្ញប្បទានក្នុងវិស័យទាំងពីរនេះនឹងបន្តធ្លាក់ចុះ ។

## *និន្នាការសំខាន់ៗនៃការបើកផ្តល់កម្ចីសម្បទាន ឆ្នាំ ២០១៤-២០១៨*

ទន្ទឹមនឹងហិរញ្ញប្បទានឥតសំណងមានទំហំនឹងនរ កំណើននៃកម្ចីសម្បទានបាននាំឱ្យហិរញ្ញប្បទានសហប្រតិបត្តិការសរុប ក្នុងឆ្នាំ ២០១៧ កើនឡើង ។ តារាងទី ៣.៣ បង្ហាញពីនិន្នាការសំខាន់ៗនៃការបើកផ្តល់កម្ចីសម្បទានតាមវិស័យ ក្នុងចន្លោះឆ្នាំ ២០១៤-២០១៨ ។

ក្នុងឆ្នាំ ២០១៦ កម្ចីសម្បទានមាន ៤២០ លានដុល្លារ ស្មើនឹង ៤៤% នៃហិរញ្ញប្បទានសរុប (មិនរាប់បញ្ចូលធនធានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាល) ។ ដោយគិតបញ្ចូលគម្រោងដែលគ្រោងអនុវត្ត កម្ចីសម្បទានបានកើនដល់ ៥២៦ លានដុល្លារ ក្នុងឆ្នាំ ២០១៧ ដោយសារការបើកផ្តល់របស់សាធារណរដ្ឋបារាំងក្នុងវិស័យទឹកស្អាត និងអនាម័យ ៤៥ លានដុល្លារ និងឧស្សាហូបនីយកម្ម និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ១៥ លានដុល្លារ ។ ជារួម កម្ចីសម្បទាននឹងបន្តកើនដល់ ៦១% នៃហិរញ្ញប្បទានសរុបក្នុងឆ្នាំ ២០១៨ ដោយសារកម្ចីសម្បទានកើនឡើងខ្ពស់ក្នុងវិស័យកសិកម្ម, ថាមពល និងអគ្គិសនី ។

ក្នុងវិស័យទាំង ៧ ដែលទទួលកម្ចីសម្បទាន, វិស័យសំខាន់ ៤ គឺវិស័យដឹកជញ្ជូន, វិស័យកសិកម្ម, វិស័យថាមពល និងវិស័យទឹកស្អាត បានទទួលធនធានប្រមាណ ៨៦% នៃធនធានសរុបឆ្នាំ ២០១៤ ប៉ុន្តែអាច នឹងធ្លាក់ចុះមកត្រឹម ៨០% ក្នុងឆ្នាំ ២០១៨ ក្នុងពេលដែលមានវិស័យ ៩ ទៀតក៏បានទទួលកម្ចីសម្បទាន ។ ដោយកម្ចីសម្បទានបានកើនឡើងជាបន្តបន្ទាប់ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តយ៉ាងម៉ត់ចត់នូវយុទ្ធសាស្ត្រស្តីពី ការគ្រប់គ្រងបំណុល ដោយតម្រង់ទិសការប្រើប្រាស់ធនធាននេះសម្រាប់គាំទ្រគម្រោង និងវិស័យអាទិភាព ។

**តារាងទី ៣.៣ ការបើកផ្តល់កម្ចីសម្បទានតាមវិស័យឆ្នាំ ២០១៤-២០១៨ (លានដុល្លារ)**

| វិស័យ | 2014 | 2015 | 2016 | 2017 | 2018 | សរុប |
|---|---|---|---|---|---|---|
| ដឹកជញ្ជូន | 270.5 | 263.8 | 130.0 | 177.4 | 200.9 | 1,042.6 |
| កសិកម្ម | 143.2 | 107.9 | 79.1 | 105.2 | 161.9 | 597.3 |
| ថាមពល និងអគ្គិសនី | 44.5 | 48.7 | 133.5 | 80.3 | 132.3 | 439.3 |
| ទឹកស្អាត និងអនាម័យ | 42.8 | 17.5 | 14.9 | 58.2 | 41.5 | 175.0 |

| | | | | | | |
|---|---|---|---|---|---|---|
| អភិវឌ្ឍន៍ជនបទ | 29.1 | 39.8 | 6.2 | 18.6 | 26.6 | 120.3 |
| អប់រំ | 9.1 | 20.4 | 10.7 | 7.5 | 24.0 | 71.7 |
| សេវាកម្មធនាគារ និងធុរកិច្ច | 5.0 | 22.2 | 9.0 | 8.2 | 15.0 | 59.4 |
| នគរូបនីយកម្ម និងការគ្រប់គ្រង | 0.6 | 0.7 | 2.8 | 8.1 | 46.7 | 58.8 |
| សហគមន៍ និងសុខុមាលភាពសង្គម | 20.3 | 27.5 | - | - | - | 47.8 |
| សុខាភិបាល | 9.6 | 0.0 | 7.5 | 6.2 | 10.6 | 33.9 |
| ទេសចរណ៍ | 0.0 | 0.9 | 0.5 | 16.2 | 8.2 | 25.7 |
| ព័ត៌មាន និងទូរគមនាគមន៍ | 8.5 | 4.9 | 12.0 | - | - | 25.3 |
| អភិបាលកិច្ច | - | - | 14.4 | 0.4 | 1.9 | 16.6 |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | - | - | - | 14.6 | 2.0 | 16.6 |
| បរិស្ថាន និងការអភិរក្ស | - | - | - | - | 1.5 | 1.5 |
| ផ្សេងៗ | - | 0.8 | - | 24.9 | - | 25.7 |
| **សរុប** | **583.1** | **555.1** | **420.6** | **525.8** | **672.9** | **2,757.5** |

## *ទម្រង់នៃការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ ២០០៨-២០១៨*

ដោយសារសមាសភាគនៃហិរញ្ញប្បទានមានការប្រែប្រួល ក្នុងចន្លោះឆ្នាំ ២០០៨-២០១៨ ទម្រង់នៃការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍនក៏មានការផ្លាស់ប្តូរផងដែរ ។ ក្នុងរយៈពេលនៃរបាយការណ៍នេះ ដៃគូបានប្រើប្រាស់ទម្រង់ ៤ ក្នុងការផ្តល់ហិរញ្ញប្បទានរបស់ខ្លួន ។ ហិរញ្ញប្បទានសម្រាប់វិនិយោគ និងកិច្ចសហប្រតិបត្តិការបច្ចេកទេសបានក្លាយហិរញ្ញប្បទានច្រើនជាងគេ ដោយសារការគាំទ្រវិស័យហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍសមត្ថភាព សម្រាប់គាំទ្រការកែទម្រង់ និងការផ្តល់សេវាសាធារណៈ ។ ដោយឡែក ជំនួយសង្គ្រោះបន្ទាន់ និងស្បៀងអាហារ ត្រូវបានប្រើប្រាស់សម្រាប់ដោះស្រាយគ្រោះមហន្តរាយ ក្នុងពេលដែលហិរញ្ញប្បទានសម្រាប់ទ្រទ្រង់ថវិកា ត្រូវបានផ្តល់ស្ទើរទាំងស្រុង សម្រាប់គាំទ្រវិស័យអប់រំ ។

គំនូរទី ៣.៣ បង្ហាញថា ចាប់ពីឆ្នាំ ២០០៨ ហិរញ្ញប្បទានសម្រាប់វិនិយោគមានទំហំធំជាងគេ ។ ក្នុងឆ្នាំ ២០១១ ហិរញ្ញប្បទានសម្រាប់វិនិយោគបានបន្តកើនឡើងរហូតដល់ ១ ០០០ លានដុល្លារ ដោយសារការកើនឡើងនៃកម្ចីសម្បទានពីសាធារណរដ្ឋប្រជាមានិតចិន ។

**គំនូរទី ៣.៣ ទម្រង់នៃការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ ២០០៨-២០១៨**




រីឯកិច្ចសហប្រតិបត្តិការបច្ចេកទេសបានរក្សាទំហំនឹងនរ ប្រមាណ ៣២១ លានដុល្លារ ក្នុងមួយឆ្នាំ ។ ទន្ទឹមនឹងនេះ កំណើនកម្ចីសម្បទានក្នុងឆ្នាំ ២០១៧ និងឆ្នាំ ២០១៨ បាននាំឱ្យអនុបាតនៃហិរញ្ញប្បទានសម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេស ធៀបនឹងហិរញ្ញប្ប-

ទានសរុប ធ្លាក់ចុះពី ៣៨% ក្នុងឆ្នាំ ២០១៦ មកត្រឹម ៣៣% ក្នុងឆ្នាំ ២០១៧-២០១៨ ។ គំនូសខ្សែបន្ទាត់ក្រហមក្នុងគំនូរទី ៣.៣ បង្ហាញថា ទំហំហិរញ្ញប្បទានឥតសំណង ធៀបនឹងហិរញ្ញប្បទានសហប្រតិបត្តិការសរុប បានធ្លាក់ចុះពី ៧២% ក្នុងឆ្នាំ ២០០៨ មក ៦១% ក្នុងឆ្នាំ ២០១៧ ។

## *ការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយអាទិភាពជាតិ*

រាជរដ្ឋាភិបាលបានរៀបចំកិច្ចពិគ្រោះយោបល់ជាច្រើនជាមួយដៃគូអភិវឌ្ឍន៍ ក្នុងគោលដៅតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយអាទិភាពជាតិ ។ ជាក់ស្តែង គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.ទ/ក.អ.ក) ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងកិច្ចការសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ បានដឹកនាំ និងសម្របសម្រួលកិច្ចពិគ្រោះយោបល់ទ្វេភាគីជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីតម្រឹមធនធានសហប្រតិបត្តិការ ជាមួយនឹងអាទិភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៤-២០១៨ ។

**គំនូរទី ៣.៤ ការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**




**គំនូរទី៣.៥ ការតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**




គំនូរទី៣.៤ បង្ហាញអំពីតម្រូវការ និងការគាំទ្រហិរញ្ញប្បទានសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ លទ្ធផលបង្ហាញថា ហិរញ្ញប្បទានសហប្រតិបត្តិការ ៦ ៤២០ លានដុល្លារ ត្រូវបានបើកផ្តល់សម្រាប់គាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៤-២០១៨ ដែលត្រូវការធនធានរហូតដល់ ៧ ៩៨០ លានដុល្លារ ។

វិស័យថាមពល, វិស័យកសិកម្ម និងវិស័យដឹកជញ្ជូន បានទទួលធនធានលើសពីតម្រូវការ ៦០%, ៨៦% និង ៣២% (គំនូរទី ៣.៥) ។ រីឯវិស័យដទៃទៀត ដូចជាវិស័យអប់រំបានទទួលហិរញ្ញប្បទានតិចជាងតម្រូវការ ហើយទាមទារឱ្យដៃគូអភិវឌ្ឍន៍គាំទ្របន្ថែម ដើម្បីរួមចំណែកលើកកម្ពស់ការអភិវឌ្ឍសមត្ថភាពជាតិក្នុងកិច្ចការអភិវឌ្ឍន៍ ។

**គំនូរទី ៣.៦ ការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍សម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**




គំនូរទី ៣.៦ បង្ហាញថា ដៃគូក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិកបានបើកផ្តល់ហិរញ្ញប្បទានច្រើនជាងគេប្រមាណ ៤០% នៃហិរញ្ញប្បទានសរុប ក្នុងចន្លោះឆ្នាំ ២០១៤-២០១៨ ។ បន្ទាប់មក គឺដៃគូពហុភាគី ២៣%, ដៃគូទ្វេភាគី ២២% និងអង្គការមិនមែនរដ្ឋាភិបាល ១៦% ។ បើធៀបនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដំណាក់កាលមុន ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍នៃទ្វីបអឺរ៉ុប និងអាមេរិកខាងជើង រក្សាបានទំហំនឹងនរ ។ ទោះបីហិរញ្ញប្បទានរបស់ដៃគូនៃបណ្តាប្រទេសអាស៊ី និងប៉ាស៊ីហ្វិកធ្លាក់ចុះបន្តិច ប៉ុន្តែរក្សាទំហំខ្ពស់ជាងដៃគូដទៃទៀត ។

## ការចូលរួមរបស់ដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសចម្រុះ

ដើម្បីពង្រឹងភាពជាដៃគូដោយផ្តោតលើលទ្ធផល រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារបច្ចេកទេសចម្រុះចំនួន ១៩ ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការក្នុងវិស័យសំខាន់ទាំង ៤ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ក្រុមការងារបច្ចេកទេសចម្រុះ គឺជាយន្តការសម្របសម្រួលការងារជាមួយដៃគូអភិវឌ្ឍន៍ នៅកម្រិតវិស័យ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដើម្បីកំណត់អាទិភាព និងដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តគម្រោង ព្រមទាំងរៀបចំ និងអនុវត្តសូចនាករតាមដានរួមគ្នាតាមវិស័យ ។

**តារាងទី ៣.៤ ការបើកផ្តល់ហិរញ្ញប្បទាន និងសកម្មភាពរបស់ដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសចម្រុះ ឆ្នាំ ២០១៧**

| ក្រុមការងារបច្ចេកទេសចម្រុះ | ការបើកផ្តល់ ឆ្នាំ ២០១៧ (លានដុល្លារ) | ចំនួនដៃគូអភិវឌ្ឍន៍ចូលរួម | ចំនួនគម្រោងសម្របសម្រួលដោយក្រុមការងារ | ចំនួនគម្រោងជាមធ្យម |
|---|---|---|---|---|
| **វិស័យសង្គមកិច្ច** | | | | |
| Health | 124.2 | 14 | 42 | 3.0 |
| HIV/AIDS | 26.1 | 4 | 6 | 4.3 |
| Education | 57.1 | 12 | 29 | 2.0 |
| Food Security and Nutrition | 16.0 | 5 | 8 | 2.0 |

| | | | | |
|---|---|---|---|---|
| Rural Water & Sanitation | 14.2 | 4 | 10 | 1.4 |
| **សរុប** | **237.5** | **39** | **95** | **2.5** |
| **វិស័យសេដ្ឋកិច្ច** | | | | |
| Agricultural and Water | 111.4 | 14 | 58 | 1.9 |
| Fisheries | 4.7 | 4 | 9 | 0.5 |
| Forestry | 10.1 | 6 | 13 | 0.8 |
| Land | 1.3 | 3 | 4 | 0.3 |
| Mine Action | 10.7 | 6 | 8 | 1.3 |
| Private Sector Development | 4.8 | 3 | 3 | 1.6 |
| **សរុប** | **143.0** | **36** | **95** | **1.5** |
| **វិស័យហេដ្ឋារចនាសម្ព័ន្ធ** | | | | |
| Infrastructure Regional Integration | 258.1 | 8 | 54 | 4.8 |
| **សរុប** | **258.1** | **8** | **54** | **4.8** |
| **អន្តរវិស័យ និងរដ្ឋបាល** | | | | |
| Public Administrative Reform | 1.1 | 2 | 2 | 0.5 |
| Public Financial Management | 19.0 | 8 | 14 | 1.4 |
| Decentralisation and Deconcentration | 21.6 | 9 | 16 | 1.4 |
| Gender | 1.9 | 7 | 7 | 0.3 |
| Legal and Judicial Reform | 6.4 | 5 | 6 | 1.1 |
| Partnership and Harmonisation | 0.0 | 1 | 1 | 0.0 |
| Planning and Poverty Reduction | 4.5 | 6 | 6 | 0.8 |
| **សរុប** | **54.6** | **38** | **52** | **1.0** |
| **សរុបធនធានដែលសម្របសម្រួលដោយក្រុមការងារបច្ចេកទេសចម្រុះ** | **693.2** | **121** | **296** | **2.3** |
| **សរុបធនធានដែលមិនស្ថិតក្រោមការសម្របសម្រួលរបស់ក្រុមការងារបច្ចេកទេសចម្រុះ** | 430.2 | 26 | 316 | 1.4 |
| **សរុប** | **1123.4** | **147** | **612** | **1.8** |

តារាងទី ៣.៤ បង្ហាញថា ក្នុងឆ្នាំ ២០១៧ ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់បានសម្របសម្រួលគម្រោងចំនួន ២៩៦ ស្មើនឹង ៦៩៣ លានដុល្លារ ។ ក្រុមការងារបច្ចេកទេសចម្រុះស្តីពីហេដ្ឋារចនាសម្ព័ន្ធ និងសមាហរណកម្មក្នុងតំបន់ បានសម្របសម្រួលធនធានធំជាងក្រុមការងារដទៃ ។ រីឯក្រុមការងារបច្ចេកទេសចម្រុះដែលមានការចូលរួមច្រើនពីដៃគូអភិវឌ្ឍន៍ មានដូចជា ក្រុមការងារវិស័យកសិកម្ម និងទឹក, វិស័យសុខាភិបាល និងវិស័យអប់រំ ដែលមានដៃគូចំនួន ១២-១៤ ចូលរួមគាំទ្រវិស័យនីមួយៗ ។ ក្រុមការងារស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ និងក្រុមការងារស្តីពីការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទទួលបន្ទុកកិច្ចសម្របសម្រួលច្រើនជាងក្រុមការងារដទៃ ដោយគម្រោងដែលក្រុមការងារទាំងនេះសម្របសម្រួលមានទំហំធំ និងមានចំនួនច្រើន ។ ទន្ទឹមនឹងនេះ ជាងពាក់កណ្តាលនៃចំនួនគម្រោងទាំងអស់ (៣១៦/៦១២ គម្រោង) ដែលទទួលធនធានស្មើនឹង ៣០% នៃហិរញ្ញប្បទានសរុប មិនស្ថិតក្រោមការសម្របសម្រួលរបស់ក្រុមការងារជាក់លាក់ណាមួយឡើយ ។ ក្នុងន័យនេះ ការបង្កើតយន្តការសម្របសម្រួល ដែលមិនស្ថិតក្រោមយន្តការក្រុមការងារបច្ចេកទេសចម្រុះ គឺជាការចាំបាច់ដើម្បីសម្របសម្រួលការប្រើប្រាស់ធនធានទាំងនេះ ។

ទិន្នន័យតាមគម្រោងដែលដៃគូអភិវឌ្ឍន៍បានកត់ត្រាក្នុងប្រព័ន្ធទិន្នន័យ គឺជាមូលដ្ឋានសម្រាប់រំលេចអំពីសកម្មភាព និងការគាំទ្ររបស់ពួកគេ ក្នុងក្រុមការងារបច្ចេកទេសចម្រុះនីមួយៗ ។ រាជរដ្ឋាភិបាលទទួលស្គាល់

អំពីកិច្ចប្រឹងប្រែងរបស់ដៃគូអភិវឌ្ឍន៍ ក្នុងការគាំទ្រក្រុមការងារបច្ចេកទេសចម្រុះ និងជួយពង្រឹងភាពជាដៃគូ ទោះបីដៃគូទាំងនោះពុំមានគម្រោង ឬមិនបានផ្តល់ធនធានគាំទ្រជាក់លាក់ក៏ដោយ ។ ជាក់ស្តែង ដៃគូអភិវឌ្ឍន៍ទាំងអស់គឺជាសមាជិកនៃក្រុមការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូ និងសុខដុមនីយកម្ម ប៉ុន្តែមានតែដៃគូអភិវឌ្ឍន៍ ១ និងគម្រោង ១ ប៉ុណ្ណោះ ដែលត្រូវបានកត់ត្រាក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ។ ទន្ទឹមនឹងនេះ អង្គការមិនមែនរដ្ឋាភិបាលជាសមាជិករបស់ក្រុមការងារ ប៉ុន្តែ សកម្មភាព និងការគាំទ្ររបស់ពួកគេ ពុំបានរំលេចក្នុងរបាយការណ៍វិភាគនេះឡើយ ។

## *ភាពទស្សន៍ទាយបាននៃហិរញ្ញប្បទានសហប្រតិបត្តិការ ឆ្នាំ ២០១៦*

ក្នុងគោលដៅលើកកម្ពស់សុក្រឹតភាពនៃការរៀបចំផែនការអភិវឌ្ឍន៍ និងភាពជឿទុកចិត្តនៃធនធានរាជរដ្ឋាភិបាលបានសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីព្យាករណ៍ហិរញ្ញប្បទានដែលពួកគេបានគ្រោងបើកផ្តល់តាមវិស័យនីមួយៗ ។ ក្នុងន័យនេះ គ.ជ.ឧ/ក.អ.ក បានព្យាករណ៍អំពីផែនការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់រយៈពេល ១-៣ ឆ្នាំខាងមុខ ដើម្បីជូនដំណឹងដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ពិនិត្យ និងវិភាជន៍ធនធានទាំងនេះក្នុងថវិកាជាតិប្រចាំឆ្នាំ ។

សូចនាករមួយចំនួនត្រូវបានប្រើប្រាស់ សម្រាប់កំណត់ភាពអាចទស្សន៍ទាយបាននៃហិរញ្ញប្បទានតាមគម្រោងនីមួយៗ ។ ទី១) គម្រោងរបស់ដៃគូអភិវឌ្ឍន៍ត្រូវគាំទ្រវិស័យរបស់រាជរដ្ឋាភិបាល, ទី២) គម្រោងត្រូវបញ្ជាក់អំពីផែនការបើកផ្តល់ធនធានសម្រាប់ឆ្នាំបន្ទាប់ ឬ ៣ ឆ្នាំខាងមុខ ។ អនុបាតនៃភាពអាចទស្សន៍ទាយបាន គឺជាផលធៀបរវាងផែនការបើកផ្តល់ហិរញ្ញប្បទាន និងការបើកផ្តល់ជាក់ស្តែងតាមឆ្នាំនីមួយៗ ។ លទ្ធផលល្អបំផុតនៃភាពទស្សន៍ទាយបាន គឺ ១០០% ខណៈដែលកម្រិតល្មៀងត្រូវស្ថិតក្នុងរង្វង់ ៣០% ធៀបនឹងផែនការបើកផ្តល់ហិរញ្ញប្បទាន ។

គំនូរទី ៣.៧ បង្ហាញអំពីលទ្ធផលជាភាគរយនៃភាពអាចទស្សន៍ទាយបាននូវហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ និងតាមវិស័យ ឆ្នាំ ២០១៦ ។ លទ្ធផលនេះ គឺជាផលធៀបរវាងផែនការបើកផ្តល់ហិរញ្ញប្បទាន ក្នុងឆ្នាំ ២០១៦ ដែលបានកត់ត្រានាថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៥ និងការបើកផ្តល់ជាក់ស្តែងក្នុងឆ្នាំ ២០១៦ ដែលបានកត់ត្រានាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៧ ។

**គំនូរទី ៣.៧ ភាពអាចទស្សន៍ទាយបាននូវហិរញ្ញប្បទានសហប្រតិបត្តិការតាមវិស័យ និងដៃគូអភិវឌ្ឍន៍ ក្នុងឆ្នាំ ២០១៦**



លទ្ធផលបានបង្ហាញថា ភាពអាចទស្សន៍ទាយបាននូវហិរញ្ញប្បទាន ក្នុងឆ្នាំ ២០១៦ អាចជឿទុកចិត្តបាន ដោយសារការបើកផ្តល់ហិរញ្ញប្បទានជាក់ស្តែង បានស្ថិតក្នុងកម្រិតល្មៀង ៣០% ធៀបនឹងផែនការបើកផ្តល់ ។ ក្នុងបណ្តាដៃគូអភិវឌ្ឍន៍, ភាពអាចទស្សន៍ទាយបានរបស់សហគមន៍អឺរ៉ុប, បារាំង និងជប៉ុន មានកម្រិតល្អប្រសើរ ដោយសារអនុបាតនៃការបើកផ្តល់ហិរញ្ញប្បទានជាក់ស្តែង ធៀបនឹងផែនការ បានស្ថិតជិត ១០០% ។ បើពិនិត្យតាមវិស័យវិញ, វិស័យបរិស្ថាន និងការអភិរក្ស មានវឌ្ឍនភាពល្អ ដោយទទួលធនធានជាក់ស្តែង ត្រឹម ៥% ទាបជាងផែនការបើកផ្តល់ ។ រីឯវិស័យដទៃទៀត រួមមានវិស័យដឹកជញ្ជូន, វិស័យអភិវឌ្ឍន៍ជនបទ, វិស័យសហគមន៍ និងសុខុមាលភាពសង្គម ក៏មានវឌ្ឍនភាពល្អផងដែរ ។ ដោយឡែកដៃគូអភិវឌ្ឍន៍ និងវិស័យដែលស្ថិតក្នុងចំណុចខ្ពស់បំផុត និងទាបបំផុតនៃគំនូរទី ៣.៧ បង្ហាញអំពីកង្វះការយកចិត្តទុកដាក់របស់ដៃគូក្នុងការព្យាករណ៍ធនធានរបស់ខ្លួន ។

### *គណនេយ្យភាពទ្វេទិសដោយផ្តោតលើលទ្ធផល*

សូចនាករតាមដានរួមគ្នា ឆ្នាំ ២០១៤-២០១៨ ត្រូវបានរៀបចំ ក្នុងគោលដៅលើកកម្ពស់ការគ្រប់គ្រងដោយផ្តោតលើលទ្ធផល និងគណនេយ្យភាពទ្វេទិសនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ហើយក៏ជាក្របខ័ណ្ឌសម្រាប់កំណត់គោលដៅរយៈពេលវែង ដើម្បីសម្រេចទិសដៅដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ បន្ទាប់ពីបានពិនិត្យឡើងវិញនូវវឌ្ឍនភាពក្នុងការអនុវត្តសូចនាករតាមដានរួមគ្នា ឆ្នាំ ២០១៤-២០១៥ គ.ជ.ន/ក.អ.ក បានស្នើក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ពិនិត្យឡើងវិញ និងកែសម្រួលសូចនាករតាមដានរួមគ្នា ដោយពិនិត្យចំណុចដៅ, សូចនាករ, ទិន្នន័យមូលដ្ឋាន និងគោលដៅ សម្រាប់ឆ្នាំ ២០១៧-២០១៨ ទន្ទឹមនឹងការវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ការធ្វើមូលដ្ឋានីយកម្មនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការពិនិត្យ និងកែសម្រួលគោលនយោបាយតាមវិស័យ ។

នៅក្នុងកិច្ចប្រជុំបណ្តាញក្រុមការងារបច្ចេកទេសចម្រុះ នាថ្ងៃទី ៦-៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ ក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានពិភាក្សាបញ្ហានានាដែលពាក់ព័ន្ធនឹងកិច្ចអភិវឌ្ឍន៍ ទាំងនៅកម្រិតជាតិ និងសកល ព្រមទាំងផ្តល់ធាតុចូលសំខាន់ៗ សម្រាប់លើកកម្ពស់លទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ ទាំងនៅកម្រិតជាតិ និងកម្រិតវិស័យ ពិសេសបានពិភាក្សាលើការធ្វើបច្ចុប្បន្នភាពសូចនាករតាមដានរួមគ្នា ។ ផ្អែកតាមលទ្ធផលនៃកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះបានឯកភាព ក្នុងការធ្វើបច្ចុប្បន្នភាពសូចនាករតាមដានរួមគ្នា ដោយផ្អែកលើ ÷ ក) អាទិភាពគន្លឹះដែលរំលេចក្នុងការវាយតម្លៃពាក់កណ្តាលអាណត្តិនៃការ

អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ខ) សង្គតិភាពជាមួយនឹងអាណត្តិការងារក្រសួង និងស្ថាប័នសាមីនិង គ) បន្ថែមសូចនាករពាក់ព័ន្ធនឹងការអភិវឌ្ឍធនធានមនុស្ស ។

យោងតាមលទ្ធផលទាំងនេះ គ.ជ.ន/ក.អ.ក បានរៀបចំបញ្ជីសូចនាករតាមដានរួមគ្នា សម្រាប់ឆ្នាំ ២០១៧-២០១៨ ដែលត្រូវបានអនុម័តដោយ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃពាក់កណ្តាលអាណត្តិក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ការធ្វើមូលដ្ឋានីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព, ការពិនិត្យឡើងវិញនូវគោលនយោបាយតាមវិស័យ និងគោលនយោបាយអាទិភាពដទៃទៀត ដូចជាគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ។

## ការគាំទ្រតាមរាជធានី-ខេត្ត

កម្ពុជាមានរាជធានី និងខេត្តសរុប ២៥ ដែលមានលក្ខណសម្បត្តិសេដ្ឋកិច្ច, សង្គម, បរិស្ថាន និងប្រជាសាស្ត្រខុសប្លែកពីគ្នា ។ ផ្នែកនេះនឹងវិភាគអំពីការបើកផ្តល់ហិរញ្ញប្បទាន សម្រាប់គាំទ្រការអភិវឌ្ឍតាមបណ្តារាជធានី-ខេត្ត ។

តារាងទី ៣.៥ បង្ហាញថា ក្នុងឆ្នាំ ២០១៧ ខេត្តចំនួន ១០ បានទទួលធនធាន ៧៦% នៃធនធានសរុបទន្ទឹមនឹងធនធានសម្រាប់បណ្តាគម្រោង ដែលមានវិសាលភាពគ្របដណ្តប់ទូទាំងប្រទេស ចំនួន ៣៥% នៃធនធានសរុប ។ រាជធានីភ្នំពេញបានទទួលហិរញ្ញប្បទានច្រើនជាងគេ (១៩០ លានដុល្លារ) ។ បន្ទាប់មក គឺខេត្តសៀមរាប (៨៤ លានដុល្លារ), ខេត្តបន្ទាយមានជ័យ (៧១ លានដុល្លារ) និងខេត្តបាត់ដំបង (៥៦ លានដុល្លារ) ។ លទ្ធផលទាំងនេះមានសង្គតិភាពជាមួយការកើនឡើងនៃហិរញ្ញប្បទានកម្ចីតាមវិស័យមួយចំនួន រួមមាន ÷ ធុរកិច្ច និងធនាគារ, នគរូបនីយកម្ម, ទឹកស្អាត និងអនាម័យ, កសិកម្ម និងពាណិជ្ជកម្ម ។ ខេត្តស្វាយរៀង និងរតនៈគីរី ទទួលធនធានច្រើនជាងឆ្នាំកន្លងមក ដោយសារការគាំទ្រពីដៃគូសំខាន់ៗ រួមមានសាធារណរដ្ឋប្រជាមានិតចិន, ជប៉ុន និងធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ។

**តារាងទី ៣.៥ ការបើកផ្តល់ហិរញ្ញប្បទានតាមរាជធានី-ខេត្ត**

| រាជធានី-ខេត្ត | 2015 | 2016 | 2017 ប៉ាន់ស្មាន | 2018 ព្យាករណ៍ |
|---|---|---|---|---|
| ភ្នំពេញ | 118,589 | 122,647 | 189,344 | 119,211 |
| សៀមរាប | 104,227 | 91,296 | 83,786 | 57,705 |
| បន្ទាយមានជ័យ | 51,860 | 43,858 | 71,458 | 76,598 |
| បាត់ដំបង | 90,274 | 66,301 | 56,728 | 51,375 |
| ស្វាយរៀង | 9,187 | 13,426 | 38,025 | 31,589 |
| កំពង់ធំ | 49,730 | 43,398 | 37,422 | 36,492 |
| ពោធិសាត់ | 31,062 | 23,035 | 36,662 | 51,841 |
| ព្រៃវែង | 42,311 | 29,715 | 36,281 | 23,539 |
| កំពង់ឆ្នាំង | 30,967 | 24,803 | 35,865 | 63,667 |

| | | | | |
|---|---|---|---|---|
| រតនគីរី | 8,230 | 6,446 | 31,021 | 22,043 |
| ទូទាំងប្រទេស | 454,064 | 393,789 | 473,556 | 266,711 |
| ខេត្តផ្សេងទៀត | 360,231 | 355,489 | 244,526 | 272,295 |
| គម្រោងពុំទាន់អនុវត្ត | - | - | 14,233 | 147,246 |
| **សរុប** | **1,350,732** | **1,214,203** | **1,348,907** | **1,220,312** |

**គំនូរទី ៣.៨ ការគាំទ្រតាមរាជធានី- ខេត្ត (ដុល្លារ/ប្រជាជនម្នាក់)**




គំនូរទី ៣.៨ បង្ហាញពីទំហំហិរញ្ញប្បទានដែលប្រជាជនម្នាក់ៗ បានទទួលតាមរាជធានី- ខេត្ត ។ ក្នុងឆ្នាំ ២០១៧ ខេត្តកែបបានទទួលហិរញ្ញប្បទានខ្ពស់ជាងគេ (៣១៨ ដុល្លារ ក្នុងប្រជាជនម្នាក់) និងបន្ទាប់មកគឺខេត្តរតនៈគីរី (១៥៦ ដុល្លារ) និងមណ្ឌលគីរី (១៣៦ ដុល្លារ) ដោយសារ ÷ ក) កម្មីសម្បទានក្នុងវិស័យថាមពល, ទេសចរណ៍ និងដឹកជញ្ជូន និង ខ) ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងវិស័យអភិវឌ្ឍន៍ជនបទ និងបរិស្ថាន ។

## *ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៧*

អង្គការមិនមែនរដ្ឋាភិបាលបានរួមចំណែកក្នុងកិច្ចអភិវឌ្ឍន៍ជាតិ តាមរយៈការកៀរគរធនធាន និងការអនុវត្តការងារ ដែលជួយបំពេញបន្ថែមដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ។ តារាងទី ៣.៦ បង្ហាញថា ក្នុងឆ្នាំ ២០១៤- ២០១៧ ធនធានផ្ទាល់របស់អង្គការមិនមែនរាជរដ្ឋាភិបាល និងធនធានទទួលបានពីដៃគូអភិវឌ្ឍន៍ មានប្រមាណ ៣០០- ៣៥០ លានដុល្លារ ក្នុងមួយឆ្នាំ ក្នុងនោះធនធានប្រមាណ ៨០% នៃហិរញ្ញប្បទានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាល ត្រូវបានបើកផ្ដល់សម្រាប់វិស័យសុខាភិបាល, អប់រំ, សុខុមាលភាពសហគមន៍ និងអភិវឌ្ឍន៍ជនបទ ។

**តារាងទី ៣.៦ ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាល ឆ្នាំ ២០១៤- ២០១៧ (លានដុល្លារ)**

| វិស័យ | 2014 | | | 2015 | | | 2016 | | | 2017 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | NGO Own | DPs | Total | NGO Own | DPs | Total | NGO Own | DPs | Total | NGO Own | DPs | Total |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| សុខាភិបាល | 79.0 | 29.0 | 108.0 | 78.1 | 30.7 | 108.9 | 73.6 | 38.4 | 112.0 | 75.4 | 35.8 | 111.1 |
| អប់រំ | 54.8 | 8.5 | 63.3 | 47.5 | 10.7 | 58.2 | 59.6 | 8.8 | 68.4 | 52.1 | 7.8 | 60.0 |
| សុខុមាលភាពសង្គម | 47.7 | 11.7 | 59.4 | 64.5 | 8.1 | 72.6 | 60.5 | 8.6 | 69.1 | 42.3 | 4.4 | 46.7 |
| អភិវឌ្ឍន៍ជនបទ | 15.1 | 18.0 | 33.1 | 24.4 | 13.6 | 38.0 | 25.6 | 13.4 | 39.0 | 21.5 | 10.4 | 32.0 |
| ហ៊ីវ/អេដស៍ | 11.6 | 10.4 | 21.9 | 5.6 | 9.7 | 15.3 | 5.5 | 9.9 | 15.4 | 6.1 | 13.8 | 19.9 |
| អភិបាលកិច្ច | 2.9 | 6.3 | 9.3 | 2.2 | 7.2 | 9.4 | 3.3 | 9.1 | 12.4 | 1.7 | 11.2 | 12.9 |
| កសិកម្ម | 7.4 | 7.5 | 14.9 | 7.0 | 7.5 | 14.5 | 12.6 | 6.8 | 19.5 | 8.9 | 3.5 | 12.4 |
| បរិស្ថាន | 6.0 | 6.8 | 12.8 | 4.1 | 9.1 | 13.3 | 6.4 | 9.2 | 15.5 | 1.5 | 2.9 | 4.4 |
| ផ្សេងៗ | 6.3 | 6.8 | 13.2 | 4.2 | 5.2 | 9.4 | 3.3 | 4.5 | 7.8 | 1.7 | 4.9 | 6.6 |
| **សរុប** | **230.7** | **105.1** | **335.8** | **237.7** | **101.9** | **339.6** | **250.3** | **108.7** | **359.0** | **211.3** | **94.6** | **305.9** |

**គំនូរទី ៣.៩ ការគាំទ្រតាមវិស័យរបស់អង្គការមិនមែនរដ្ឋាភិបាល (លានដុល្លារ)**




**គំនូរទី ៣.១០ ភាគរយនៃធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ ឆ្នាំ ២០១៤-២០១៧**




ដោយសារការធ្លាក់ចុះនៃធនធានផ្ទាល់របស់អង្គការ និងធនធានទទួលពីដៃគូអភិវឌ្ឍន៍ ។ ក្នុងបណ្ដាវិស័យសំខាន់ទាំង ៤, ធនធានសម្រាប់វិស័យសុខុមាលភាពសហគមន៍ បានចាប់ផ្ដើមធ្លាក់ចុះ ដោយសារការធ្លាក់ចុះនៃធនធានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាល ចំនួន ១៨ លានដុល្លារ និងការធ្លាក់ចុះនៃធនធានដែលទទួលពីដៃគូអភិវឌ្ឍន៍ ចំនួន ៤ លានដុល្លារ ធៀបនឹងឆ្នាំ ២០១៦ ។

គំនូរទី ៣.៩ បង្ហាញអំពីការបើកផ្ដល់ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ គិតទាំងធនធានផ្ទាល់ និងធនធានទទួលពីដៃគូអភិវឌ្ឍន៍ ក្នុងឆ្នាំ ២០១៧ ។ ធនធានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាលភាគច្រើន ត្រូវបានប្រើប្រាស់ក្នុងវិស័យសុខាភិបាល, អប់រំ, អភិវឌ្ឍន៍ជនបទ, សុខុមាលភាពសហគមន៍ និងកសិកម្ម ។ ទន្ទឹមនឹងនេះ ធនធានដែលទទួលពីដៃគូអភិវឌ្ឍន៍ ត្រូវបានប្រើប្រាស់សម្រាប់វិស័យអភិបាលកិច្ច, សុខាភិបាល និងហ៊ីវ/អេដស៍ ។ គំនូរទី ៣.១០ បានបញ្ជាក់បន្ថែមពីទំហំធនធានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាល គិតជាមធ្យម ក្នុងចន្លោះឆ្នាំ ២០១៤-២០១៧ ។

**តារាងទី ៣.៧ ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗ ឆ្នាំ ២០១៥-២០១៧ (លានដុល្លារ)**

| ឈ្មោះអង្គការមិនមែនរដ្ឋាភិបាល | 2015 | | | 2016 | | | 2017 | | |
|---|---|---|---|---|---|---|---|---|---|
| | NGO Own | DPs | Total | NGO Own | DPs | Total | NGO Own | DPs | Total |
| Foundation Children's Hospital Kantha Bopha | 33.3 | 4.2 | 37.5 | 30.2 | 6.3 | 36.5 | 32.2 | 4.3 | 36.5 |
| World Vision Cambodia | 24.0 | 2.9 | 26.9 | 27.3 | 2.8 | 30.1 | 25.4 | 1.3 | 26.7 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| Save the Children International | 2.6 | 4.1 | 6.7 | 3.0 | 7.1 | 10.0 | 1.7 | 11.0 | 12.7 |
| Plan International | 2.4 | 8.4 | 10.8 | 4.1 | 7.3 | 11.3 | 4.6 | 7.3 | 11.9 |
| University Research Co., LLC | - | 5.8 | 5.8 | - | 8.7 | 8.7 | - | 9.8 | 9.8 |
| Khmer HIV/AIDS NGO Alliance | - | 7.4 | 7.4 | - | 7.0 | 7.0 | - | 8.0 | 8.0 |
| Cambodian Children's Fund | 5.8 | - | 5.8 | 8.1 | - | 8.1 | 7.1 | - | 7.1 |
| Reproductive Health Association of Cambodia | 0.7 | 2.0 | 2.7 | 0.7 | 0.9 | 1.6 | 5.4 | 0.4 | 5.8 |
| Angkor Hospital for Children | 5.2 | 0.0 | 5.2 | 5.8 | - | 5.8 | 5.5 | - | 5.5 |
| Hazardous Area Life Support Organisation Trust | 0.1 | 4.5 | 4.6 | 0.1 | 4.2 | 4.2 | 0.1 | 4.8 | 4.8 |
| Sos Children's Villages of Cambodia | 2.4 | - | 2.4 | 2.8 | - | 2.8 | 4.7 | - | 4.7 |
| Japan Relief for Cambodia and World Assistance for Cambodia | 4.9 | 0.3 | 5.2 | 4.8 | 0.3 | 5.2 | 4.0 | 0.3 | 4.3 |
| Population Services International | 0.0 | 0.2 | 0.3 | 4.6 | 1.5 | 6.1 | 4.1 | 0.0 | 4.1 |
| Room to Read | 3.1 | - | 3.1 | 3.6 | - | 3.6 | 4.0 | - | 4.0 |
| SNV Netherlands Development Organization | 1.5 | 3.4 | 4.8 | 0.5 | 3.6 | 4.1 | 0.4 | 3.6 | 4.0 |
| Pour un Sourire d'Enfant | 7.2 | - | 7.2 | 7.4 | - | 7.4 | 4.0 | - | 4.0 |
| Winrock Cambodia | - | 6.2 | 6.2 | - | 7.9 | 7.9 | - | 3.9 | 3.9 |
| International Development Enterprises Cambodia | 1.1 | 2.2 | 3.3 | 1.2 | 2.5 | 3.7 | 3.3 | 0.4 | 3.8 |
| Reproductive and Child Health Alliance | 0.2 | 1.3 | 1.5 | - | 3.2 | 3.2 | - | 3.6 | 3.6 |
| Maries Stopes International Cambodia | 0.6 | 1.7 | 2.3 | 0.5 | 2.0 | 2.5 | 1.2 | 2.2 | 3.4 |
| Aide et Action, South-East Asia | - | - | - | 3.4 | 0.0 | 3.4 | 3.3 | - | 3.3 |
| Missionaries of Charity | 0.4 | - | 0.4 | 0.4 | - | 0.4 | 3.3 | - | 3.3 |
| Mines Advisory Group | 1.4 | 0.8 | 2.2 | 1.4 | 1.1 | 2.5 | 1.5 | 1.4 | 2.9 |
| Family Health International | - | - | - | - | - | - | - | 2.8 | 2.8 |
| Asian Hope Cambodia | 2.4 | - | 2.4 | 2.5 | - | 2.5 | 2.7 | - | 2.7 |
| **NGOs ធំៗទាំង ២៥** | **99.3** | **55.4** | **154.7** | **112.1** | **66.4** | **178.4** | **118.6** | **65.2** | **183.8** |
| **NGOs ៤៣៥ ផ្សេងទៀត** | **138.4** | **46.6** | **184.9** | **138.2** | **42.3** | **180.6** | **92.7** | **29.4** | **122.1** |
| **សរុបរួម** | **237.7** | **101.9** | **339.6** | **250.3** | **108.7** | **359.0** | **211.3** | **94.6** | **305.9** |

តារាងទី ៣.៧ បង្ហាញថា ក្នុងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៤៦០ ដែលបានផ្តល់របាយការណ៍មក គ.ជ.ន/ក.អ.ក ក្នុងឆ្នាំ ២០១៧, អង្គការសំខាន់ ២៥ បានផ្តល់ធនធាន ១៨៤ លានដុល្លារ ស្មើនឹង ៦០% នៃធនធានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាល ។ ក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយ ២០១៥-២០១៧ អង្គការមិនមែនរដ្ឋាភិបាលសំខាន់ ៣ គឺ÷ មូលនិធិគន្ធបុប្ផាបានផ្តល់ធនធាន ៣៧ លានដុល្លារ ក្នុងមួយឆ្នាំ ស្មើនឹង ១១% នៃធនធានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាល ។ អង្គការទស្សនៈពិភពលោកបានបើកផ្តល់ធនធាន ២៨ លានដុល្លារ ក្នុងមួយឆ្នាំ ស្មើនឹង ៨% នៃធនធានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាល ។ រីឯអង្គការផ្លែនអន្តរជាតិបានបើកផ្តល់ហិរញ្ញប្បទាន ១១ លានដុល្លារ ក្នុងមួយឆ្នាំ ស្មើនឹង ៣% នៃធនធានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាល ។

## ជំពូក ៤
## ស្ថានភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្នុងអន្តរវិស័យ

កំណើនសេដ្ឋកិច្ចខ្ពស់ក្នុងទសវត្សរ៍កន្លងមក បាននាំឱ្យមានការប្រែប្រួលខាងរចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ចកម្ពុជា ដែលធ្វើឱ្យមានការផ្លាស់ប្ដូររបៀបរស់នៅរបស់ប្រជាជន, ការរួមរស់សុខដុមរមនាក្នុងសង្គមជាតិ និងការទាញយកផលប្រយោជន៍ពីបរិស្ថានធម្មជាតិ ។ ដោយសារការអភិវឌ្ឍមានលក្ខណៈពហុវិស័យ រាជរដ្ឋាភិបាលស្វាគមន៍ចំពោះកិច្ចប្រឹងប្រែងនានាដែលនាំទៅដល់ការប្រែប្រួលជាវិជ្ជមាន ។ ក្នុងស្មារតីនេះ ដោយមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ រាជរដ្ឋាភិបាលបានរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងគោលដៅតម្រង់ទិសកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព និងប្រឹងប្រែងដោះស្រាយការជះឥទ្ធិពលអវិជ្ជមាន ដែលបង្កឡើងដោយការប្រែប្រួលនេះ ដើម្បីឆ្លើយតបនឹងសេចក្ដីត្រូវការរបស់ប្រជាជន ។ លើមូលដ្ឋាននេះ ដោយសារចរិតអន្តរវិស័យ គម្រោងនីមួយៗអាចមានគោលដៅច្រើនសម្រាប់គាំទ្រដល់កិច្ចអភិវឌ្ឍន៍ ។

ការបង្កើនចំណេះដឹងស្ដីពីការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ នឹងលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានទាំងនេះ ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលបានរៀបចំប្រព័ន្ធទិន្នន័យស្ដីពីហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីគាំទ្រការរៀបចំផែនការ, ការសម្របសម្រួល, ការតាមដាន និងវាយតម្លៃ ព្រមទាំងលើកកម្ពស់តម្លាភាពនៃការប្រើប្រាស់ធនធាន ។ ចំពោះគម្រោងអន្តរវិស័យ ដៃគូអភិវឌ្ឍន៍អាចផ្ដល់ព័ត៌មានពីការគាំទ្ររបស់ខ្លួនក្នុង «វិស័យគោល» និង «វិស័យសម្គាល់បន្ថែម» តាមរយៈកម្រងសំណួរក្នុងប្រព័ន្ធទិន្នន័យស្ដីពីហិរញ្ញប្បទានសហប្រតិបត្តិការ ទោះបីគម្រោងនោះមិនគាំទ្រផ្ទាល់ដល់វិស័យជាក់លាក់ក៏ដោយ ។

ការចូលរួមរបស់គម្រោងនីមួយៗ អាចមិនមែនជាការផ្ដល់ធនធានហិរញ្ញវត្ថុឡើយ ។ ក្នុងវិស័យយេនឌ័រ ការបញ្ជ្រាបសមភាពយេនឌ័រទៅក្នុងគម្រោងត្រូវបានចាត់ទុកជាឧត្តមានុវត្តន៍ ។ ការបញ្ជ្រាបសមភាពយេនឌ័រក្នុងគម្រោងអភិវឌ្ឍន៍បានជួយគាំទ្រដល់សមភាពយេនឌ័រ ទោះបីជាវិស័យគោលដែលគម្រោងគាំទ្រមិនមែនវិស័យយេនឌ័រក៏ដោយ ។

វិស័យសម្គាល់បន្ថែម គឺជាជម្រើសដែលអាចទទួលយកបានសម្រាប់គម្រោងអភិវឌ្ឍន៍ទាំងឡាយដែលមានចរិតអន្តរវិស័យ និងមានគោលដៅគាំទ្រដល់វិស័យជាច្រើន បន្ថែមពីលើវិស័យគោលរបស់ខ្លួន ។ ទោះជាយ៉ាងនេះក្ដី ក៏ឧត្តមានុវត្តន៍នេះពុំអាចកំណត់ជាក់ស្ដែងអំពីការបែងចែកធនធានសម្រាប់គាំទ្រវិស័យទាំងនោះបានឡើយ ។ ដូច្នេះ ដើម្បីដោះស្រាយចំណុចខ្វះខាតខាងលើ ជំពូកនៃរបាយការណ៍នេះបានផ្អែកលើទិន្នន័យដែលដៃគូអភិវឌ្ឍន៍បាន ÷ ក) កំណត់គោលដៅបន្ថែមរបស់គម្រោង ដែលមិនមែនវិស័យគោល, ខ) កំណត់កម្រិតនៃការគាំទ្រពីទាបទៅមធ្យម និងខ្ពស់ ។ ការចាត់ថ្នាក់បែបនេះ គឺដើម្បីវាស់ស្ទង់អំពីកម្រិតនៃការគាំទ្រ

នៃគម្រោងនីមួយៗរបស់ដៃគូអភិវឌ្ឍន៍ដែលមានគោលដៅច្រើន តាមវិស័យសម្គាល់បន្ថែម ក្នុងពេលរៀបចំ និងអនុវត្តគម្រោង ។

ចាប់ពីឆ្នាំ ២០១៥ វិស័យសម្គាល់បន្ថែមត្រូវបានរៀបចំចំនួន ១៨ ក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ (តារាងទី ៤.១) ។ ជំពូកនេះវិភាគអំពីទំហំធនធានក្នុងវិស័យសម្គាល់បន្ថែម ៣ (សមភាពយេនឌ័រ, ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍវិស័យឯកជន) ហើយបានវិភាគអំពីការប្តេជ្ញារបស់រាជរដ្ឋាភិបាល ក្នុងការសម្របសម្រួលការងារដែលមានចរិតអន្តរវិស័យទាំងនេះ ។

**តារាងទី ៤.១: វិស័យសម្គាល់បន្ថែម**

| | |
|---|---|
| ការអភិវឌ្ឍ និងការពង្រឹងសមត្ថភាព និងប្រព័ន្ធរបស់រាជរដ្ឋាភិបាល | ការគាំទ្រការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ការគាំទ្រការអនុវត្តការកែទម្រង់ការគ្រប់គ្រងរដ្ឋបាលសាធារណៈ | ការគាំទ្រការអនុវត្តការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ |
| ការគាំទ្រការអនុវត្តការកែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ | សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី |
| ការការពារបរិស្ថាន (មិនរាប់បញ្ចូលការប្រែប្រួលអាកាសធាតុ) | ការប្រែប្រួលអាកាសធាតុ |
| ហ៊ីវ/អេដស៍ (ការយល់ដឹង, ការការពារ និងការព្យាបាល) | គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា |
| ការបង្កើតប្រាក់ចំណូល និងការងារ | ការអភិវឌ្ឍវិស័យឯកជន |
| កិច្ចសហប្រតិបត្តិការត្បូង-ត្បូង និងកិច្ចសហប្រតិបត្តិការត្រីកោណ | គម្រោងអភិវឌ្ឍន៍សហគមន៍ |
| ការចូលរួមរបស់សង្គមស៊ីវិល ឬ តួអង្គមិនមែនរដ្ឋ | សន្តិសុខស្បៀង |
| ការគាំពារសង្គម | ការគាំទ្រ និងការអភិវឌ្ឍយុវជន |

## *ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់លើកកម្ពស់សមភាពយេនឌ័រ*

យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលបានទទួលស្គាល់សមភាពយេនឌ័រជាគន្លឹះក្នុងការអភិវឌ្ឍជាតិ និងធនធានមនុស្ស ។ រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ និងគោលនយោបាយជាច្រើន ដើម្បីលើកកម្ពស់សមភាពយេនឌ័រនៅកម្ពុជា ។ ជាក់ស្តែង ក្រសួងកិច្ចការនារីកំពុងអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី ៤ តាមអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ជំនួសការអនុវត្តតាមគម្រោងនីមួយៗ ដើម្បីបញ្ជ្រាបសមភាពយេនឌ័រតាមក្រសួង និងស្ថាប័នពាក់ព័ន្ធ តាមរយៈការផ្តល់ប្រឹក្សា, ការគាំទ្របច្ចេកទេស, ការតស៊ូមតិ និងការត្រួតពិនិត្យ ។

ក្នុងឆ្នាំ ២០១៧ ហិរញ្ញប្បទានសហប្រតិបត្តិការសរុប (គិតទាំងធនធានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាល) ដែលបានគាំទ្រវិស័យគោលយេនឌ័រ មានទំហំ ៣,៨ លានដុល្លារ ស្មើនឹង ០,២៥% នៃធនធានសរុប ។ តារាងទី ៤.២ បង្ហាញថា ហិរញ្ញប្បទានសម្រាប់បញ្ជ្រាបយេនឌ័រមានប្រមាណជាង ៣៧៤ លានដុល្លារ ស្មើនឹង ២៥% នៃហិរញ្ញប្បទានសរុប ពោលគឺកើន ១៧% ធៀបនឹងឆ្នាំ ២០១៦ ដោយសារការកើនឡើងនៃធនធានសម្រាប់បញ្ជ្រាបយេនឌ័រក្នុងវិស័យទឹកស្អាត និងអនាម័យ ប្រមាណ ៤១ លានដុល្លារ និងវិស័យកសិកម្ម ប្រមាណ ២១ លានដុល្លារ ។

វិស័យកសិកម្ម, សុខាភិបាល និងអភិបាលកិច្ច គឺជាវិស័យនាំមុខដែលទទួលធនធានច្រើនជាងគេ ប្រមាណជាង ១៧៦ លានដុល្លារ សម្រាប់បញ្ជ្រាបយេនឌ័រ ។ វិស័យសុខាភិបាល និងអប់រំ ដែលជាវិស័យដែលបញ្ជ្រាបយេនឌ័របានជោគជ័យក្នុងកម្រិតខ្ពស់ ទទួលធនធានសរុបប្រមាណជាង ២៦ លានដុល្លារ ។ រីឯ វិស័យនគរូបនីយកម្ម, ការប្រែប្រួលអាកាសធាតុ, ទឹកស្អាត និងអនាម័យ, និងអភិបាលកិច្ច ទទួលធនធានប្រមាណជាង ៥០% នៃធនធានសរុបសម្រាប់វិស័យនីមួយៗ ។

**តារាងទី ៤.២ : ការបញ្ជ្រាបសមភាពយេនឌ័រតាមវិស័យ ឆ្នាំ ២០១៦-២០១៧ (លានដុល្លារ)**

| វិស័យ | ២០១៦ (សរុប) | ២០១៧ | | | | ធនធានតាមវិស័យ ឆ្នាំ ២០១៧ | យេនឌ័រ (គិតជា % នៃធនធាន) |
|---|---|---|---|---|---|---|---|
| | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |
| នគរូបនីយកម្ម និងការគ្រប់គ្រង | 4.9 | 10.1 | 1.6 | - | **11.6** | **12.1** | **96%** |
| ការប្រែប្រួលអាកាសធាតុ | 3.6 | 4.6 | 3.5 | - | **8.1** | **11.3** | **72%** |
| ទឹកស្អាត និងអនាម័យ | 4.9 | 39.9 | 6.1 | - | **46.0** | **75.7** | **61%** |
| អភិបាលកិច្ច និងរដ្ឋបាល | 55.8 | 16.5 | 27.4 | 6.4 | **50.3** | **83.1** | **61%** |
| កសិកម្ម | 52.2 | 32.8 | 35.0 | 5.3 | **73.1** | **181.7** | **40%** |
| ការអភិវឌ្ឍជនបទ | 20.2 | 11.3 | 11.9 | 3.3 | **26.4** | **74.8** | **35%** |
| អប់រំ | 70.7 | 5.9 | 33.4 | 6.6 | **45.9** | **148.2** | **31%** |
| សេវាធុរកិច្ច និងហិរញ្ញវត្ថុ | 4.9 | 1.0 | 0.2 | 3.0 | **4.3** | **14.8** | **29%** |
| ទេសចរណ៍ | 1.1 | - | 4.6 | - | **4.6** | **17.2** | **27%** |
| ផ្សេងៗ | 3.3 | 1.4 | 14.1 | 1.8 | **17.4** | **67.5** | **26%** |
| សុខាភិបាល | 68.0 | 7.3 | 25.8 | 20.0 | **53.0** | **213.8** | **25%** |
| បរិស្ថាន និងចីរភាព | 5.3 | 3.4 | 1.0 | - | **4.3** | **19.0** | **23%** |
| សហគមន៍ និងសុខុមាលភាពសង្គម | 8.9 | 0.5 | 7.8 | - | **8.3** | **53.9** | **15%** |
| វប្បធម៌ សិល្បៈ និងកីឡា | 0.3 | - | 0.5 | - | **0.5** | **4.6** | **10%** |
| ហ៊ីវ/អេដស៍ | 5.6 | 2.7 | 0.1 | - | **2.8** | **32.2** | **9%** |
| ឧស្សាហកម្ម និងពាណិជ្ជកម្ម | 1.6 | - | 1.3 | - | **1.3** | **18.3** | **7%** |
| ការដឹកជញ្ជូន | 6.7 | 11.7 | 1.0 | - | **12.7** | **216.6** | **6%** |
| ថាមពល និងអគ្គិសនី | 1.7 | 3.4 | - | - | **3.4** | **88.6** | **4%** |
| ជំនួយសង្គ្រោះបន្ទាន់ និងស្បៀងអាហារ | 0.2 | - | - | - | **-** | **0.3** | **0%** |
| បច្ចេកវិទ្យា, ព័ត៌មានវិទ្យា និងទំនាក់ទំនង | - | - | - | - | **-** | **0.9** | **0%** |
| **សរុប (មិនរាប់បញ្ចូលគម្រោងដែលគ្រោងអនុវត្ត)** | **320.0** | **152.6** | **175.2** | **46.5** | **374.2** | **1334.7** | **28%** |

*<u>កំណត់សម្គាល់</u>: ហិរញ្ញប្បទានសរុបសម្រាប់គាំទ្រវិស័យគោលយេនឌ័រ ឆ្នាំ ២០១៧ មាន ៣,៨ លានដុល្លារ*

ដៃគូអភិវឌ្ឍន៍ភាគច្រើនបានគិតគូរបញ្ជ្រាបយេនឌ័រក្នុងគម្រោងរបស់ខ្លួន ។ តារាងទី ៤.៣ បង្ហាញថា កម្មវិធីស្បៀងអាហារពិភពលោក, អង្គការសុខភាពពិភពលោក និងអូស្រ្តាលី បានបញ្ជ្រាបយេនឌ័រទៅក្នុងគម្រោងរបស់ខ្លួន (១០០%) ។ ដៃគូអភិវឌ្ឍន៍ ៨ ទៀតបានប្រើប្រាស់ធនធានជាង ៣/៤ សម្រាប់គាំទ្រការបញ្ជ្រាបយេនឌ័រ ។

**តារាងទី ៤.៣: ការបញ្ជ្រាបសមភាពយេនឌ័ររបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ ២០១៦-២០១៧ (លានដុល្លារ)**

| ដៃគូអភិវឌ្ឍន៍ | ២០១៦ | ២០១៧ | | | | ធនធានរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ ២០១៧ | យេនឌ័រ (គិតជា %នៃធនធានរបស់ដៃគូអភិវឌ្ឍន៍) |
|---|---|---|---|---|---|---|---|
| | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |
| WFP | 16.4 | - | 14.1 | 3.3 | **17.3** | **17.3** | **100%** |
| WHO | 9.5 | - | 1.5 | 8.0 | **9.5** | **9.5** | **100%** |
| Australia | 49.2 | 27.4 | 11.7 | 17.1 | **56.2** | **56.3** | **100%** |
| Switzerland | 15.6 | 2.0 | 11.3 | 0.2 | **13.5** | **13.8** | **97%** |
| UNFPA | 3.4 | - | 2.4 | 0.1 | **2.5** | **2.6** | **97%** |
| ILO | 2.9 | - | 3.2 | 0.2 | **3.4** | **3.7** | **91%** |
| Germany | 41.6 | 3.1 | 27.6 | - | **30.7** | **36.5** | **84%** |
| UNDP | 4.7 | 1.6 | 4.2 | 0.4 | **6.2** | **7.4** | **83%** |
| UN Women | 1.1 | - | - | 0.3 | **0.3** | **0.5** | **74%** |
| World Bank | 16.6 | 2.6 | 24.9 | - | **27.5** | **39.7** | **69%** |
| Sweden | 18.7 | 7.6 | 1.4 | 4.5 | **13.5** | **20.3** | **66%** |
| New Zealand | 2.3 | - | 0.7 | 2.3 | **2.9** | **5.3** | **56%** |
| ADB | 55.0 | 46.2 | 27.4 | - | **73.6** | **146.0** | **50%** |
| FAO | 0.4 | - | 2.2 | 0.1 | **2.3** | **4.8** | **48%** |
| IFAD | 12.1 | 2.0 | 0.9 | 4.0 | **6.9** | **14.7** | **47%** |
| USA | 23.8 | 15.3 | 15.6 | 4.4 | **35.3** | **76.0** | **46%** |
| EU/EC | 29.1 | 5.5 | 18.0 | 0.4 | **24.0** | **59.8** | **40%** |
| UNICEF | 2.8 | 1.7 | 3.4 | - | **5.1** | **12.8** | **40%** |
| France | 2.9 | 33.2 | 2.9 | 0.4 | **36.5** | **103.3** | **35%** |
| Czech Republic | 0.4 | - | 0.2 | 0.1 | **0.3** | **1.2** | **26%** |
| Canada | 0.5 | 0.0 | 0.2 | 0.1 | **0.3** | **1.6** | **19%** |
| UK | 0.2 | 0.4 | 0.0 | - | **0.4** | **2.3** | **16%** |
| Japan | 4.4 | 3.9 | - | 0.7 | **4.6** | **126.4** | **4%** |
| Republic of Korea | 6.4 | 0.0 | 1.4 | - | **1.4** | **51.2** | **3%** |
| Others | - | - | - | - | **-** | **310.4** | **0%** |
| **សរុប (មិនរាប់បញ្ចូលគម្រោងដែលគ្រោងអនុវត្ត)** | **319.8** | **152.6** | **175.2** | **46.5** | **374.2** | **1334.7** | **28%** |

## *ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការប្រែប្រួលអាកាសធាតុ*

ការប្រែប្រួលអាកាសធាតុបានក្លាយជាកង្វល់របស់សកលលោក ដោយសារនេះគឺជាគោលដៅនៃរបៀបវារៈស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព ។ តាមការធ្វើបច្ចុប្បន្នភាពនៃមូលនិធិសម្រាប់ការប្រែប្រួលអាកាសធាតុ, ហិរញ្ញប្បទានសម្រាប់ការប្រែប្រួលអាកាសធាតុត្រូវបានផ្តល់តាមរយៈយន្តការពហុភាគី ដូចជាយន្តការសម្របសម្រួលបរិស្ថានសកល និងមូលនិធិសម្រាប់វិនិយោគលើអាកាសធាតុ ក៏ដូចជាតាមរយៈយន្តការទ្វេភាគី ទន្ទឹមនឹងការកើនឡើងនៃចំនួនប្រទេសទទួលហិរញ្ញប្បទាន ។ ក្នុងស្មារតីនេះ អនុសញ្ញា

ក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ គឺជាក្របខ័ណ្ឌដើម្បីបង្កើតយន្តការហិរញ្ញប្បទានសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ដែលទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ។

**តារាងទី ៤.៤: ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុតាមវិស័យ ឆ្នាំ ២០១៦-២០១៧ (លានដុល្លារ)**

| វិស័យ | ២០១៦ (សរុប) | ២០១៧ | | | | ធនធានតាមវិស័យ ឆ្នាំ ២០១៧ | ការប្រែប្រួលអាកាសធាតុ (គិតជា %នៃធនធានតាមវិស័យ) |
|---|---|---|---|---|---|---|---|
| | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |
| នគរូបនីយកម្ម និងការគ្រប់គ្រង | 2.3 | 0.2 | 9.5 | - | **9.7** | **12.1** | **80%** |
| បរិស្ថាន និងចីរភាព | 17.1 | 0.3 | 10.0 | 4.8 | **15.2** | **19.0** | **80%** |
| ជំនួយសង្គ្រោះបន្ទាន់ និងស្បៀងអាហារ | 0.8 | 0.2 | - | - | **0.2** | **0.3** | **61%** |
| កសិកម្ម | 62.5 | 37.4 | 63.5 | 6.9 | **107.8** | **181.7** | **59%** |
| ការដឹកជញ្ជូន | 31.9 | 37.1 | 23.9 | 2.7 | **63.8** | **216.6** | **29%** |
| ការអភិវឌ្ឍជនបទ | 9.9 | 4.2 | 5.8 | 9.6 | **19.6** | **74.8** | **26%** |
| សេវាធុរកិច្ច និងហិរញ្ញវត្ថុ | - | - | 3.3 | - | **3.3** | **14.8** | **22%** |
| អប់រំ | 33.1 | - | 26.9 | - | **26.9** | **148.2** | **18%** |
| យេនឌ័រ | 0.7 | 0.5 | - | - | **0.5** | **3.8** | **13%** |
| សុខាភិបាល | 13.0 | 13.6 | 6.2 | 8.0 | **27.8** | **213.8** | **13%** |
| ថាមពល និងអគ្គិសនី | 93.5 | 10.7 | 0.2 | - | **10.9** | **88.6** | **12%** |
| ផ្សេងៗ | 2.4 | 0.3 | 9.7 | 2.9 | **12.9** | **143.7** | **9%** |
| អភិបាលកិច្ច និងរដ្ឋបាល | 4.5 | 2.9 | 0.6 | 2.2 | **5.7** | **83.1** | **7%** |
| វប្បធម៌សិល្បៈ និងកីឡា | 0.2 | - | 0.2 | - | **0.2** | **4.6** | **4%** |
| ទឹកស្អាត និងអនាម័យ | 0.1 | 1.0 | 0.3 | - | **1.3** | **75.7** | **2%** |
| សហគមន៍ និងសុខុមាលភាពសង្គម | 0.4 | - | 0.3 | - | **0.3** | **53.9** | **1%** |
| **សរុប (មិនរាប់បញ្ចូលគម្រោងត្រៀមអនុវត្ត)** | **272.5** | **108.4** | **160.5** | **37.1** | **306.1** | **1334.7** | **23%** |

ក្នុងបរិការណ៍ថ្មីនេះ កម្ពុជាត្រូវបានចាត់ទុកជាប្រទេសងាយរងគ្រោះដោយការប្រែប្រួលអាកាសធាតុ ដោយសារទំហំខូចខាតក្នុងមួយឆ្នាំអាចកើនដល់ ១,៥% នៃផលិតផលក្នុងស្រុកសរុប នាឆ្នាំ ២០៣០ និង ៣,៥% នាឆ្នាំ ២០៥០ ។ រាជរដ្ឋាភិបាលបានអនុម័តផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ ២០១៤-២០២៣ ដើម្បីឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា ។ រាជរដ្ឋាភិបាលក៏បានរៀបចំក្របខ័ណ្ឌហិរញ្ញប្បទានសម្រាប់ការប្រែប្រួលអាកាសធាតុ និងយន្តការសម្របសម្រួល ដែលស្ថិតនៅក្រោម

ការគ្រប់គ្រងរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ខណៈដែលក្រសួងបរិស្ថានគឺជាស្ថាប័នទទួលបន្ទុកការគ្រប់គ្រងមូលនិធិបន្សាំ, មូលនិធិអាកាសធាតុបៃតង និងយន្តការសម្របសម្រួលបរិស្ថានសកល ។

គ.ជ.ន/ក.អ.ក ដែលជាចំណុចប្រមូលផ្តុំសម្រាប់កៀរគរ, សម្របសម្រួល និងគ្រប់គ្រងធនធានសហប្រតិបត្តិការ នឹងសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ និងដឹកនាំកិច្ចពិភាក្សាដៃគូអភិវឌ្ឍន៍ ដើម្បីតម្រឹមធនធានសហប្រតិបត្តិការ ជាមួយធនធានសម្រាប់ការប្រែប្រួលអាកាសធាតុនៅកម្ពុជា ។ ក្នុងន័យនេះ ប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការដែលគ្រប់គ្រងដោយ គ.ជ.ន/ក.អ.ក បានកត់ត្រាទិន្នន័យស្តីពីធនធានសម្រាប់ការប្រែប្រួលអាកាសធាតុនៅកម្ពុជា ។

**តារាងទី ៤.៥: ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ ២០១៦-២០១៧ (លានដុល្លារ)**

| ដៃគូអភិវឌ្ឍន៍ | ២០១៦ (សរុប) | ២០១៧ | | | | ធនធានរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ ២០១៧ | ការប្រែប្រួលអាកាសធាតុ (គិតជា% នៃធនធានរបស់ដៃគូអភិវឌ្ឍន៍) |
|---|---|---|---|---|---|---|---|
| | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |
| WFP | 16.4 | - | 14.1 | 3.3 | **17.3** | **17.3** | **100%** |
| WHO | 9.5 | 1.5 | - | 8.0 | **9.5** | **9.5** | **100%** |
| World Bank | 13.1 | 0.5 | 30.3 | 1.0 | **31.8** | **39.7** | **80%** |
| IFAD | 15.5 | - | 4.9 | 6.8 | **11.7** | **14.7** | **80%** |
| UNDP | 3.4 | - | 0.5 | 5.3 | **5.8** | **7.4** | **78%** |
| ADB | 49.2 | 38.1 | 59.9 | 8.1 | **106.1** | **146.0** | **73%** |
| UN Women | 0.7 | 0.3 | - | - | **0.3** | **0.5** | **66%** |
| UNIDO | 0.5 | - | - | 1.2 | **1.2** | **2.1** | **55%** |
| Australia | 13.3 | 12.0 | 18.9 | - | **30.9** | **56.3** | **55%** |
| FAO | 0.1 | - | 1.5 | 1.0 | **2.6** | **4.8** | **54%** |
| Germany | 9.8 | 4.8 | 4.8 | 0.3 | **9.9** | **36.5** | **27%** |
| Czech Republic | 0.3 | 0.1 | 0.2 | - | **0.3** | **1.2** | **23%** |
| Canada | 0.2 | 0.3 | - | - | **0.3** | **1.6** | **21%** |
| USA | 9.9 | 1.3 | 9.5 | 1.7 | **12.5** | **76.0** | **16%** |
| Republic of Korea | 5.1 | 7.5 | - | - | **7.5** | **51.2** | **15%** |
| Japan | 12.7 | 18.1 | - | - | **18.1** | **126.4** | **14%** |
| Sweden | 5.1 | 2.9 | - | - | **2.9** | **20.3** | **14%** |
| EU/EC | 8.8 | 0.4 | 6.9 | 0.5 | **7.8** | **59.8** | **13%** |
| Switzerland | 1.7 | 1.6 | - | - | **1.6** | **13.8** | **12%** |
| France | 4.9 | 0.9 | 9.0 | - | **9.9** | **103.3** | **10%** |
| China | 92.3 | 18.1 | - | - | **18.1** | **223.5** | **8%** |
| Others | - | - | - | - | **-** | **111.4** | **0%** |
| **Total (Exclude Pipeline Projects)** | **272.5** | **108.4** | **160.5** | **37.1** | **306.1** | **1334.7** | **23%** |

ក្នុងឆ្នាំ ២០១៧ ធនធានសរុបសម្រាប់គាំទ្រការប្រែប្រួលអាកាសធាតុ (វិស័យគោល) មាន ១១,៣ លានដុល្លារ កើន ៤០% ធៀបនឹងឆ្នាំ ២០១៦ ។ រីឯការបញ្ជ្រាបការប្រែប្រួលអាកាសធាតុតាមវិស័យសម្គាល់បន្ថែម បានកើន ១២% ធៀបនឹងឆ្នាំ ២០១៦ ដែលមាន ២៧២ លានដុល្លារ ដោយសារកំណើនធនធានសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម ៤៥ លានដុល្លារ, ដឹកជញ្ជូន ៣២ លានដុល្លារ និងសុខាភិបាល ១៥ លានដុល្លារ ។

វិស័យកសិកម្ម និងដឹកជញ្ជូន គឺជាវិស័យចម្បងដែលទទួលធនធានសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ ប្រមាណ ១៧១ លានដុល្លារ ស្មើនឹង ៥៦% នៃធនធានសរុបសម្រាប់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ។ វិស័យដែលទទួលធនធានច្រើនសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុក្នុងកម្រិតខ្ពស់គឺ ÷ វិស័យអភិវឌ្ឍន៍ជនបទ, សុខាភិបាល និងកសិកម្ម ។ បើគិតជាផលធៀបជាមួយនឹងទំហំធនធានតាមវិស័យក្នុងឆ្នាំ ២០១៧ វិស័យនគរូបនីយកម្ម និងការគ្រប់គ្រង, បរិស្ថាន និងចីរភាព, និងជំនួយសង្គ្រោះបន្ទាន់ និងស្បៀងអាហារ គឺជាវិស័យចម្បងដែលបានបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងវិស័យរបស់ខ្លួន ។

តារាងទី ៤.៥ បានបង្ហាញថា កម្មវិធីស្បៀងអាហារពិភពលោក និងអង្គការសុខភាពពិភពលោក បានគាំទ្រការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងបណ្តាគម្រោងរបស់ខ្លួន ១០០% ខណៈពេលដែលធនាគារអភិវឌ្ឍន៍អាស៊ី, ធនាគារពិភពលោក, និងអូស្ត្រាលី ក៏ជាដៃគូអភិវឌ្ឍន៍សំខាន់ ក្នុងការគាំទ្រការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ដែលមានធនធានសរុបជាង ១៦៨ លានដុល្លារ ។

### *ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការអភិវឌ្ឍវិស័យឯកជន*

តារាងទី ៤.៦ បង្ហាញថា ក្នុងឆ្នាំ ២០១៧ ធនធានប្រមាណជាង ៤៦៤ លានដុល្លារ ស្មើនឹង ៣៥% នៃធនធានសរុប ត្រូវបានប្រើប្រាស់សម្រាប់អនុវត្តគម្រោងដែលបានរួមចំណែកដល់ការអភិវឌ្ឍវិស័យឯកជន ។ ធនធាននេះបានកើនប្រមាណ ៤០% បើធៀបឆ្នាំ ២០១៦ ដោយសារការកើនឡើងនៃធនធានសម្រាប់បញ្ជ្រាបការអភិវឌ្ឍវិស័យឯកជនក្នុងវិស័យមួយចំនួន ដូចជាវិស័យកសិកម្ម ៥៤ លានដុល្លារ, វិស័យដឹកជញ្ជូន ៨៦ លានដុល្លារ, និងវិស័យទេសចរណ៍ ១៦ លានដុល្លារ ។ វិស័យដឹកជញ្ជូន, កសិកម្ម, និងថាមពល និងអគ្គិសនី គឺជាវិស័យដែលទទួលធនធានច្រើនជាងគេ (ប្រមាណ ២៨០ លានដុល្លារ) សម្រាប់បញ្ជ្រាបការអភិវឌ្ឍវិស័យឯកជន ក្នុងនោះធនធានសម្រាប់វិស័យដឹកជញ្ជូន មាន ២៦%, វិស័យកសិកម្ម ២៣% និងវិស័យថាមពល និងអគ្គិសនី ១២% នៃធនធានសរុបក្នុងវិស័យសម្គាល់បន្ថែមនីមួយៗ ។

វិស័យដែលទទួលជោគជ័យក្នុងការបញ្ជ្រាបការអភិវឌ្ឍវិស័យឯកជនក្នុងកម្រិតខ្ពស់ រួមមាន ÷ វិស័យកសិកម្ម និងវិស័យថាមពល និងអគ្គិសនី ។ ទន្ទឹមនឹងនេះ ក៏មានវិស័យ ៧ ដែលបានប្រើប្រាស់ធនធានច្រើនជាង ៥០% នៃធនធានសរុបរបស់ខ្លួន សម្រាប់បញ្ជ្រាបការអភិវឌ្ឍវិស័យឯកជន ។ វិស័យទាំងនោះ រួមមានវិស័យទេសចរណ៍ ៩៩% នៃធនធានសរុបរបស់ខ្លួន, វិស័យឧស្សាហូបនីយកម្ម និងពាណិជ្ជកម្ម ៨៩%, វិស័យសេវាធុរកិច្ច និងហិរញ្ញវត្ថុ ៨៦%, វិស័យនគរូបនីយកម្ម ៧៩%, វិស័យថាមពល និងអគ្គិសនី ៦៣%, វិស័យកសិកម្ម ៥៨% និងវិស័យដឹកជញ្ជូន ៥៥% ។

**តារាងទី ៤.៦: ការបញ្ជ្រាបការអភិវឌ្ឍវិស័យឯកជនតាមវិស័យ ឆ្នាំ ២០១៦-២០១៧ (លានដុល្លារ)**

| វិស័យ | ២០១៦ | ២០១៧ | | | | ធនធានតាមវិស័យ ឆ្នាំ ២០១៧ | វិស័យឯកជន (គិតជា % នៃធនធាន |
|---|---|---|---|---|---|---|---|
| | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ទេសចរណ៍ | 1.1 | 0.2 | 16.8 | - | **16.9** | **17.2** | **99%** |
| ឧស្សាហូបនីយកម្ម និងពាណិជ្ជកម្ម | 3.0 | - | 16.0 | 0.3 | **16.3** | **18.3** | **89%** |
| សេវាធុរកិច្ច និងហិរញ្ញវត្ថុ | 12.2 | - | 9.2 | 3.5 | **12.7** | **14.8** | **86%** |
| នគរូបនីយកម្ម និងការគ្រប់គ្រង | 1.8 | 9.5 | - | - | **9.5** | **12.1** | **79%** |
| ថាមពល និងអគ្គិសនី | 108.2 | 42.1 | 9.3 | 4.5 | **55.9** | **88.6** | **63%** |
| កសិកម្ម | 51.0 | 18.0 | 66.0 | 21.3 | **105.3** | **181.7** | **58%** |
| ការដឹកជញ្ជូន | 33.3 | 77.8 | 40.0 | 1.1 | **119.0** | **216.6** | **55%** |
| វប្បធម៌ និងសិល្បៈ | 2.2 | 0.4 | 1.8 | - | **2.2** | **4.6** | **48%** |
| ការប្រែប្រួលអាកាសធាតុ | 0.5 | 1.1 | 3.5 | - | **4.6** | **11.3** | **41%** |
| អភិវឌ្ឍន៍ជនបទ | 16.8 | 8.1 | 20.4 | - | **28.5** | **74.8** | **38%** |
| បរិស្ថាន និងចីរភាព | 11.5 | 1.5 | 5.3 | - | **6.8** | **19.0** | **36%** |
| ទឹក និងអនាម័យ | 10.7 | 5.2 | 10.0 | 3.6 | **18.8** | **75.7** | **25%** |
| បច្ចេកវិទ្យា ព័ត៌មានវិទ្យា និងទំនាក់ទំនង | 12.0 | - | 0.2 | - | **0.2** | **0.9** | **23%** |
| ផ្សេងៗ | 1.3 | 8.8 | 0.2 | - | **9.0** | **63.8** | **14%** |
| សហគមន៍ និងសុខុមាលភាពសង្គម | 7.2 | 4.4 | 0.2 | 2.5 | **7.0** | **53.9** | **13%** |
| សុខាភិបាល | 23.4 | 17.0 | 10.1 | | **27.1** | **213.8** | **13%** |
| អប់រំ | 24.2 | 0.3 | 16.1 | 2.2 | **18.7** | **148.2** | **13%** |
| អភិបាលកិច្ច និងរដ្ឋបាល | 8.1 | 1.4 | 4.0 | 0.1 | **5.5** | **83.1** | **7%** |
| យេនឌ័រ | 2.1 | 0.1 | 0.1 | - | **0.2** | **3.8** | **5%** |
| ហ៊ីវ/អេដស៍ | - | - | - | - | **-** | **32.2** | **0%** |
| ជំនួយសង្គ្រោះបន្ទាន់ និងម្ហូបអាហារ | - | - | - | - | **-** | **0.3** | **0%** |
| **សរុប (មិនរាប់បញ្ចូលគម្រោងដែលគ្រោងអនុវត្ត)** | **330.8** | **195.9** | **229.3** | **39.0** | **464.2** | **1334.7** | **35%** |

តារាងទី ៤.៧ បង្ហាញថា អង្គការសុខភាពពិភពលោកបានបញ្ជ្រាបការអភិវឌ្ឍវិស័យឯកជនទៅក្នុងបណ្តាគម្រោងរបស់ខ្លួន ១០០% ។ មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្មបានប្រើប្រាស់ធនធាន ប្រមាណ ៩៣% ដើម្បីបញ្ជ្រាបការអភិវឌ្ឍវិស័យឯកជន ។ សាធារណរដ្ឋប្រជាមានិតចិន, ធនាគារអភិវឌ្ឍន៍អាស៊ី និងបារាំង គឺជាដៃគូអភិវឌ្ឍន៍សំខាន់ដែលបានផ្តល់ហិរញ្ញប្បទានគាំទ្រដល់ការអភិវឌ្ឍវិស័យឯកជន ក្នុងទម្រង់ជាអន្តរវិស័យ ក្នុងនោះ សាធារណរដ្ឋប្រជាមានិតចិនបានផ្តល់ធនធានប្រមាណ ១០១ លានដុល្លារ, ធនាគារអភិវឌ្ឍន៍អាស៊ី ៩៧ លានដុល្លារ និងបារាំង ៦៦ លានដុល្លារ ។ ដៃគូអភិវឌ្ឍន៍ ៩ ទៀតបានប្រើប្រាស់ជាងពាក់កណ្តាលនៃធនធានរបស់ខ្លួន សម្រាប់អនុវត្តគម្រោងដែលបានបញ្ជ្រាបការអភិវឌ្ឍវិស័យឯកជន ។

**តារាងទី ៤.៧: ការបញ្ជ្រាបរបស់ដៃគូអភិវឌ្ឍន៍ក្នុងការអភិវឌ្ឍវិស័យឯកជន ឆ្នាំ ២០១៦-២០១៧ (លានដុល្លារ)**

| ដៃគូអភិវឌ្ឍន៍ | សរុប ២០១៦ | ២០១៧ | | | | ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ ២០១៧ | វិស័យឯកជន (គិតជា % នៃហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍) |
|---|---|---|---|---|---|---|---|
| | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |
| WHO | 9.5 | 9.5 | - | - | **9.5** | **9.5** | **100%** |
| IFAD | 15.5 | 0.9 | 9.3 | 3.5 | **13.7** | **14.7** | **93%** |
| ILO | 2.7 | - | 0.2 | 3.0 | **3.2** | **3.7** | **88%** |
| UNICEF | 3.7 | 3.4 | 6.5 | - | **9.8** | **12.8** | **77%** |
| Czech Republic | 0.9 | 0.2 | 0.1 | 0.5 | **0.8** | **1.2** | **72%** |
| Australia | 41.2 | 1.6 | 15.2 | 21.9 | **38.7** | **56.3** | **69%** |
| ADB | 39.0 | 73.0 | 24.2 | - | **97.1** | **146.0** | **67%** |
| France | 27.8 | 8.9 | 57.0 | - | **65.9** | **103.3** | **64%** |
| Germany | 9.9 | 8.3 | 10.8 | - | **19.1** | **36.5** | **52%** |
| China | 92.3 | 76.0 | 24.9 | - | **100.9** | **223.5** | **45%** |
| Japan | 41.0 | 9.9 | 42.6 | 0.7 | **53.2** | **126.4** | **42%** |
| Switzerland | 4.1 | - | 4.7 | - | **4.7** | **13.8** | **34%** |
| UNIDO | 0.4 | - | 0.3 | 0.4 | **0.7** | **2.1** | **33%** |
| UNDP | 2.6 | 0.7 | 1.6 | - | **2.3** | **7.4** | **31%** |
| Republic of Korea | 12.1 | - | 12.3 | 2.0 | **14.3** | **51.2** | **28%** |
| New Zealand | 0.4 | - | 0.3 | 1.0 | **1.3** | **5.3** | **24%** |
| Canada | 0.4 | - | 0.1 | 0.3 | **0.4** | **1.6** | **23%** |
| USA | 13.5 | 1.8 | 10.1 | 5.3 | **17.2** | **76.0** | **23%** |
| EU/EC | 9.3 | 0.5 | 7.0 | 0.5 | **8.0** | **59.8** | **13%** |
| Sweden | 1.7 | 1.0 | 1.0 | - | **2.0** | **20.3** | **10%** |
| World Bank | 2.7 | - | 1.1 | - | **1.1** | **39.7** | **3%** |
| FAO | - | 0.1 | 0.0 | - | **71** | **4.8** | **1%** |
| Others | - | - | - | - | **-** | **107.4** | **0%** |
| **Total (Exclude Pipeline Projects)** | **330.8** | **195.9** | **229.3** | **39.0** | **464.2** | **1334.7** | **35%** |

## ជំពូក ៥

## តួនាទីហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការគាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្ម

នៅកម្ពុជា ហិរញ្ញប្បទានសហប្រតិបត្តិការមានតួនាទីគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម តាមរយៈការបង្កើតបរិស្ថានអំណោយផលសម្រាប់គាំទ្រវិនិយោគឯកជន និងជាកាតាលីករ

ដើម្បីគៀរគរធនធានពីប្រភពដទៃសម្រាប់ការអភិវឌ្ឍ ព្រមទាំងជាប្រភពធនធានសម្រាប់គាំទ្រដោយផ្ទាល់ក្នុងការផ្តល់ទំនិញ និងសេវាសាធារណៈ ដូចមានចែងក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥ ។ គោលនយោបាយនេះមានគោលដៅបន្តជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងកម្រិតខ្ពស់ថែមទៀត ក្នុងសង្វាក់ផលិតកម្មតំបន់ និងសកល ។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តវិធានការគោលនយោបាយ ៤ ឬ ផែនការសកម្មភាព និងវិធានការគន្លឹះ ៤ ជាក់ស្តែងដែលផ្សារភ្ជាប់នឹងគោលដៅ និងចំណុចដៅ ដែលត្រូវសម្រេចឱ្យបានត្រឹមឆ្នាំ ២០២៥ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញវិធានការគន្លឹះ ៤ ជាក់ស្តែង ដែលត្រូវសម្រេចមុនដំណាច់ឆ្នាំ ២០១៨ ផងដែរ ។

**តារាងទី ៥.១: វិធានការគោលនយោបាយ និងវិធានការគន្លឹះ ៤ ជាក់ស្តែង**

| **វិធានការគោលនយោបាយ ៤ ដែលត្រូវសម្រេចឆ្នាំ ២០២៥** | **វិធានការគន្លឹះ ៤ ជាក់ស្តែង ដែលត្រូវសម្រេចមុនដំណាច់ឆ្នាំ ២០១៨** |
|---|---|
| ការជំរុញការទាក់ទាញវិនិយោគ | រៀបចំ និងអនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនី សម្រាប់វិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម រួមទាំងការពង្រឹងភាពទុកចិត្ត និងការពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនី |
| ការពង្រីក និងទំនើបកម្មសហគ្រាសធុនតូច និងមធ្យម | រៀបចំ និងអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងឡូជិស្ទិក ពិសេស ផ្តោតលើការតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ និងការអភិវឌ្ឍរបៀងសេដ្ឋកិច្ច |
| ការកែលម្អបរិស្ថាននិយតកម្ម | ពង្រឹងយន្តការគ្រប់គ្រងទីផ្សារពលកម្ម និងការបណ្តុះបណ្តាលជំនាញ ដើម្បីរក្សាស្ថិរភាព និងបង្កើនផលិតភាពក្នុងការផ្គត់ផ្គង់កម្លាំងពលកម្ម |
| ការសម្របសម្រួលគោលនយោបាយគាំទ្រ | អភិវឌ្ឍ និងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ដែលគ្រោងអនុវត្តតាមគោលការណ៍តំបន់រដ្ឋបាលពិសេស |

នាខែ មិថុនា ឆ្នាំ ២០១៧ លេខាធិការដ្ឋាននៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ត្រូវបានបង្កើតឡើង សម្រាប់គាំទ្រក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងការអនុវត្តអាណត្តិរបស់ខ្លួនដែលមានចែងក្នុងគោលនយោបាយនេះ ។ ភារកិច្ចស្នូលនៃលេខាធិការដ្ឋាននេះ គឺការសម្របសម្រួលការងារជាមួយរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន, ការសិក្សាស្រាវជ្រាវ, ការពិនិត្យ តាមដាន និងការរៀបចំរបាយការណ៍វឌ្ឍនភាព ។ កិច្ចការសំខាន់ក៏បានផ្តោតលើការសិក្សាកម្រិតគោលនយោបាយពាក់ព័ន្ធនឹងការអភិវឌ្ឍឧស្សាហកម្ម ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ក្នុងគោលដៅពន្លឿនវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ។

ចាប់ពីគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ នាថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥, ក្រសួង និងស្ថាប័ន ព្រមទាំងអាជ្ញាធរថ្នាក់ក្រោមជាតិបានអនុវត្តផែនការសកម្មភាព និងវិធានការគោលនយោបាយ ។ គិតដល់ឆ្នាំ ២០១៦ រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពជាដុំកំភួន ក្នុងការអនុវត្តវិធានការគន្លឹះ ៤ ជាក់ស្តែង ដោយសារក្រសួង និងស្ថាប័នពាក់ព័ន្ធ

បានបញ្ចប់ការរៀបចំគោលនយោបាយតាមវិស័យ សម្រាប់ជំរុញការអនុវត្តគោលនយោបាយនេះ, បានសិក្សាពីសមិទ្ធិលទ្ធភាព, បានរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់គាំទ្រការអនុវត្តគម្រោង ព្រមទាំងបានពង្រីកវិសាលភាពគ្របដណ្តប់ការផ្គត់ផ្គង់អគ្គិសនី បានពាក់កណ្តាលនៃតំបន់ឧស្សាហកម្មគោលដៅទាំងមូល ។

ក្នុងនាមជាស្ថាប័នសម្របសម្រួល, គ.ជ.ទា/ក.អ.ក មានភារកិច្ចរៀបចំកម្មវិធីវិនិយោគសាធារណៈ សម្រាប់គាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ។ ក្នុងន័យនេះ គ.ជ.ទា/ក.អ.ក បានស្នើក្រសួង និងស្ថាប័នពាក់ព័ន្ធវាយតម្លៃអំពីតម្រូវការ និងរៀបចំបញ្ជីគម្រោងពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យឧស្សាហកម្មដែលកំពុងអនុវត្តដោយធនធានក្រៅប្រទេស ដោយប្រើប្រាស់ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ។ បន្ទាប់មក គ.ជ.ទា/ក.អ.ក នឹងបូកសរុបបញ្ជីគម្រោងវិនិយោគដែល កំពុងអនុវត្ត និងគម្រោងដែលមិនទាន់មានការគាំទ្រ សម្រាប់រៀបចំផែនការវិនិយោគសាធារណៈ ដើម្បីកំណត់ដៃគូដែលអាចផ្តល់ការគាំទ្រ ក៏ដូចជាតម្រឹមការប្រើប្រាស់ហិរញ្ញប្បទានក្រៅប្រទេស ជាមួយគម្រោងអាទិភាពដែលបានកំណត់ក្នុងផែនការវិនិយោគនេះ ។ គ.ជ.ទា/ក.អ.ក នឹងផ្សំផ្គុំតម្រូវការ ជាមួយនឹងធនធានដែលមានដើម្បីកំណត់ទំហំធនធានដែលខ្វះចន្លោះសម្រាប់កៀរគរបន្ថែម ។ ព័ត៌មានទាំងនេះនឹងត្រូវចែករំលែកជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងអនុវត្តថវិកា ។

## *តួនាទីហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា*

តួនាទីហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់គាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម រួមមាន ÷ ការបង្កើតបរិស្ថានអំណោយផលសម្រាប់គាំទ្រការវិនិយោគឯកជន, តួនាទីជាកាតាលីករដើម្បីកៀរគរហិរញ្ញប្បទានអភិវឌ្ឍន៍ពីប្រភពដទៃទៀតសម្រាប់កិច្ចអភិវឌ្ឍន៍ និងជាប្រភពធនធានសម្រាប់គាំទ្រដោយផ្ទាល់ ដល់ការផ្គត់ផ្គង់ទំនិញ និងសេវាសាធារណៈ ដូចមានចែងក្នុងគោលនយោបាយនេះ ។ ស្របតាមក្របខណ្ឌអភិវឌ្ឍន៍នេះ ហិរញ្ញប្បទានសហប្រតិបត្តិការផ្តល់ការគាំទ្រ សម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ, ការកសាងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស ពិសេសការបណ្តុះបណ្តាលពលករជំនាញ ។

ដោយទទួលស្គាល់ពីតួនាទីនៃហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការគាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និងផ្អែកលើព័ត៌មានដែលដៃគូអភិវឌ្ឍន៍បានបញ្ចូលក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ គ.ជ.ទា/ក.អ.ក បានពិនិត្យ និងតាមដានដោយយកចិត្តទុកដាក់អំពីទំហំហិរញ្ញប្បទាន ដែលបានគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ព្រមទាំងរំលេចតួនាទីសំខាន់នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ សម្រាប់ពន្លឿនការអនុវត្តគោលនយោបាយនេះ ។

## *ការវិភាគហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម*

ការវិភាគត្រូវបានរៀបចំតាមអភិក្រម ២ គឺ ÷ ១) ការវិភាគអំពីហិរញ្ញប្បទានតាមវិស័យ និងអនុវិស័យ ក្នុងប្រព័ន្ធទិន្នន័យស្ដីពីហិរញ្ញប្បទានសហប្រតិបត្តិការ តាមអាទិភាពនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម (វិធានការគោលនយោបាយ និងផែនការសកម្មភាព) និង ២) ការវិភាគតាមវិស័យសម្គាល់បន្ថែម ។

**តារាងទី ៥.២ : ការគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ ២០១៧ (លានដុល្លារ)**

| | វិធានការគោលនយោបាយនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម | | | | | |
|---|---|---|---|---|---|---|
| ដៃគូអភិវឌ្ឍន៍ | ការជំរុញការវិនិយោគ | ការពង្រីកសហគ្រាសធុនតូច និងមធ្យម | ការកែលម្អបរិយាកាស និយតកម្ម | ការសម្របសម្រួលគោលនយោបាយគាំទ្រ | វិធានការគន្លឹះ ៤ ជាក់ស្ដែង | សរុប |
| សាធារណរដ្ឋប្រជាមានិតចិន | - | - | - | - | 65.9 | **65.9** |
| បារាំង | - | - | 19.6 | 0.8 | 6.6 | **27.1** |
| ជប៉ុន | - | 0.9 | - | 3.0 | 10.9 | **14.8** |
| អូស្ត្រាលី | 1.6 | - | - | 5.7 | 3.4 | **10.7** |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 0.2 | - | - | - | 6.6 | **6.8** |
| សាធារណរដ្ឋកូរ៉េ | - | 0.0 | 1.6 | 4.1 | - | **5.7** |
| ណូវែលហ្សេឡង់ | - | - | - | 3.1 | - | **3.1** |
| មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម | - | 2.0 | - | - | - | **2.0** |
| ស្វីស | - | - | - | 1.4 | - | **1.4** |
| ស៊ុយអ៊ែត | - | - | - | 1.4 | - | **1.4** |
| សហភាពអឺរ៉ុប | - | - | 0.7 | 0.2 | 0.2 | **1.2** |
| អាល្លឺម៉ង់ | - | - | 1.1 | - | - | **1.1** |
| អង្គការពលកម្មអន្តរជាតិ | - | - | 0.5 | 0.6 | - | **1.0** |
| សហរដ្ឋអាមេរិក | - | - | 0.1 | 0.2 | 0.7 | **1.0** |
| កាណាដា | - | 0.3 | - | 0.2 | - | **0.4** |
| សាធារណរដ្ឋឆែក | - | - | - | - | 0.3 | **0.3** |
| អង្គការយូនីដូ | - | - | - | 0.3 | - | **0.3** |
| ចក្រភពអង់គ្លេស | - | - | - | 0.0 | - | **0.0** |
| **សរុប** | **1.8** | **3.2** | **23.6** | **21.1** | **94.7** | **144.2** |

តារាងទី ៥.២ បានបង្ហាញថា ក្នុងឆ្នាំ ២០១៧ ធនធាន ១៤៤ លានដុល្លារ ស្មើនឹង ១៣% នៃធនធានសរុប (មិនរាប់បញ្ចូលធនធានរបស់អង្គការមិនមែនរដ្ឋាភិបាល) ត្រូវបានបើកផ្ដល់សម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ។ ធនធានជិត ២/៣ បានគាំទ្រដល់ការអនុវត្តវិធានការគន្លឹះ ៤ ជាក់ស្ដែង ក្នុងនោះ ធនធាន ៨៨,៥ លានដុល្លារ បានគាំទ្រវិស័យថាមពល (សាធារណរដ្ឋប្រជាមានិតចិន ៦៦ លានដុល្លារ) ហើយ ៦,២ លានដុល្លារទៀត បានគាំទ្រវិស័យដឹកជញ្ជូន (ជប៉ុន ៦ លានដុល្លារ) ។

**តារាងទី ៥.៣ : ធនធានរយៈពេលមធ្យមសម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម (លានដុល្លារ)**

| ដៃគូអភិវឌ្ឍន៍ | ឆ្នាំ ២០១៤ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | សរុប |
|---|---|---|---|---|---|---|

| | | | | | | |
|---|---|---|---|---|---|---|
| សាធារណរដ្ឋប្រជាមានិតចិន | 33.2 | 45.1 | 122.2 | 65.9 | 67.6 | **334.0** |
| ជប៉ុន | 20.3 | 12.8 | 19.0 | 14.8 | 25.0 | **91.9** |
| បារាំង | 6.9 | 1.2 | 13.0 | 27.1 | 33.9 | **82.1** |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 15.0 | 11.1 | 9.8 | 6.8 | 19.7 | **62.3** |
| អូស្ត្រាលី | 9.2 | 7.3 | 9.5 | 10.7 | 5.9 | **42.6** |
| សហភាពអឺរ៉ុប | 11.6 | 2.8 | 1.7 | 1.2 | 1.0 | **18.4** |
| ណូវែលហ្សេឡង់ | 3.2 | 2.6 | 1.9 | 3.1 | 3.6 | **14.5** |
| សាធារណរដ្ឋកូរ៉េ | - | - | 1.1 | 5.7 | 3.2 | **10.0** |
| មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម | - | - | - | 2.0 | 6.0 | **7.9** |
| ធនាគារពិភពលោក | 4.6 | 1.8 | - | - | - | **6.4** |
| អាល្លឺម៉ង់ | 3.2 | 0.0 | 1.1 | 1.1 | 0.1 | **5.5** |
| ស៊ុយអែត | 0.8 | 1.1 | 1.3 | 1.4 | 0.6 | **5.2** |
| ស្វីស | 0.2 | 0.5 | 0.8 | 1.4 | 1.5 | **4.4** |
| សហរដ្ឋអាមេរិក | 1.1 | 1.2 | 0.8 | 1.0 | 0.3 | **4.3** |
| អង្គការពលកម្មអន្តរជាតិ | 0.2 | 0.9 | 1.0 | 1.0 | 0.2 | **3.3** |
| កាណាដា | 0.0 | 0.1 | 0.4 | 0.4 | 0.6 | **1.6** |
| សាធារណរដ្ឋឆែក | 0.3 | 0.3 | 0.4 | 0.3 | - | **1.2** |
| អង្គការយូនីដូ | 0.5 | 0.1 | 0.1 | 0.3 | - | **0.9** |
| អង្គការសហប្រជាជាតិសម្រាប់អភិវឌ្ឍន៍ | 0.1 | 0.0 | 0.1 | - | - | **0.1** |
| ចក្រភពអង់គ្លេស | 0.0 | 0.0 | 0.0 | 0.0 | 0.0 | **0.1** |
| អង្គការយូណេស្កូ | 0.0 | 0.0 | - | - | - | **0.0** |
| **សរុប** | **110.4** | **88.8** | **184.2** | **144.2** | **169.1** | **696.8** |

**តារាងទី ៥.៣ ៖ ធនធានរយៈពេលមធ្យមសម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម (លានដុល្លារ)**

| វិស័យនៃគោលនយោបាយ អភិវឌ្ឍន៍វិស័យឧស្សាហកម្ម | ឆ្នាំ ២០១៤ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | សរុប |
|---|---|---|---|---|---|---|
| ការជំរុញការវិនិយោគ | 0.2 | 0.2 | 3.3 | 1.8 | 3.4 | **8.9** |
| ការពង្រីកសហគ្រាសធុនតូច និងមធ្យម | 0.9 | 1.1 | 1.7 | 3.2 | 6.3 | **13.1** |
| ការកែលម្អបរិយាកាសនិយតកម្ម | 11.8 | 4.3 | 9.0 | 23.6 | 3.7 | **52.4** |
| ការសម្របសម្រួលគោលនយោបាយគាំទ្រ | 30.5 | 27.4 | 22.2 | 21.1 | 17.1 | **118.3** |
| វិធានការគន្លឹះ ៤ ជាក់ស្តែង | 67.0 | 55.9 | 148.0 | 94.7 | 138.6 | **504.1** |
| **សរុប** | **110.4** | **88.8** | **184.2** | **144.2** | **169.1** | **696.8** |

ដៃគូអភិវឌ្ឍន៍ដែលផ្តល់ធនធានច្រើន សម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម មាន ÷ សាធារណរដ្ឋប្រជាមានិតចិន, បារាំង, ជប៉ុន និងអូស្ត្រាលី ។ ទន្ទឹមនឹងនេះ ប្រព័ន្ធទិន្នន័យក៏បានបញ្ជាក់អំពីដៃគូអភិវឌ្ឍន៍ចំនួន ១៨ ដែលកំពុងគាំទ្រការអនុវត្តគោលនយោបាយនេះ ក្នុងនោះដៃគូអភិវឌ្ឍន៍ភាគច្រើនបានគាំទ្រដល់វិធានការគោលនយោបាយទី ៤ (ការសម្របសម្រួលគោលនយោបាយគាំទ្រ) ។ បើធៀបនឹងរបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ ២០១៦ ដៃគូអភិវឌ្ឍន៍ជាច្រើនបាន និងកំពុងគាំទ្រវិធានការគោលនយោបាយដទៃទៀតនៃគោលនយោបាយនេះ ។

តារាងទី ៥.៣ បានបង្ហាញពីធនធានរយៈពេលមធ្យមសម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ។ ដៃគូអភិវឌ្ឍន៍បានផ្តល់ធនធាន ៦៩៧ លានដុល្លារ (១៣៩ លានដុល្លារក្នុងមួយឆ្នាំ) សម្រាប់ដំណាក់កាលឆ្នាំ ២០១៤-២០១៨ ដែលធនធានភាគច្រើន (៥០៤ លានដុល្លារ) បានគាំទ្រវិធានការគន្លឹះ ៤ ជាក់ស្តែងនៃគោលនយោបាយ ។ សាធារណរដ្ឋប្រជាមានិតចិន គឺជាដៃគូសំខាន់ដែលបានបើកផ្តល់ធនធាន ៣៣៤ លានដុល្លារ សម្រាប់គាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ។

តារាងទី ៥.៤ បង្ហាញអំពីការបញ្ជ្រាបគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មទៅក្នុងគម្រោងរបស់ដៃគូអភិវឌ្ឍន៍ តាមរយៈវិស័យសម្គាល់បន្ថែម ។ ក្នុងឆ្នាំ ២០១៧ ដៃគូអភិវឌ្ឍន៍ចំនួន ១៥ បានចាត់ទុកគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ជាគោលដៅអាទិភាពសម្រាប់គាំទ្រ ដោយបានផ្តល់ធនធាន ៣៣៣ លានដុល្លារ ស្មើនឹង ២៥% នៃធនធានសរុប ។ ធនធានសម្រាប់បញ្ជ្រាបគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មបានកើន ១២២ លានដុល្លារ ធៀបនឹងឆ្នាំ ២០១៦ ដោយសារការបង្កើនធនធានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី, ជប៉ុន និងបារាំង ។ ជាក់ស្តែង ក្នុងឆ្នាំ ២០១៧ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ធនធាន ៨៤% នៃធនធានសរុបរបស់ខ្លួន សម្រាប់គាំទ្រដល់ការបញ្ជ្រាបគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ។ ជប៉ុនបានបើកផ្តល់ធនធាន ៥២ លានដុល្លារ សម្រាប់បញ្ជ្រាបគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មក្នុងកម្រិតខ្ពស់ ។

**តារាងទី ៥.៤ : ការបញ្ជ្រាបគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ ២០១៦-២០១៧ (លានដុល្លារ)**

| ដៃគូអភិវឌ្ឍន៍ | ២០១៦ | ២០១៧ | | | | ធនធានរបស់ដៃគូអភិវឌ្ឍន៍ | IDP គិតជា % នៃធនធានរបស់ដៃគូអភិវឌ្ឍន៍ |
|---|---|---|---|---|---|---|---|
| | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 63.2 | 2.8 | 112.6 | 6.7 | **122.2** | **146.0** | **84%** |
| អង្គការពលកម្មអន្តរជាតិ | 2.5 | - | 2.5 | 0.6 | **3.0** | **3.7** | **82%** |
| ជប៉ុន | 81.4 | 19.1 | 21.4 | 52.3 | **92.8** | **126.4** | **73%** |
| បារាំង | 14.4 | 2.1 | 58.5 | - | **60.6** | **103.3** | **59%** |
| អូស្ត្រាលី | 22.7 | 5.7 | 21.9 | - | **27.6** | **56.3** | **49%** |
| អង្គការសហប្រជាជាតិសម្រាប់អភិវឌ្ឍន៍ | 1.3 | 3.0 | 0.0 | - | **3.1** | **7.4** | **41%** |
| អាល្លឺម៉ង់ | 4.0 | 7.1 | 2.8 | 1.1 | **11.0** | **36.5** | **30%** |

| | | | | | | | |
|---|---|---|---|---|---|---|---|
| កាណាដា | 0.3 | - | 0.3 | - | **0.3** | **1.6** | **17%** |
| ស្វីស | 1.5 | 0.2 | 2.0 | - | **2.2** | **13.8** | **16%** |
| សហភាពអឺរ៉ុប | 11.1 | 7.0 | 0.5 | - | **7.5** | **59.8** | **13%** |
| អង្គការយូនីសេហ្វ | 0.9 | 1.3 | - | - | **1.3** | **12.8** | **10%** |
| មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម | 5.9 | 0.9 | - | - | **0.9** | **14.7** | **6%** |
| សាធារណរដ្ឋកូរ៉េ | 0.5 | 0.5 | - | - | **0.5** | **51.2** | **1%** |
| ស៊ុយអែត | 0.2 | 0.1 | - | - | **0.1** | **20.3** | **1%** |
| សហរដ្ឋអាមេរិក | 0.5 | 0.0 | 0.1 | - | **0.1** | **76.0** | **0%** |
| ផ្សេងៗ | - | - | - | - | **-** | **393.5** | **0%** |
| **សរុប (មិនរាប់បញ្ចូលគម្រោងដែលត្រៀមអនុវត្ត)** | **210.3** | **49.8** | **222.6** | **60.7** | **333.1** | **1334.7** | **25%** |

វិស័យសម្គាល់បន្ថែមអាចផ្តល់ព័ត៌មានស្តីពីការបញ្ជ្រាបគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មតាមវិស័យនីមួយៗ ។ តារាងទី ៥.៥ បង្ហាញថា ក្នុងឆ្នាំ ២០១៧ វិស័យដឹកជញ្ជូន, កសិកម្ម, និងទឹកស្អាត និងអនាម័យ គឺជាវិស័យចម្បងដែលបានទទួលធនធាន ២២៨ លានដុល្លារ សម្រាប់បញ្ជ្រាបគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ធៀបនឹងធនធានសរុប ៣៣៣ លានដុល្លារ សម្រាប់បញ្ជ្រាបគោលនយោបាយនេះ ។ ធនធានក្នុងវិស័យអភិបាលកិច្ច និងរដ្ឋបាល និងវិស័យអប់រំ សម្រាប់បញ្ជ្រាបគោលនយោបាយនេះបានធ្លាក់ចុះ ធៀបនឹងឆ្នាំ ២០១៦ ក្នុងនោះ ធនធានសម្រាប់វិស័យអភិបាលកិច្ច និងរដ្ឋបាល បានធ្លាក់ចុះ ២ លានដុល្លារ ទន្ទឹមនឹងធនធានសម្រាប់វិស័យអប់រំបានធ្លាក់ចុះ ២-៥ លានដុល្លារ ។ ដោយសារហិរញ្ញប្បទានក្រៅប្រទេស បានដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ, ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស, ការធ្លាក់ចុះធនធានក្នុងវិស័យទាំងនេះ គឺជាសញ្ញាណមួយ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ និងការគាំទ្របន្ថែម ពិសេសលើការកសាងសមត្ថភាព និងជំនាញ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចដែលផ្អែកលើវិស័យឧស្សាហកម្ម ។

**តារាងទី ៥.៥ : ការបញ្ជ្រាបគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មតាមវិស័យ ឆ្នាំ ២០១៦-២០១៧**

| វិស័យ | ២០១៦ | ២០១៧ | | | | ធនធានសរុបតាមវិស័យ | IDP គិតជា % នៃធនធានតាមវិស័យ |
|---|---|---|---|---|---|---|---|
| | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |
| ឧស្សាហូបនីយកម្ម និងពាណិជ្ជកម្ម | 1.9 | - | 14.9 | 1.1 | **16.0** | **18.3** | **87%** |
| នគរូបនីយកម្ម និងការគ្រប់គ្រង | 3.1 | - | 9.5 | - | **9.5** | **12.1** | **79%** |
| ទឹកស្អាត និងអនាម័យ | 30.3 | - | 51.0 | 0.7 | **51.7** | **75.7** | **68%** |
| ការដឹកជញ្ជូន | 68.5 | 0.7 | 59.0 | 47.7 | **107.3** | **216.6** | **50%** |
| ការប្រែប្រួលអាកាសធាតុ | 0.4 | 3.5 | 1.1 | - | **4.6** | **11.3** | **41%** |
| កសិកម្ម | 30.5 | 16.6 | 50.2 | 3.2 | **70.0** | **181.7** | **38%** |
| ទេសចរណ៍ | 1.2 | - | 4.6 | - | **4.6** | **17.2** | **27%** |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ថាមពល និងអគ្គិសនី | 15.5 | - | 19.0 | 2.4 | **21.4** | **88.6** | **24%** |
| ការអភិវឌ្ឍជនបទ | 11.3 | 6.8 | 7.0 | - | **13.7** | **74.8** | **18%** |
| អភិបាលកិច្ច និងរដ្ឋបាល | 12.3 | 9.4 | 0.1 | 0.7 | **10.2** | **83.1** | **12%** |
| ផ្សេងៗ | 0.1 | 6.1 | 1.1 | - | **7.2** | **63.8** | **11%** |
| សហគមន៍ និងសុខុមាលភាពសង្គម | 3.3 | 1.5 | 2.5 | - | **3.9** | **53.9** | **7%** |
| សេវាធុរកិច្ច និងហិរញ្ញវត្ថុ | 1.7 | 0.2 | 0.8 | - | **1.0** | **14.8** | **7%** |
| អប់រំ | 13.0 | 1.3 | 1.7 | 5.0 | **8.0** | **148.2** | **5%** |
| បរិស្ថាន និងចីរភាព | 0.4 | 1.0 | - | - | **1.0** | **19.0** | **5%** |
| វប្បធម៌ សិល្បៈ និងកីឡា | 0.3 | 0.2 | - | - | **0.2** | **4.6** | **4%** |
| យេនឌ័រ | 0.3 | - | 0.1 | - | **0.1** | **3.8** | **3%** |
| សុខាភិបាល | 4.0 | 2.6 | - | - | **2.6** | **213.8** | **1%** |
| ជំនួយសង្គ្រោះបន្ទាន់និងស្បៀងអាហារ | 0.2 | - | - | - | **-** | **0.3** | **0%** |
| ហ៊ីវ/អេដស៍ | - | - | - | - | **-** | **32.2** | **0%** |
| បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ | 12.0 | - | - | - | **-** | **0.9** | **0%** |
| **សរុប (មិនគិតគម្រោងពុំទាន់អនុវត្ត)** | **210.3** | **49.8** | **222.6** | **60.7** | **333.1** | **1334.7** | **25%** |

### ***ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងឧត្តមសិក្សា***

គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ទទួលស្គាល់សារៈសំខាន់នៃការលើកកម្ពស់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។ លើមូលដ្ឋាននេះ ក្នុងខែ មិថុនា ឆ្នាំ ២០១៧ រាជរដ្ឋាភិបាលបានអនុម័តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ ២០១៧-២០២៥ ដោយមានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាសេនាធិការដឹកនាំការអនុវត្ត ។ គោលនយោបាយជាតិនេះនឹងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយជំរុញឱ្យមានការចូលរួម និងការកៀរគរធនធានពីភាគីពាក់ព័ន្ធសំខាន់ៗ ។ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មបានកំណត់កិច្ចការជាក់លាក់មួយចំនួនដែលពាក់ព័ន្ធនឹងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ រួមមាន ៖

- ជំរុញការអប់រំចំណេះដឹងទូទៅ យ៉ាងហោចឱ្យបានត្រឹមថ្នាក់ទី ៩
- ពង្រឹងគុណភាពអប់រំផ្នែកគណិតវិទ្យា, វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា
- បង្កើតសាលាមធ្យមសិក្សាបច្ចេកទេស និងមជ្ឈមណ្ឌលហ្វឹកហ្វឺនជំនាញ
- រៀបចំផែនការបណ្តុះបណ្តាលបច្ចេកទេស និងវិទ្យាសាស្ត្រ ដែលបម្រើឱ្យវិស័យឧស្សាហកម្ម
- ជំរុញស្ថាប័ននីយកម្មនូវកម្មវិធីប្រព័ន្ធកម្មសិក្សា (Apprenticeship Schemes) ដែលផ្សារភ្ជាប់ជាមួយប្រព័ន្ធលើកទឹកចិត្តដល់វិស័យឯកជន
- ពង្រីកការបណ្តុះបណ្តាលជំនាញ និងវិជ្ជាជីវៈនៅនឹងកន្លែងការងារសម្រាប់កម្មកររោងចក្រ ។

ក្រៅពីសារៈសំខាន់ក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈគឺជាគន្លឹះសម្រាប់ធានាស្ថិរភាពការងារនាអនាគត តាមរយៈការលើកកម្ពស់សមត្ថភាពការងាររបស់ពលករ និង

យុវជន ដែលជាកត្តាសំខាន់សម្រាប់លើកកម្ពស់សុខុមាលភាព និងអភិវឌ្ឍធនធានមនុស្ស ។ ដើម្បីសម្រេចជោគជ័យក្នុងកិច្ចការនេះ ដៃគូអភិវឌ្ឍន៍គប្បីបង្កើនការគាំទ្រដល់ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីតម្រឹមទៅនឹងអាទិភាពរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុងគោលនយោបាយជាតិស្តីពីការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ។

តារាងទី ៥.៦ បង្ហាញថា គម្រោងកំពុងអនុវត្តដែលពាក់ព័ន្ធនឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងឧត្តមសិក្សា (ទាំងអាហារូបករណ៍ និងអ្នកបច្ចេកទេសស្ម័គ្រចិត្ត) មានហិរញ្ញប្បទានសរុបប្រមាណ ២៨៨,៧៤ លានដុល្លារ ។ បើគិតជាមធ្យមប្រចាំឆ្នាំ មានទំហំ ពី ២៦-៣២ លានដុល្លារ ក្នុងចន្លោះឆ្នាំ ២០១៥-២០១៧ ។ ទោះជាយ៉ាងនេះក្តី ហិរញ្ញប្បទានដែលបានផ្តល់សម្រាប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅមានកម្រិតទាប ប្រមាណ ៧,៩ លានដុល្លារ ក្នុងឆ្នាំ ២០១៧ ដោយជប៉ុន និងស្វីសគឺជាដៃគូសំខាន់ ។ ដៃគូអភិវឌ្ឍន៍ចំនួន ៩ បានគាំទ្រការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រោមយន្តការសម្របសម្រួល ទន្ទឹមនឹងការប្តេជ្ញាកៀរគរធនធានរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ។ ទាំងនេះបង្ហាញពីការកើនឡើងនូវសក្តានុពលនៃកិច្ចសហប្រតិបត្តិការសម្រាប់វិស័យមួយនេះ ។

**តារាងទី ៥.៦ : ធនធានរបស់ដៃគូអភិវឌ្ឍន៍សម្រាប់ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងឧត្តមសិក្សា (លានដុល្លារ)**

| | ថវិកាសរុប | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|
| **ឧត្តមសិក្សា** | | | | |
| សាធារណរដ្ឋឆែក | 0.21 | 0.04 | 0.12 | - |
| បារាំង | 10.69 | 0.82 | 0.68 | 0.41 |
| ជប៉ុន | 14.04 | 3.51 | 0.64 | 0.67 |
| សាធារណរដ្ឋកូរ៉េ | 5.28 | - | 0.58 | 4.13 |
| ស៊ុយអ៊ែត | 0.13 | 0.01 | 0.04 | 0.04 |
| ចក្រភពអង់គ្លេស | 0.31 | - | - | 0.20 |
| អង្គការយូណេស្កូ | 0.03 | 0.02 | - | - |
| ធនាគារពិភពលោក | 11.50 | 1.79 | - | - |
| **សរុបឧត្តមសិក្សា** | **42.18** | **6.20** | **2.06** | **5.45** |
| **ការផ្តល់អាហារូបករណ៍** | | | | |
| អូស្ត្រាលី | 70.74 | 6.15 | 5.53 | 5.67 |
| កាណាដា | 0.98 | 0.09 | 0.16 | 0.16 |
| បារាំង | 8.31 | 0.39 | 0.52 | 0.40 |
| ជប៉ុន | 21.98 | 1.99 | 3.00 | 1.68 |

| | | | | |
|---|---|---|---|---|
| ណូវែលហ្សេឡង់ | 24.45 | 2.61 | 1.95 | 3.14 |
| **សរុបការផ្ដល់អាហារូបករណ៍** | **126.47** | **11.23** | **11.16** | **11.06** |
| **ការផ្ដល់អ្នកបច្ចេកទេសស្ម័គ្រចិត្ត** | | | | |
| ជប៉ុន | 17.74 | 2.77 | 2.28 | 2.41 |
| **សរុបការផ្ដល់អ្នកបច្ចេកទេសស្ម័គ្រចិត្ត** | **17.74** | **2.77** | **2.28** | **2.41** |
| **ការបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ** | | | | |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 53.12 | 5.67 | 1.18 | - |
| សហភាពអឺរ៉ុប | 1.86 | 0.42 | 0.31 | 0.20 |
| បារាំង | 3.26 | - | 2.91 | - |
| អង្គការពលកម្មអន្តរជាតិ | 1.28 | 0.28 | 0.41 | 0.58 |
| ជប៉ុន | 24.81 | 3.45 | 3.84 | 3.35 |
| ស៊ុយអ៊ែត | 6.25 | 1.08 | 1.05 | 1.37 |
| ស្វីស | 10.70 | 0.66 | 1.48 | 2.17 |
| ចក្រភពអង់គ្លេស | 0.06 | - | 0.01 | 0.03 |
| សហរដ្ឋអាមេរិក | 1.00 | 0.40 | 0.20 | 0.20 |
| **សរុបការបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ** | **102.34** | **11.95** | **11.39** | **7.89** |
| **សរុប** | **288.74** | **32.14** | **26.89** | **26.81** |

# ជំពូក ៦

# សេចក្ដីសន្និដ្ឋាន

ក្រោមការដឹកនាំ និងភាពជាម្ចាស់ដ៏រឹងមាំរបស់រាជរដ្ឋាភិបាល និងដោយមានការគាំទ្រពីដៃគូអង្គអភិវឌ្ឍន៍ទាំងអស់ កម្ពុជាបានសម្រេចសមិទ្ធផលធំធេងក្នុងការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច ។ ជាក់ស្ដែង កម្ពុជារក្សាបានកំណើនសេដ្ឋកិច្ចខ្ពស់ប្រចាំឆ្នាំ ជាមធ្យម ៧,៧% និងអត្រាភាពក្រីក្រធ្លាក់ចុះពី ៥៣,២% ក្នុងឆ្នាំ ២០០៤ មកត្រឹម ១៣,៥% ក្នុងឆ្នាំ ២០១៤ ។ ដើម្បីពង្រឹងវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តឱ្យបានជោគជ័យនូវកម្មវិធីតាមវិស័យ សម្រាប់គាំទ្រដល់ការប្រែប្រួលខាងរចនាសម្ព័ន្ធ និងការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច ទន្ទឹមនឹងការបន្តអនុវត្តកម្មវិធីកែទម្រង់ស្នូល ដូចជាការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការកែទម្រង់រដ្ឋបាលសាធារណៈ និងការកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

របាយការណ៍នេះគឺជាសក្ខីកម្មដែលអាចបញ្ជាក់ថា ការបន្តកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងអស់ នឹងនាំទៅដល់ការសម្រេចលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ ។ ទន្ទឹមនឹងនេះ ក៏បង្ហាញអំពីកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការ និងតម្រឹមធនធានទាំងនេះជាមួយអាទិភាពជាតិ ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៤-២០១៨ ។ លទ្ធផលវិភាគបានបង្ហាញថា ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ការបើកផ្ដល់ហិរញ្ញប្បទានសហប្រតិបត្តិការបានតម្រឹមជាមួយតម្រូវការធនធានសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ទោះបីមានការប្រែប្រួលតួនាទីនៃហិរញ្ញប្បទានសហប្រតិបត្តិការក៏ដោយ ក៏ហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណងបន្តរក្សាទំហំនឹងនរ

ទន្ទឹមនឹងការកើនឡើងនូវកម្ចីសម្បទាន ក្នុងបរិការណ៍ដែលកម្ពុជាបានសម្រេចឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប ។ ស្ថានភាពរបស់កម្ពុជានេះ មានសង្គតិភាពជាមួយស្ថានភាពនៃប្រទេសដទៃ ដែលបានសម្រេចឋានៈប្រទេសមានចំណូលមធ្យម ។

